ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

យុទ្ធសាស្ត្រ និងផែនយោធាយប្រយុទ្ធប្រឆាំងអំពើពុករលួយ ផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី ៤ ២០២៥-២០៣០

ស្ថាប័នប្រឆាំងអំពើពុករលួយ (ស.ប.ព.)

គ្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព.)

អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.)

ព្រះរាជសារ
ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
ក្នុងឱកាសជាកិច្ចអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិ
ប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី ៤
(២០២៥-២០៣០)

វិបុលភាព និងការរីកចម្រើនគ្រប់វិស័យរបស់មាតុភូមិជាទីស្រឡាញ់នៃយើង ឆ្លុះបញ្ចាំងពីមាគ៌ាដឹកនាំដ៏ថ្លៃថ្លា និងត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំជាច្រើនអាណត្តិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។ ពីកំណើនសេដ្ឋកិច្ចប្រមាណ ៧% ជាង ២ ទសវត្សរ៍ដល់ការកាត់បន្ថយភាពក្រីក្រមកនៅក្រោម១០% ពីការអភិវឌ្ឍពីទីក្រុងដល់ជនបទ លើហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ផ្លូវ ថ្នល់ ទឹក ភ្លើង ដល់ការរក្សាសន្តិសុខសាធារណៈ និងពីកំណែទម្រង់ហើយកំណែទម្រង់ទៀត ជាសក្ខីភាពនៃគុណភាពបម្រើជាតិ និងប្រសិទ្ធភាពបម្រើរាស្ត្ររបស់រាជរដ្ឋាភិបាល ដែលបានប្រឹងប្រែងប្រើអស់នូវកម្លាំង ប្រាជ្ញាស្មារតីបំពេញទំនួលខុសត្រូវដល់ប្រជារាស្ត្រ ដែលបានប្រគល់ជូន ហើយថែមទាំងបានកសាងថ្មាល និងធនធានបន្តវេនដឹកនាំប្រកបដោយភាពជឿជាក់ និងមោទនភាពជាតិសម្រាប់រាជរដ្ឋាភិបាល អាណត្តិទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ដែលជាងពីរឆ្នាំនៃការដឹកនាំគឺពោរពេញដោយឆន្ទៈ ការប្តេជ្ញាខ្ពស់ ភាពស្មៀវក្លា និងថាមពល។ ជាមួយនឹងបញ្ហាប្រឈម ឧបសគ្គនានា នៅក្នុងបរិការណ៍ពិភពលោកប្រកបដោយភាពមិននឹងនរទាំងផ្នែកសន្តិសុខសង្គម និងសេដ្ឋកិច្ច ការប្រកួតប្រជែងកាន់តែជ្រាលជ្រៅ ទាំងកម្រិតតំបន់ និងសកល និងកម្មវិធីគោលនយោបាយដឹកនាំប្រទេសប្រកបដោយមហិច្ឆតា ដែលបានដាក់ចេញ ខ្ញុំមានជំនឿថាមាតុភូមិកម្ពុជាយើងមានសុវត្ថិភាពក្នុងដំណើរឆ្ពោះទៅកាន់គោលដៅកសាង និងអភិវឌ្ឍថ្មីៗ ប្រកបដោយចីរភាពយូរអង្វែង ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលបច្ចុប្បន្នផង និងការចូលរួមតម្រែតម្រង់ទិស និងគាំទ្រដោយឥតលក្ខខណ្ឌពីសំណាក់ ថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាលមុនៗផង ។

ខ្ញុំមានជំនឿជឿជាក់ថា ការចូលរួមជាកម្លាំងរួមមួយជាមួយរាជរដ្ឋាភិបាលក្នុងរបៀបវារៈកសាង និងអភិវឌ្ឍបន្តទៀត មានតម្លៃជាសារវន្ត ជាពិសេសលើការអនុវត្តការងារកែទម្រង់រដ្ឋ និងការងារអាទិភាពនានាដូចជាការជំរុញអភិបាលកិច្ចល្អ និងការប្រឆាំងអំពើពុករលួយ ដែលជារបៀបវារៈសំខាន់មួយរបស់រាជរដ្ឋាភិបាលជាដើម។ ការចូលរួមនឹងតម្រូវឱ្យយើងចាប់ផ្តើមពីម្នាក់ៗ ពីក្រុមមួយៗ ពីសហគមន៍មួយៗ និងពីសង្គមយើងមួយទាំងមូល។ យើងម្នាក់ៗចាំបាច់ត្រូវលះបង់ប្រយោជន៍សូនតូ ប្រកាន់ខ្ជាប់នូវផ្នត់គំនិតស្អាតស្អំ សុចរិតភាព និងប្រព្រឹត្តតែអំពើល្អ។ ការប្រាសចាកពីទង្វើដ៏ថ្លៃថ្លាទាំងនេះ ជាពិសេសដោយសារតែប្រយោជន៍សូនតូ ការលោភលន់ ការយកប្រយោជន៍រួមមកធ្វើផលចំណេញផ្ទាល់ខ្លួន ក៏ដូចជាការប្រព្រឹត្តអំពើពុករលួយ នឹងបង្កើតបានជាឧបសគ្គដល់ការស្តារ ការអភិវឌ្ឍ និងដល់ការកសាងសង្គមកម្ពុជា ឱ្យកាន់តែរីកចម្រើន សំដៅប្រែក្លាយមាតុប្រទេសយើងឱ្យទៅជាអារ្យប្រទេសប្រកបដោយភាពជឿនលឿន ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងជាច្រើនឆ្នាំកន្លងមក ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ខ្ញុំបានមើលឃើញនូវសមិទ្ធផលគួរជាទីមោទនៈជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ក៏ដូចជារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ដែលជាសេនាធិការជូនរដ្ឋ ដឹកនាំ និងជំរុញការងារប្រឆាំងអំពើពុករលួយ មានជាអាទិ៍ ការបណ្តុះបណ្តាលផ្នត់គំនិតស្អាតស្អំ ការរស់នៅល្អ ស្អប់ខ្ពើមអំពើពុករលួយ និងការកសាងថ្នាលសុចរិតភាពចាប់ពីកុមារភាព ដល់កូនចៅជំនាន់ក្រោយ ការចូលរួមកសាងយុត្តិធម៌សង្គម ជាពិសេសក្នុងស្រទាប់យុវជន ដែលជាទំពាំងស្នងឫស្សី និងជាអនាគតមាតុភូមិយើង និងការអនុវត្តច្បាប់ប្រកបដោយមនសិការ និងឧត្តមគតិ។ ការឈ្មុសឈ្មុលលើការងារប្រកបដោយភាពច្នៃប្រឌិត និងពោរពេញដោយផ្លែផ្កាទាំងនេះ ពិតជាបានរួមចំណែកដល់ការកសាងគ្រឹះនៃការអភិវឌ្ឍ ពូនផ្តុំថ្នាលបរិយាកាសសស្អាតទាំងការរស់នៅ និងការប្រកបធុរកិច្ចចិញ្ចឹមជីវិត ហើយក៏បានលើកស្ទួយអនាគតប្រទេសឱ្យបានកាន់តែថ្កុំថ្កើងផងដែរ ។

ក្នុងឱកាសនៃការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤(២០២៥-២០៣០) ពីសំណាក់ស្ថាប័នប្រឆាំងអំពើពុករលួយ ខ្ញុំសូមសំដែងនូវការគាំទ្រ និងវាយតម្លៃខ្ពស់ ចំពោះការប្តេជ្ញា និងឆន្ទៈមោះមុត ក្នុងការជ្រោងទង់ ដើម្បីឱ្យនាវាកម្ពុជាយើងឆ្លងផុតអស់នូវឧបសគ្គ និងអាចបោះពួយទៅមុខបានកាន់តែលឿន ឆ្ពោះទៅកាន់ត្រើយសុខក្សេមក្សាន្តជារៀងរហូត។ ចក្ខុវិស័យវែងឆ្ងាយ និងគោលដៅប្រកបដោយមហិច្ឆតាទៅមុខ អមដោយយុទ្ធសាស្ត្រ និងនយោបាយប្រឆាំងអំពើពុករលួយ ដែលកំពុងត្រូវបានដាក់ចេញពេលនេះ នឹងអាចសម្រេចទៅបាននៅពេលយើងទាំងអស់រួមសាមគ្គី គាំទ្រ និងចូលរួមជាមួយរាជរដ្ឋាភិបាល និងស្ថាប័នប្រឆាំងអំពើពុករលួយ ។

ខ្ញុំសូមជូនពរថ្នាក់ដឹកនាំ មន្ត្រីរាជការនៃស្ថាប័នប្រឆាំងអំពើពុករលួយ គ្រួអង្គពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងនយោបាយដ៏សំខាន់នេះ ក៏ដូចជាជនរួមជាតិគ្រប់ៗរូប បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ឧកញ៉ា សីហមុនី

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២៦

ព្រឹទ្ធសភា

សារលិខិត
ក្នុងឱកាសជាកិច្ចអនុវត្តន៍ទសវត្សរ៍យុទ្ធសាស្ត្រ និងនយោបាយ ប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤ (២០២៥-២០៣០)

កម្ពុជាក្នុងដំណើរស្វែងរកសន្តិភាព កសាង និងអភិវឌ្ឍដូចសព្វថ្ងៃ ពោរពេញដោយឧបសគ្គ - បញ្ហាប្រឈម - វិបត្តិដែលពីដំណាក់មួយទៅមួយតែងស្តែងឱ្យឃើញពីការលះបង់ - បូជា - ការប្តេជ្ញា - ការរួមកម្លាំងសាមគ្គីក្នុងការដឹកនាំប្រទេស និងការគាំទ្រផ្តល់ទំនុកចិត្តចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាលទាំងក្នុងអាណត្តិនៃរាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់រូបខ្ញុំ និងបន្តដល់ការដឹកនាំរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ក្រោមម្លប់ជាតិ សាសនា ព្រះមហាក្សត្រនៃយើង ប្រជាជនកម្ពុជាបានរួមជាមួយរាជរដ្ឋាភិបាល បង្ហាញនូវភាពរឹងមាំ ប្រឹងរស់ ប្រឹងកសាង ប្រឹងអភិវឌ្ឍ ប្រឹងកែលម្អ ប្រឹងថែរក្សា និងប្រឹងទំនើបកម្ម ដើម្បីសន្តិភាព និងការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ តម្លៃនៃភាពរឹងមាំ ជាពិសេសពីខាងក្នុងរបស់កម្ពុជាត្រូវបានស្តែងឱ្យឃើញកាន់តែច្បាស់ និងកាន់តែសំខាន់ជាសារវន្តក្នុងកាលៈទេសៈនៃដំណើរការអភិវឌ្ឍប្រទេសនាពេលបច្ចុប្បន្ន។ យើងត្រូវបន្តរួមគ្នាតាមគ្រប់រូបភាព តាមគ្រប់លទ្ធភាព ក្នុងនាមជាប្រជាជាតិមួយ ដើម្បីពង្រឹង និងពង្រីកធនធានមនុស្សយើងឱ្យកាន់តែខ្លាំងក្លាពីមួយជំនាន់ទៅមួយជំនាន់ - ចាក់គ្រឹះសេរីភាពការពារឱ្យកាន់តែជ្រៅ និងអភិវឌ្ឍប្រទេសឱ្យកាន់តែខ្លាំង និងកាន់តែមានប្រសិទ្ធភាពក្នុងកម្រិតកាន់តែខ្ពស់ សំដៅថែរក្សាឱ្យបានគង់វង្សនូវបូរណភាពដែនដី និងអធិបតេយ្យ និងនាំមកនូវវិបុលភាពដល់ប្រទេស ដល់ប្រជាពលរដ្ឋបានកាន់តែច្រើនបន្ថែមទៀត។

បទពិសោធដឹកនាំប្រទេស ដឹកនាំរាជរដ្ឋាភិបាល ៣៨ ឆ្នាំ ជាមួយសហការីប្រកបដោយភាពស្មោះស្ម័គ្រ និងគុណភាពជាច្រើន តាំងពីបាតដៃទទេ កវែក កឆ្នាំង ខ្វះមុខ ខ្វះក្រោយ បទពិសោធន៍ល្វីងជូរចត់ផ្អែមប្រៃគ្រប់រសជាតិ ខ្ញុំបានឆ្លងកាត់រហូតដល់ការសម្រេចបាននូវសន្តិភាពពេញផ្ទៃប្រទេស - រៀបចំបាននូវគ្រឹះសម្រាប់ការអភិវឌ្ឍ ទាំងក្របខណ្ឌរដ្ឋបាលគ្រប់គ្រង - ច្បាប់ និងបទដ្ឋានគតិយុត្តអំណោយផលដល់ការចូលរួមពីគ្រប់តួអង្គសំខាន់ៗទាំងអស់ក្នុងសង្គម ទាំងរដ្ឋ - ឯកជន - សង្គមស៊ីវិល - ផ្នែកសិក្សាធិការ - សារព័ត៌មាន និងមហាជនទូទៅ និងជាពិសេសគឺការទទួលបាននូវការគាំទ្រដ៏ខ្លាំងក្លាពីសំណាក់ពលរដ្ឋម្ចាស់ប្រទេស ម្ចាស់ឆ្នោត ដូចបានស្តែងឡើងនៅក្នុងការបោះឆ្នោតសាកល តាមបែបប្រជាធិបតេយ្យសេរីពហុបក្ស នាពេលកន្លងមក។ ក្នុងរយៈពេលជាង ២ ឆ្នាំនៃការផ្តល់ឱកាសបន្តវេនដល់ទំពាំងស្នងឫស្សីដែលជាធនធានជំនាន់ថ្មីដឹកនាំប្រទេស ដឹកនាំរាជរដ្ឋាភិបាល អាណត្តិទី៧ នេះ ខ្ញុំឃើញនូវគុណភាព និងប្រសិទ្ធភាពពិតប្រាកដនៃការដឹកនាំ - កំណែទម្រង់ និងការអភិវឌ្ឍ រក្សានូវអ្វីដែលល្អ កែនូវអ្វីដែលមិនទាន់ប្រសើរ និងដាក់ចេញនូវអ្វីដែលថ្មីៗបន្ថែមទៀត សំដៅជំរុញល្បឿននាវាកម្ពុជាយើងឱ្យកាន់តែទៅ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

មុខលឿនឆ្ពោះទៅកាន់ត្រើយសុខដុមរុងរឿងដូចអរិយប្រទេសនានា។ ជាមួយសក្តីភាពទាំងនេះ ខ្ញុំហ៊ានអះអាងថាកម្ពុជាកំពុងដើរលើផ្លូវមួយដ៏ត្រឹមត្រូវ ក្រោមការជ្រោងទង់បន្តវេនដឹកនាំដោយប្រមុខរាជរដ្ឋាភិបាល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**។ ខ្ញុំក៏សូមអំពាវនាវដល់គ្រប់ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋទាំងអស់ រួមទាំងពលរដ្ឋទូទៅ បន្តចូលរួមជាមហាគ្រួសារកម្ពុជា ជាមួយរាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធី - គោលនយោបាយដឹកនាំប្រទេស ដែលបានដាក់ចេញ ជាពិសេសការអនុវត្តនូវផែនទីបង្ហាញផ្លូវដឹកនាំប្រទេស ដែលហៅថា **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ (២០២៣-២០២៨)** ដែលបានដាក់ចេញបន្តពីយុទ្ធសាស្ត្រអាណត្តិមុនៗ និងពង្រីកការគ្របដណ្តប់កាន់តែមានភាពគ្រប់ជ្រុងជ្រោយ ប្រទាក់ក្រឡា និងឆ្លើយតបទៅនឹងការវិវត្ត និងបរិបទប្រទេស និងពិភពលោក។

នៅក្នុងឱកាសនៃការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយដំណាក់កាលទី៤ (២០២៥-២០៣០) ដែលត្រូវបានបន្សុីជាមួយយុទ្ធសាស្ត្របញ្ចកោណ សំដៅគាំទ្រដល់ការជំរុញអភិបាលកិច្ចល្អ - ស្ថាប័នសាធារណៈស្អាតស្អំ ដែលជាស្នូលគន្លឹះមួយនៃយុទ្ធសាស្ត្របញ្ចកោណ ដោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដើម្បីអង្គភាពប្រឆាំងអំពើពុករលួយទទួលអនុវត្ត ខ្ញុំសូមស្នើដល់គ្រប់តួអង្គពាក់ព័ន្ធ គ្រប់វិស័យ គ្រប់ផ្នែកទាំងអស់ ចូលរួមគាំទ្រ និងអនុវត្តតួនាទី - ភារកិច្ច និងការទទួលខុសត្រូវ ដែលខ្លួនមានរៀងៗខ្លួន ដើម្បីប្រយោជន៍ជាតិ ប្រយោជន៍សាធារណៈ។ ក្នុងឋានៈជាប្រធានព្រឹទ្ធសភា ខ្ញុំក៏សូមជំរុញការចូលរួមអនុវត្តយុទ្ធសាស្ត្រនេះពីសំណាក់ស្ថាប័ននីតិប្បញ្ញត្តិ ជាពិសេសការជំរុញការងារ និងការចូលរួមក្នុងរូបភាព - ទម្រង់ជាច្រើនទៀតពីសំណាក់គណៈកម្មការទី១០ នៃព្រឹទ្ធសភា ទាំងការបំពេញតួនាទីភារកិច្ច ការជ្រោមជ្រែង គាំទ្រ និងការបំពេញនូវទិដ្ឋភាពច្បាប់ និងបទដ្ឋានគតិយុត្តចាំបាច់ដល់កិច្ចប្រឹងប្រែងរួមគ្នានេះ ជាមួយអង្គប្រតិបត្តិ - តុលាការ - ស្ថាប័នប្រឆាំងអំពើពុករលួយ និងស្ថាប័នអន្តរជាតិ ទាំងក្នុង និងក្រៅតំបន់ ដែលចូលរួមដល់កិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រង និងដឹកនាំប្រទេស។

ខ្ញុំសូមជូនពរដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃស្ថាប័នប្រឆាំងអំពើពុករលួយ តួអង្គពាក់ព័ន្ធទាំងអស់ ក៏ដូចជាជនរួមជាតិគ្រប់ៗរូប បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕.

ថ្ងៃព្រហស្បតិ៍ ៩កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២៦

ប្រធានព្រឹទ្ធសភា
និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃ ព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុជារី
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

សារលិខិតអបអរសាទរ
ការជាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ
ប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤ (២០២៤-២០៣០)

ក្រោមរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ តាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាដែលបានបង្កើតឡើងក្រោយការបោះឆ្នោតជាសាកលឆ្នាំ១៩៩៣ បានបំពេញតួនាទីស្នូលរបស់ខ្លួនយ៉ាងសកម្ម ជាអាទិ៍ តួនាទីនីតិកម្ម តំណាង និងតួនាទីតាមដានការអនុវត្តច្បាប់ និងបានរួមចំណែកដ៏ធំធេងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ជាពិសេសជានាការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ រដ្ឋសភាបានចាត់ទុកអំពើពុករលួយជា "**ឧបសគ្គដ៏ធំក្នុងការអភិវឌ្ឍជាតិ**" ដែលតម្រូវឱ្យតួអង្គពាក់ព័ន្ធទាំងអស់ ក្នុងនោះមាន ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ វិស័យឯកជន សង្គមស៊ីវិល សារព័ត៌មាន និងសាធារណជនទូទៅ និងជាពិសេសបុគ្គលម្នាក់ៗ ត្រូវចូលរួមទាំងអស់គ្នាដើម្បី ប្រយុទ្ធប្រឆាំងអំពើពុករលួយនេះ សំដៅកសាងសង្គមកម្ពុជាឱ្យមានការអភិវឌ្ឍរីកចម្រើន ជឿនលឿន ប្រកបដោយភាពស្អាតស្អំ ថ្លៃថ្នូរ និងសុខដុមរមនា។

ឈរលើស្មារតីនេះ រដ្ឋសភាកម្ពុជាបានអនុម័តច្បាប់ស្តីពី "**ការប្រឆាំងអំពើពុករលួយ**" នៅឆ្នាំ ២០១០ និងបានបង្កើត "**គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ**" ដែលបម្រើជាយន្តការដ៏សំខាន់ ក្នុងការជានានូវចីរភាពនៃការអភិវឌ្ឍជាតិ ពង្រឹងជំនឿទុកចិត្តពីសាធារណជនជាតិ និងអន្តរជាតិ លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ។ ចាប់តាំងពីនីតិកាលទី១ រហូតដល់នីតិកាលទី៧ (២០២៣-២០២៨) រដ្ឋសភាចាត់ទុក "**អភិបាលកិច្ចល្អ**" ជាស្នូលនិងគ្រឹះដ៏រឹងមាំសម្រាប់ការដឹកនាំ និងការអភិវឌ្ឍគ្រប់វិស័យ។ រដ្ឋសភាបានចូលរួមយ៉ាងសកម្មនិងប្រកបដោយភាពបុរេសកម្មជាមួយរាជរដ្ឋាភិបាលក្នុងកិច្ចខិតខំប្រឹងប្រែងពហុវិស័យដើម្បីជំរុញការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនៅគ្រប់នីតិកាល ជាពិសេសរាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ចក្ខុវិស័យវែងឆ្ងាយ និងថាមពលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ដែលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យឆ្នាំ២០៣០ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋសភាតែងបានធ្វើអន្តរកម្ម ច្រាស្រ័យទាក់ទង និងពិគ្រោះយោបល់ជាមួយស្ថាប័នសាធារណៈទទួលបន្ទុកតាមវិស័យ ក្នុងនោះស្ថាប័នប្រឆាំងអំពើពុករលួយក្នុងក្របខណ្ឌជាតិ ដើម្បីបង្កើតបាននូវការយល់ដឹង ការផ្ទាស់ប្តូរទស្សនៈប្រកបដោយភាពវិជ្ជមានលើយន្តការត្រួតពិនិត្យនៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (UNCAC) ទាំង២ជុំ (២០១៥-២០២៥) ការពិគ្រោះយោបល់ជាមួយអង្គភាពប្រឆាំងអំពើពុករលួយលើការងារអប់រំ ទប់ស្កាត់ និងអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងបានចូលរួមផ្តល់ជាតុចូលលើគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយជាទៀងទាត់។ ក្នុងក្របខណ្ឌអន្តរជាតិ រដ្ឋសភាក៏បានចូលរួមយ៉ាងសកម្មក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិ និងបាននាំយកនូវបទពិសោធន៍ល្អៗរបស់កម្ពុជាចែករំលែកដល់ពិភពលោក និងនាំយកមកនូវទស្សនៈវិជ្ជមាន និងការអនុវត្តប្រសើរជាច្រើនមកសិក្សារៀនសូត្រនិងអនុវត្តក្នុងប្រទេស។ សកម្មភាពទាំងនេះ ធ្វើបញ្ជាំងឱ្យឃើញពីអត្ថប្រយោជន៍នៃកិច្ចសហការ និងការរួមគ្នាដើម្បីសម្រេចគោលដៅ និងក្តីប្រាថ្នារួមរបស់ជាតិ គឺការកសាងសង្គមកម្ពុជាមួយដែលមានភាពស្អាតស្អំ ថ្លៃថ្នូរ និងចៀសផុតពីអំពើពុករលួយ។

ខ្ញុំសូមបន្តលើកទឹកចិត្តដល់ស្ថាប័នទាំងពីរ ទាំងរដ្ឋសភា ទាំងស្ថាប័នប្រឆាំងអំពើពុករលួយដែលមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ បន្តកិច្ចប្រឹងប្រែងរួមគ្នា ដើម្បីផ្តល់ការគាំទ្រជាសារវន្តដល់ការអនុវត្តកម្មវិធីនិងគោលនយោបាយរាជរដ្ឋាភិបាលអាណត្តិទី៧ ឱ្យទទួលបានជោគជ័យត្រចះត្រចង់ថែមទៀត។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ជាមួយនឹងការកំណត់គោលដៅជាយុទ្ធសាស្ត្រច្បាស់លាស់ ការរួមកម្លាំងសាមគ្គីគ្នាដើម្បីប្រយោជន៍ជាតិ ប្រយោជន៍ប្រជាជនដែលជាម្ចាស់ឆ្នោត ម្ចាស់ប្រទេស និងការចូលរួមពីគ្រប់តួអង្គទាំងអស់ក្នុងសង្គមព្រះរាជាណាចក្រកម្ពុជានឹងសម្រេចបានចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ ជាមិនខាន ។

តាងនាមឱ្យរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមគាំទ្រទាំងស្រុង និងវាយតម្លៃខ្ពស់ចំពោះខ្លឹមសារនៃយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយដំណាក់កាលទី៤ (២០២៥-២០៣០) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយលើទិដ្ឋភាព **«ការបង្ការ ការទប់ស្កាត់ ការអប់រំ និងការបង្ក្រាប»** ដែលនឹងក្លាយជាត្រីវិស័យ និងឧបករណ៍ដ៏មានឥទ្ធិពលក្នុងការលើកកម្ពស់តម្លាភាព គណនេយ្យភាព និងយុត្តិធម៌សង្គម។ រដ្ឋសភាកម្ពុជាប្តេជ្ញាបន្តផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលនិងស្ថាប័នប្រឆាំងអំពើពុករលួយ ទាំងក្របខណ្ឌច្បាប់ និងក្របខណ្ឌបទដ្ឋានគតិយុត្តចាំបាច់នានា ដើម្បីសម្រេចគោលដៅរួមរបស់ជាតិ និងប្រជាជន។ ជាមួយគ្នានេះ ខ្ញុំក៏សូមអំពាវនាវឱ្យមានការគាំទ្រនិងចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ទាំងសមាជិក សមាជិការដ្ឋសភា ព្រឹទ្ធសភា មន្ត្រីតុលាការ មន្ត្រីរាជការ ធុរជន និង សង្គមស៊ីវិល និងបុគ្គលម្នាក់ៗ ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយឱ្យបានជោគជ័យ។

ខ្ញុំសូមជូនពរដល់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ក្នុងអង្គភាពប្រឆាំងអំពើពុករលួយ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមទទួលបាននូវជោគជ័យថ្មីៗបន្ថែមទៀត ក្នុងបុព្វហេតុកសាង និងអភិវឌ្ឍជាតិមាតុភូមិ៕

ថ្ងៃ៨រុ ១៣ ១៦ ខែ៨ឆ្នូ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២៦

ឃួន សុជារី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សារលិខិត

ក្នុងឱកាសដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤ (២០២៥-២០៣០)

រាជរដ្ឋាភិបាលកន្លងមកក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** បានបូជាជីវិតប្តូរនឹងសន្តិភាព និងការបង្រួបបង្រួមជាតិ និងលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី កសាងអភិវឌ្ឍប្រទេសលើគ្រប់វិស័យ។ សមិទ្ធផលដែលបានបន្សល់ទុកដល់រាជរដ្ឋាភិបាល អាណត្តិទី៧ ក្រោមការដឹកនាំរបស់រូបខ្ញុំ ទាំងការគាំទ្រ និងការជឿជាក់ដ៏មហាសាលពីសំណាក់ពលរដ្ឋម្ចាស់ឆ្នោត ម្ចាស់ប្រទេស ការថែទាំពូនជ្រុំថ្នាលបន្តផែន និងបទពិសោធន៍ ចំណេះដឹង ចំណេះវិជ្ជា ចំណេះដឹកនាំ ចំណេះអនុវត្ត ដែលបានឆ្លងកាត់ និងជាពិសេសការបន្តគាំទ្រដោយឥតលក្ខខណ្ឌ បានកំពុងដើរតួនាទីជាប្រទីបបង្ហាញផ្លូវ និងជាមគ្គុទ្ទេសក៍តម្រង់ទិសឆ្ពោះទៅកាន់ការអភិវឌ្ឍ និងរីកចម្រើនបន្ថែមទៀតជូនសង្គមជាតិយើង។ មហិច្ឆតាដែលបានដាក់ចេញនៃចក្ខុវិស័យនាំកម្ពុជាទៅជាប្រទេសមានកម្រិតចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ នឹងបន្តជំរុញសន្ទុះ កំណែទម្រង់គ្រប់វិស័យ និងការអនុវត្តតាមកម្មវិធីគោលនយោបាយ ដែលបានដាក់ចេញដោយភាពច្នៃប្រឌិត ទន់ភ្លន់ និងបត់បែន ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ (២០២៣-២០២៨) ដើម្បីដឹកនាំការងាររាជរដ្ឋាភិបាលអមដោយអភិក្រមទាំង៥ **"ឆ្លុះកញ្ចាក់ ងូតទឹក ដុសក្តែល ព្យាបាល វះកាត់"** និងអភិក្រម **"ជវរភាពនៃប្រព័ន្ធតួអង្គតែមួយ"** ដែលបម្រើដល់ការអភិវឌ្ឍស្ថាប័ន ការពង្រឹងអភិបាលកិច្ចល្អ និងការពង្រីកប្រសិទ្ធភាពការងារក្នុងវិស័យសាធារណៈ។ ការជំរុញរដ្ឋបាលស្អាតស្អំ ដែលជាអាទិភាពមួយត្រូវបានកំណត់ឡើងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ (២០២៣-២០២៨) នឹងតម្រូវឱ្យមាននូវការកែទម្រង់ស្ថាប័នពីខាងក្នុងឱ្យបានកាន់តែស៊ីជម្រៅ ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យ និងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាល។ កំណែទម្រង់នេះ ព្រមជាមួយនឹងកំណែទម្រង់ជាច្រើនទៀត ដូចជាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ ច្បាប់ និងយុត្តិធម៌ វិមជ្ឈការ និងវិសហមជ្ឈការជាដើម ដែលកំពុងត្រូវបានជំរុញយ៉ាងសកម្ម បានចូលរួមគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលជាបញ្ហាឆ្លង និងពហុវិស័យ ឱ្យកាន់តែមានគុណភាព និងផ្លែផ្កា។

ខ្ញុំសូមបន្តជំរុញការចូលរួមលើការងារប្រឆាំងអំពើពុករលួយជាមួយនឹងស្ថាប័នប្រឆាំងអំពើពុករលួយពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមានពីស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ ស្ថាប័នសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ផ្នែកសិក្សាធិការ ផ្នែកសារព័ត៌មាន និងមហាជនទូទៅ។ ខ្ញុំមានជំនឿថា ការចូលរួមពីគ្រប់មជ្ឈដ្ឋាន នឹងផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល និងស្ថាប័នប្រឆាំងអំពើពុករលួយនាំមកនូវសមិទ្ធផលគួរជាទីមោទនៈថ្មីៗបន្ថែមទៀត ហើយក៏នឹងជួយឱ្យយើងឈានឆ្ពោះកាន់តែជិតដល់គោលដៅរួមរបស់យើង គឺការពង្រីកប្រសិទ្ធភាពការដឹកនាំគ្រប់គ្រង ការបង្រួមហានិភ័យ និងបញ្ហាប្រឈម សំដៅកាត់បន្ថយ និងឈានទៅលុបបំបាត់អំពើពុករលួយ ដែលជាសត្រូវនៃការអភិវឌ្ឍ និងកិច្ចខិតខំលុបបំបាត់ភាពក្រីក្រ។ ការចូលរួមពីសំណាក់តួអង្គនានា ជាពិសេសពីសំណាក់ក្រសួង ស្ថាប័ន ទាំងផ្នែកអប់រំ ស្មារតី ផ្តត់គំនិតប្រកាន់ខ្ជាប់សីលធម៌ល្អ និងសុចរិតភាពទាំងការបង្ការទប់ស្កាត់ ឬបិទឱកាស និងច្រកនៃអំពើពុករលួយ និងការផ្តល់កិច្ចសហការដល់ស្ថាប័នប្រឆាំងអំពើពុករលួយក្នុងការអនុវត្តច្បាប់បង្ក្រាប នៅតែជាអាទិភាពចាំបាច់បំផុត។

ខ្ញុំសូមផ្តល់នូវការគាំទ្រដោយឥតងាករេជាថ្មីរបស់ខ្ញុំ ក៏ដូចជារបស់រាជរដ្ឋាភិបាល ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយទាំងអស់ក្នុងការបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួន ស្របតាមយុទ្ធសាស្ត្រ និងនយោបាយដែលក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយបានដាក់ចេញសម្រាប់ ៥ ឆ្នាំ (២០២៥-២០៣០) ខាងមុខទៀត។

ខ្ញុំសូមជូនពរដល់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយទាំង ១១ រូប ប្រធាន អនុប្រធាន ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ក្នុងអង្គភាពប្រឆាំងអំពើពុករលួយ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ហើយសូមទទួលបាននូវជោគជ័យថ្មីៗបន្ថែមទៀតសម្រាប់អាណត្តិទី៤ (២០២៥-២០៣០)៕

ថ្ងៃ សុក្រ ១១កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៦

ហ៊ុន ម៉ាណែត

កថាមុខ

ក្រោមម្លប់សន្តិភាព និងការដឹកនាំប្រទេសជាច្រើនទសវត្សរ៍របស់មហាបុរសកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាទទួលបាននូវការរីកចម្រើន និងអភិវឌ្ឍគ្រប់វិស័យ។ សមិទ្ធផលគួរជាទីមោទនៈជាច្រើនដែលសម្រេចបានជូនសង្គមជាតិ ឆ្ពុះបញ្ចាំងពីសមត្ថភាព និងគុណភាពនៃការដឹកនាំ ដែលរឹងមាំ ឈ្លាសវៃ និងប៉ិនប្រសប់ ជម្នះរាល់ឧបសគ្គ ចាប់យករាល់កាលានុវត្តភាព រីឡើងខ្ពស់ជាប្រចាំ តែទម្រង់មិនចេះនឿយហត់ សម្រប និងបត់បែនតាមកាលៈទេសៈតម្រូវ ទាំងក្នុងបរិបទជាតិ និងអន្តរជាតិ សំដៅផ្តោះទៅគោលដៅរួមដែលទាំងរដ្ឋ ទាំងប្រជាពលរដ្ឋប៉ងប្រាថ្នាដូចគ្នា គឺការរស់នៅក្នុងសន្តិភាព សុខដុមភាព និងវឌ្ឍនភាពប្រកបដោយចីរភាពយូរអង្វែង។ កម្មវិធីគោលនយោបាយរដ្ឋ ដែលបានដាក់ចេញជាបន្តបន្ទាប់ ទាំងយុទ្ធសាស្ត្រត្រីកោណ - យុទ្ធសាស្ត្រចតុកោណ ត្រូវបានបន្ត និងសម្រួចឱ្យកាន់តែមុតស្រួច ដោយរាជរដ្ឋាភិបាលបន្តវេន អាណត្តិទី៧ ក្រោមការដឹកនាំដ៏ក្លៀវក្លា និងឋាមពល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** សបញ្ជាក់ពីនិរន្តរភាពនៃមាគ៌ាដឹកនាំគោលនយោបាយអភិវឌ្ឍប្រទេសដ៏ត្រឹមត្រូវ កំពុងអនុវត្តបន្តជាមួយនឹងធន្ទះ និងការប្តេជ្ញាដ៏មោះមុត និងច្បាស់លាស់ លើការដ្ឋានចម្រុះ រួមទាំងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលតែងតែបន្តជាការងារអាទិភាពស្នូលមួយរបស់រដ្ឋ។ ព្រមជាមួយនឹងកម្មវិធីគោលនយោបាយអំណោយផលទាំងនេះ ការអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយ ការដាក់ចេញជាចំណាត់ការ ជាសារ ជាកំណែទម្រង់ ជាការជំរុញលើកទឹកចិត្តអនុវត្ត និងចូលរួមសហប្រតិបត្តិការពីសំណាក់គ្រប់ភាគីពាក់ព័ន្ធ និងការគាំទ្រឥតងាករេរបស់ប្រមុខរាជរដ្ឋាភិបាលចំពោះកិច្ចប្រឹងប្រែងក្នុងការបំពេញតួនាទី ភារកិច្ចជាប្រវត្តិសាស្ត្ររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ សុទ្ធតែបានជំរុញ និងផ្តល់ជាកម្លាំងចិត្តយ៉ាងខ្លាំងក្លា ដល់ថ្នាក់ដឹកនាំ និងមន្ត្រី អ.ប.ព. ក្នុងការពុះពារឧបសគ្គ ប្រឹងប្រែងជម្នះ និងលះបង់កម្លាំងកាយចិត្តដើម្បីបំពេញតួនាទី ភារកិច្ចប្រកបដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈ សំដៅនាំមកជូនរាជរដ្ឋាភិបាល និងសង្គមជាតិនូវសមិទ្ធផលលើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ដូចអាណត្តិមុនៗដែរ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើពុករលួយ (២០២៥-២០៣០) ដែលត្រូវបានបន្សុី និងសម្របតាមកម្មវិធីគោលនយោបាយរដ្ឋ ដើម្បី អ.ប.ព. ប្រើប្រាស់ជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តតួនាទី ភារកិច្ច និងដាក់ចេញនូវចំណាត់ការ និងសកម្មភាពការងារនានាដែលចូលរួមគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលជារួមផង គាំទ្រដល់ការងារកំណែទម្រង់នានាដោយស្ថាប័នសាធារណៈពាក់ព័ន្ធ គាំទ្រដល់វិស័យឯកជន និងសាធារណជនទូទៅ គាំទ្រដល់ការបំពេញកាតព្វកិច្ចដែលកម្ពុជាមានចំពោះសហគមន៍អន្តរជាតិក្នុងវេទិកាអន្តរដ្ឋាភិបាលនានា ដូចជាវេទិកា UNCAC-APG ជាដើម។ សកម្មភាពដែលបានរំលេចឡើងក្នុងផែនការយុទ្ធសាស្ត្រ៥ឆ្នាំទៅមុខបន្ត នឹងរួមមាននូវការងារខ្លះដែលបន្តពីផែនការមុន ខ្លះមិនទាន់បានអនុវត្ត ខ្លះត្រូវបានកែសម្រួល និង

ខ្លះត្រូវបានកំណត់ថ្មីស្របតាមបរិបទជាក់ស្តែង និងការវិវឌ្ឍផ្ទាស់ប្តូរថ្មីៗ បទពិសោធន៍នៃការអនុវត្តការងារកន្លងមក ក៏ដូចជាធាតុចូលទាំងដោយផ្ទាល់ ដោយប្រយោលដែលទទួលបានពីភាគីពាក់ព័ន្ធនានា ដូចជាស្ថាប័នសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ផ្នែកសិក្សាធិការ ផ្នែកសារព័ត៌មានជាដើម ក៏បានចូលរួមចំណែកដល់ការរៀបចំ ដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៤ នេះផងដែរ។

ជារួម ការងារ៥ឆ្នាំទៅមុខនឹងបន្តផ្តោតលើការដ្ឋានយុទ្ធសាស្ត្រ៦គឺ (១). អប់រំ (២). បង្ការទប់ស្កាត់ (៣). អនុវត្តច្បាប់ (៤). គោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិ (៥). កិច្ចសហការជាតិ អន្តរជាតិ និងការរឹបអូសផលនៃបទល្មើស (៦). ពង្រឹងសមត្ថភាព អភិបាលកិច្ចផ្ទៃក្នុង និងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ជាមួយនឹងការពង្រឹងការអនុវត្តរបបរាយការណ៍ និងការផ្សព្វផ្សាយអំពីសមិទ្ធផលការអនុវត្តផែនការយុទ្ធសាស្ត្រជាតិឱ្យបានទូលំទូលាយ។ សកម្មភាពយុទ្ធសាស្ត្រគន្លឹះៗជាច្រើនត្រូវបានដាក់ចេញសំដៅពង្រឹងប្រសិទ្ធភាពការងារ ពង្រីកវិសាលភាពនៃការអនុវត្ត គាំទ្រដល់កិច្ចប្រឹងប្រែងកំណែទម្រង់រដ្ឋឱ្យបានកាន់តែមានផ្ទៃផ្ទា បង្កើនកិច្ចសហប្រតិបត្តិការ និងការផ្តុំកម្លាំងដើម្បីប្រយោជន៍សាធារណៈ និងគោលដៅរួម និងឆ្លើយតបទៅនឹងកាតព្វកិច្ចដែលកម្ពុជាមាន និងចូលរួមជារដ្ឋសមាជិកប្រកបដោយសក្តានុពល និងការទទួលខុសត្រូវចំពោះសហគមន៍អន្តរជាតិ។

យើងខ្ញុំ ក្នុងនាមស្ថាប័នប្រឆាំងអំពើពុករលួយ បេក្ខជនប្រឹងប្រែងបំពេញបេសកកម្មកសាងសង្គមស្អាតស្អំ ដោយខិតខំពង្រឹងសមត្ថភាព ជំនាញវិជ្ជាជីវៈរបស់ខ្លួន និងជាពិសេសជម្នះរាល់ភាពរាំងស្ទះ និងបញ្ហាប្រឈមនានា ដែលអាចនឹងកើតឡើងនាពេលខាងមុខ។ ក្នុងន័យនេះ យើងខ្ញុំសូមបន្តអំពាវនាវដល់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់នៃស្ថាប័នប្រឆាំងអំពើពុករលួយ សូមបន្តបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយធន្ទៈ មនសិការខ្ពស់ ក្រោមស្មារតីជាគំរូ និងគិតប្រយោជន៍ជាតិជាធំ ស្របតាមគុណតម្លៃសុចរិតភាព គុណធម៌ គណនេយ្យភាព តម្លាភាព និងកក្តីភាពចំពោះច្បាប់ សំដៅចូលរួមកសាង និងអភិវឌ្ឍជាតិ ដើម្បីបន្តសុខសន្តិភាព និងសម្រេចបានវិបុលភាព សុខដុមរមនានៃសង្គមកម្ពុជា ក្រោមម្លប់តែមួយនៃ **ជាតិ សាសនា ព្រះមហាក្សត្រ** នៃយើង។ យើងខ្ញុំសូមជូនពរថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃស្ថាប័នប្រឆាំងអំពើពុករលួយទទួលបាននូវពុទ្ធពរទាំង ៤ប្រការ និងជោគជ័យគ្រប់ភារកិច្ច៕

ថ្ងៃចន្ទ ៧កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៦

ឧបនាយករដ្ឋមន្ត្រី	
ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ	៨.ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
	ប្រធាន
កិត្តិនីតិកោសលបណ្ឌិត ឌិម យ៉ិនជៀន	សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ១ - ២០១១-២០១៨

ឯកឧត្តម តុប សំ

ជ្រើសតាំងដោយ រដ្ឋសភា

ឯកឧត្តម ច្រាក់ សុខ

ជ្រើសតាំងដោយ ព្រឹទ្ធសភា

ឯកឧត្តម កុយ សុផល

តែងតាំងដោយ ព្រះមហាក្សត្រ

ឯកឧត្តម ច័ន្ទ តានី

ជ្រើសតាំងពី រាជរដ្ឋាភិបាល

ឯកឧត្តម អ៊ុត ឈន

ជ្រើសតាំងពី អាជ្ញាធរសវនកម្មជាតិ

លោកជំទាវ សោម គីមស្វក់

ជ្រើសតាំងពី ក្រសួងទំនាក់ទំនង
រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ឯកឧត្តម ហេង វង្ស ប៊ុនធាត

ជ្រើសតាំងពី ក្រុមប្រឹក្សាអ្នកច្បាប់

ឯកឧត្តម ស៊ុយ ម៉ុងលាង

ជ្រើសតាំងពី ក្រុមប្រឹក្សាកំណែ
ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឯកឧត្តម ជីវ កេង

ជ្រើសតាំងពី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឯកឧត្តម កែវ រ៉ែមី

ជ្រើសតាំងពី គណៈកម្មាធិការ
សិទ្ធិមនុស្សកម្ពុជា

ឯកឧត្តម ឌិម យ៉ិនឌៀង

ទេសរដ្ឋមន្ត្រី
ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - ពាក់កណ្តាលអាណត្តិទី ១ - ២០១១-២០១៥

ឯកឧត្តម តុប សំ

ជ្រើសតាំងដោយ រដ្ឋសភា

ឯកឧត្តម ស៊ុយ ម៉ុងលាង

ជ្រើសតាំងពី ក្រុមប្រឹក្សាកំណែ
ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឯកឧត្តម តុយ សុផល

តែងតាំងដោយ ព្រះមហាក្សត្រ

ឯកឧត្តម លី ណារុន

ជ្រើសតាំងដោយ ព្រឹទ្ធសភា

ឯកឧត្តម ច័ន្ទ តានី

ជ្រើសតាំងពី រាជរដ្ឋាភិបាល

លោកជំទាវ សោម គឹមស្វក់

ជ្រើសតាំងពី អាជ្ញាធរសវនកម្មជាតិ

ឯកឧត្តម ឆេង សារឿន

ជ្រើសតាំងពី ក្រសួងទំនាក់ទំនង
រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ឯកឧត្តម ហោជវង្ស ប៊ុនធាត

ជ្រើសតាំងពី ក្រុមប្រឹក្សាអ្នកច្បាប់

ឯកឧត្តម ជីវ កេង

ជ្រើសតាំងពី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឯកឧត្តម កែវ ម៉ែមី

ជ្រើសតាំងពី គណៈកម្មាធិការ
សិទ្ធិមនុស្សកម្ពុជា

ឯកឧត្តម ឯម យ៉ិនឌៀង

ទេសរដ្ឋមន្ត្រី
ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ២ - ២០១៥-២០២០

ឯកឧត្តម តុប សំ

ជ្រើសតាំងដោយ រដ្ឋសភា

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន

ជ្រើសតាំងពី ក្រសួងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ឯកឧត្តម កុយ សុផល

តែងតាំងដោយ ព្រះមហាក្សត្រ

ឯកឧត្តម លី ណារុន

ជ្រើសតាំងដោយ ព្រឹទ្ធសភា

ឯកឧត្តម អង្គ វង្ស វឌ្ឍានា

ជ្រើសតាំងពី រាជរដ្ឋាភិបាល

លោកជំទាវ សោម គីមស្វក់

ជ្រើសតាំងពី អាជ្ញាធរសវនកម្មជាតិ

ឯកឧត្តម ហេង វង្ស ប៊ុនធាត

ជ្រើសតាំងពី ក្រុមប្រឹក្សាអ្នកច្បាប់

ឯកឧត្តម ស៊ុយ ម៉ុងសាង

ជ្រើសតាំងពី ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឯកឧត្តម យ៉ែត ចរិយា

ជ្រើសតាំងពី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឯកឧត្តម កែវ រ៉ែមី

ជ្រើសតាំងពី គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

ឯកឧត្តម ឌិម យ៉ិនឌៀង

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ៣ - ២០២០-២០២៤

ឯកឧត្តម តុប សំ

ជ្រើសតាំងដោយ រដ្ឋសភា

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន

ជ្រើសតាំងពី ក្រសួងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ឯកឧត្តម កុយ សុផល

តែងតាំងដោយ ព្រះមហាក្សត្រ

ឯកឧត្តម លី ណារុន

ជ្រើសតាំងដោយ ព្រឹទ្ធសភា

ឯកឧត្តម កើត រិទ្ធ

ជ្រើសតាំងពី រាជរដ្ឋាភិបាល

លោកជំទាវ សោម គីមស្វក់

ជ្រើសតាំងពី អាជ្ញាធរសវនកម្មជាតិ

ឯកឧត្តម ហេង វង្ស ប៊ុនធាត

ជ្រើសតាំងពី ក្រុមប្រឹក្សាអ្នកច្បាប់

ឯកឧត្តម ស៊ុយ ម៉ុងលាង

ជ្រើសតាំងពី ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឯកឧត្តម តាំង ស៊ុនឌ្បាយ

ជ្រើសតាំងពី ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

ឯកឧត្តម កែវ ម៉ែម

ជ្រើសតាំងពី គណៈកម្មាធិការ សិទ្ធិមនុស្សកម្ពុជា

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជិម យ៉ិនឌៀង

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ៤ - ២០២៥-២០៣០

សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន
ជ្រើសតាំងដោយ ក្រសួងអធិការកិច្ច

ឯកឧត្តម តុប សំ
ជ្រើសតាំងដោយ រដ្ឋសភា

សម្តេចមហាមន្ត្រី កុយ សុផល
តែងតាំងដោយ ព្រះមហាក្សត្រ

ឯកឧត្តម ឌ្បាយ សំកុល
ជ្រើសតាំងដោយ ព្រឹទ្ធសភា

ឯកឧត្តម កើត រិទ្ធ
ជ្រើសតាំងពី រាជរដ្ឋាភិបាល

លោកជំទាវ សោម គីមស្វក់
ជ្រើសតាំងពី អាជ្ញាធរសវនកម្មជាតិ

ឯកឧត្តម ហេង វង្ស ប៊ុនឆាត
ជ្រើសតាំងពី ក្រុមប្រឹក្សាអ្នកឆ្បាប់

ឯកឧត្តម ជីវ កេង
ជ្រើសតាំងពី គណៈកម្មាធិការ
ដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

ឯកឧត្តម តាំង ស៊ុនឌ្បាយ
ជ្រើសតាំងដោយ
ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឯកឧត្តម កែវ ប៉ែមី
ជ្រើសតាំងពី គណៈកម្មាធិការ
សិទ្ធិមនុស្សកម្ពុជា

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត
ង៉ិម យ៉ិនឌៀង
ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

មាតិកា

កថាមុខ i
សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ១ - ២០១១-២០១៥ iii
សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - ពាក់កណ្តាលអាណត្តិទី ១ - ២០១១-២០១៥ iv
សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ២ - ២០១៥-២០២០ v
សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ៣ - ២០២០-២០២៥ vi
សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ - អាណត្តិទី ៤ - ២០២៥-២០៣០ vii
១. សេចក្តីផ្តើម 1
១.១. សាវតា 1
១.២. វិចារណកម្មនៃផែនការយុទ្ធសាស្ត្រជាតិ (២០២៥-២០៣០) 3
១.២.១. ឧបការណ៍គោលនយោបាយជាតិ 3
១.២.២. ឧបការណ៍គោលនយោបាយ តំបន់ និងអន្តរជាតិ 5
១.២.៣. បទពិសោធន៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៣ ដំណាក់កាលកន្លងមក 7
១.៣. ប្រៀបធៀបផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៤ (២០២៥-២០៣០) និងផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៣ (២០២០-២០២៥) 7
១.៤. ការរៀបចំផែនការយុទ្ធសាស្ត្រជាតិដំណាក់កាលទី៤ (២០២៥-២០៣០) 8
២. ការត្រួតពិនិត្យឡើងវិញលទ្ធការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៣ (២០២០-២០២៥) 9
២.១. សារចាន 9
២.២. សមិទ្ធផលសំខាន់ៗ 9
២.២.១. ការងារអប់រំ 9
២.២.២. ការងារបង្ការទប់ស្កាត់ 15
២.៣. ការងារអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ និងកិច្ចសហប្រតិបត្តិការជាតិ - អន្តរជាតិ 27
២.៣.១. ការងារអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ 27
២.៣.២. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ 34
២.៤. អភិចាលកិច្ចផ្ទៃក្នុង (ក.វ.ត.ផ.) 39
២.៥. ត្រួតពិនិត្យ និងវាយតម្លៃ និងការងារមិនចានអនុវត្ត 41
២.៥.១. ការងារត្រួតពិនិត្យ និងវាយតម្លៃ 41
២.៥.២. ការងារមិនជាន់ចានអនុវត្ត 43
២.៦. កត្តាជោគជ័យ-បញ្ហាប្រឈម-មេរៀនទទួលចាន 43
២.៦.១. កត្តាជោគជ័យ 43

๒.๖.๒. បញ្ហាប្រឈម 45
๒.๖.๓. មេរៀនឧទ្ធរណ៍ 46
๓. ការវិភាគអំពីបរិយាកាសជុំវិញ 48
๓.๑. ការវិភាគបរិយាកាសនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ បរិស្ថាន (PESTLE) 48
๓.๑.๑. បរិយាកាសនយោបាយ 48
๓.๑.๒. បរិយាកាសសេដ្ឋកិច្ច 49
๓.๑.๓. បរិយាកាសសង្គម 50
๓.๑.๔. បរិយាកាសបច្ចេកវិទ្យា 51
๓.๑.๕. បរិយាកាសច្បាប់ 52
๓.๑.๖. បរិយាកាសបរិស្ថាន 52
๓.๒. ការវិភាគចំណុចខ្លាំង-ចំណុចខ្សោយ-ឱកាស- ការគំរាមកំហែង (SWOT) 53
๓.๒.๑. ចំណុចខ្លាំង 53
๓.๒.๒. ចំណុចខ្សោយ 53
๓.๒.๓. ឱកាស 54
๓.๒.๔. ការគំរាមកំហែង 54
๔. ទិសដៅយុទ្ធសាស្ត្រ (๒๐๒๕-๒๐๓๐) 55
๔.๑. ចក្ខុវិស័យ 55
๔.๒. បេសកកម្ម 55
๔.๓. គោលនយោបាយ 55
๔.๔. តុណាតម្លៃ 55
๔.๕. គោលដៅ 55
๔.๖. ការជ្រើរអាទិភាពដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងភាគីពាក់ព័ន្ធ 55
๕. យុទ្ធសាស្ត្រ សកម្មភាពគោល សកម្មភាព និងសូចនាករ នៃការអនុវត្តការជ្រើរ 58
๖. ផែនការយុទ្ធសាស្ត្រ និងថវិកា 87
๗. ការត្រួតពិនិត្យ និងវាយតម្លៃ 87
๘. ការរាយការណ៍ និងផ្សព្វផ្សាយ 87
๙. ការកែសម្រួល 88
๑๐.សេចក្តីសន្និដ្ឋាន 88
๑๑.កម្រងរូបភាព 90

១. សេចក្តីផ្តើម

១.១. សាវតា

សន្តិភាពនាំមកនូវភាពរីកចម្រើន និងការអភិវឌ្ឍ។ កេរ្តិ៍ដំណែលសន្តិភាពដែលរកបានដោយការលះបង់ទាំងជីវិត កម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញាដ៏ឈ្លាសវៃរបស់មហាបុរសកម្ពុជា ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធាន ព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តម ប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា*** *បានផ្តល់ដល់រដ្ឋអំណាចបន្តវេន នូវថ្នាល ដ៏សុខដុមសម្រាប់ផ្ចិតផ្ចង់ការយកចិត្តទុកដាក់លើការបន្តបង្រួបបង្រួម កសាង និងដឹកនាំប្រទេសដើម្បីការរីកចម្រើន និងអភិវឌ្ឍបន្ថែម ក៏ដូចជាដល់ប្រជាជនកម្ពុជា នូវការរស់រាន ទទួលទាន ប្រកបដោយស្នាមញញឹម ក្តីសង្ឃឹម និងមោទន:ភាពចំពោះជាតិមាតុភូមិ។ កេរ្តិ៍ដំណែលក៏រួមមាននូវរដ្ឋអំណាចដឹកនាំមួយដែលរឹងមាំ មានគុណធម៌ មានការគិត ការគូរ មានមាយាទ មានយុទ្ធសាស្ត្រ មានគោលនយោបាយ មានធន្ទ:ជំរុញអភិបាលកិច្ចល្អ កសាង និងអភិវឌ្ឍដែលអំណោយផលដល់ការបន្តវេនដោយចីរភាពយូរអង្វែង។ យុទ្ធសាស្ត្រ គោលនយោបាយ និងធន្ទ:ទាំងនេះ ត្រូវបានស្តែងឡើងក្នុងសមិទ្ធផលរដ្ឋគួរជាទីមោទន:ជាច្រើន ពីមួយអាណត្តិទៅមួយអាណត្តិ នៃការដឹកនាំប្រទេស។ ភាពរឹងមាំត្រូវបានស្តែងឱ្យឃើញកាន់តែច្បាស់ក្នុងពេលប្រទេសជួបវិបត្តិ ដូចជា កូវីដ-១៩ ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលដែលបានជះឥទ្ធិពលអវិជ្ជមានដល់កម្ពុជាខ្លាំងក្លាក៏ដោយ ក៏រដ្ឋអំណាចកម្ពុជានៅតែអាចដោះស្រាយ និងជម្នះបានប្រកបដោយទំនុកចិត្ត និងភាពជឿជាក់។*

លើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ ***សម្តេចតេជោ*** *បានអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០ ហើយតាមរយៈច្បាប់នេះបានបង្កើតនូវស្ថាប័នប្រឆាំងអំពើពុករលួយ ដែលមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយជាអង្គត្រួតពិនិត្យ និងផ្តល់អនុសាសន៍តម្រៃតម្រង់ទិសការងារ និងអង្គភាពប្រឆាំងអំពើពុករលួយជាអង្គប្រតិបត្តិអនុវត្តច្បាប់ផ្ទាល់។ យុទ្ធសាស្ត្រ និងគោលនយោបាយដឹកនាំប្រទេសដូចជាយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាច្រើនដំណាក់កាល ក៏ត្រូវបានដាក់ចេញ និងអនុវត្ត ដោយក្នុងនោះ ការងារអភិបាលកិច្ចល្អ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយត្រូវបានចាត់ទុកជាស្នូល និងអាទិភាពគន្ទឹះមួយរបស់រដ្ឋដើម្បីជានានូវប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រង។ បន្ថែមពីនេះចំណាត់ការជាក់ស្តែង សារផ្ទាល់ៗ ក៏ដូចជាអភិក្រមបង្ហាញផ្លូវគន្ទឹះសាមញ្ញ តែប្រកបដោយអត្ថន័យជ្រាលជ្រៅក្នុងការតម្រែតម្រង់លើកទឹកចិត្ត ជំរុញ និងដោះស្រាយពោលគឺអភិក្រមទាំង៥ "**ទុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" ត្រូវបានជ្រួតជ្រាប និងចូលរួមប្រតិបត្តិដោយមន្ត្រីរដ្ឋ កាន់តែទូលំទូលាយ។ គោលនយោបាយ អភិក្រមដឹកនាំ និងចំណាត់ការទាំងនេះត្រូវបានបន្តជំរុញដោយរាជរដ្ឋាភិបាលអាណត្តិទី៧ ដែលជាទំពាំងស្នងឫស្សី ក្រោមការដឹកនាំដ៏ក្លៀវក្លា និងថាមពលរបស់* ***សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី*** *ដោយក្នុងនោះអាទិភាព និង*

សកម្មភាពគន្លឹះៗចាំបាច់មួយចំនួនដូចជា កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ យុត្តិធម៌ និងតុលាការ វិមជ្ឈការ និងវិសហមជ្ឈការជាដើម ត្រូវបានសម្រួចឱ្យកាន់តែមានប្រសិទ្ធភាព សំដៅជំរុញកម្ពុជាឱ្យឈានទៅដល់គោលដៅជាប្រទេសអភិវឌ្ឍ ដែលមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងចំណូលកម្រិតខ្ពស់ឆ្នាំ២០៥០។

ស្ថាប័នប្រឆាំងអំពើពុករលួយដែលជាស្ថាប័នឯករាជ្យ ដើរតួជាសេនាធិការជូនរាជរដ្ឋាភិបាលលើការងារដឹកនាំប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលបានដាក់ចេញ និងអនុវត្តន៍នូវយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ៣ ដំណាក់កាលរួចមកហើយ (២០១១-២០២៥) ដោយតែងតែបន្សុី និងសម្របយុទ្ធសាស្ត្រ និងការងាររបស់ខ្លួនឱ្យស្របតាមគោលនយោបាយ និងអនុសាសន៍ដឹកនាំរបស់រាជរដ្ឋាភិបាល ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលឆ្លើយតបទៅនឹងក្តីប្រាថ្នារបស់រដ្ឋ។ សមិទ្ធផលជាច្រើនដែលសម្រេចបានលើការងារអភិបាលកិច្ចល្អ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ បានមកពីកិច្ចប្រឹងប្រែងកំណែទម្រង់រដ្ឋ មិនចេះនឿយហត់របស់រាជរដ្ឋាភិបាលទាំងអាណត្តិមុនៗ និងបច្ចុប្បន្ន ពីការចង្អុលបង្ហាញរបស់ប្រមុខរាជរដ្ឋាភិបាល ពីការដាក់ចេញនូវយុទ្ធសាស្ត្រ ការផ្តល់យោបល់ និងតម្រង់ទិសពីសំណាក់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ពីការប្តេជ្ញា និងបំពេញតួនាទីការកិច្ចជាប្រវត្តិសាស្ត្ររបស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក៏ដូចជា ពីការចូលរួមយ៉ាងសកម្មពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គមទាំងស្ថាប័នសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ផ្នែកសិក្សាធិការ ប្រព័ន្ធផ្សព្វផ្សាយ និងមហាជនទូទៅដែលបានរួបរួមគ្នា ដើម្បីគោលបំណងរបស់សង្គមជាតិយើងគឺកម្ពុជាសស្អាត រឹងមាំ រុងរឿង និងរីកចម្រើន។

ស្របតាមធន្ទ: ការប្តេជ្ញា និងស្មារតីគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ដែលត្រូវបានរំលេចឡើងក្នុងឯកសារគន្លឹះ "យុទ្ធសាស្ត្របញ្ចកោណ" ដំណាក់កាលទី១ (២០២៣-២០២៨) និងបន្តពីយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី៣ (២០២០-២០២៥) ក៏ដូចជាការដកពិសោធន៍រៀនសូត្របានបន្ថែមពីបទពិសោធន៍ការងារនាពេលកន្លងមក ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី៤ (២០២៥-២០៣០) ត្រូវបានរៀបចំឡើងដើម្បីចង្អុលបង្ហាញទិស និងមាគ៌ាទៅមុខលើការងារកសាងសង្គមស្អាតស្អំ ស្ថាប័នរឹងមាំ និងមានប្រសិទ្ធភាព លើកស្ទួយតម្លាភាព សុចរិតភាព អភិបាលកិច្ចល្អ និងកៀរគរការចូលរួមពីគ្រប់តួអង្គបន្តទៀតក្នុងបុព្វហេតុរួមរបស់ជាតិមាតុភូមិយើង។

ដើម្បីសម្រេចបានឯកសារយុទ្ធសាស្ត្រមួយមានភាពស៊ីចង្វាក់ និងប្រទាក់ក្រឡាជាមួយគោលនយោបាយរដ្ឋ និងស្របតាមគតិ និងបទដ្ឋានអន្តរជាតិផងដែរនោះ វិចារណកម្មលើឧបករណ៍ និងបទពិសោធន៍ជាតិ និងអន្តរជាតិ ត្រូវបានធ្វើឡើង ហើយជាតុចូលពីសំណាក់ភាគីពាក់ព័ន្ធនានា ក៏ត្រូវបានយកមកពិនិត្យពិចារណាសំដៅធានាបាននូវទស្សនទានចម្រុះ និងបរិយាប័ន្នភាព។

ផែនការយុទ្ធសាស្ត្រជាតិដំណាក់កាលទី៤ ក្នុងរយៈពេល៥ឆ្នាំទៅមុខ (២០២៥-២០៣០) និងបន្ត កំណត់យកការងារអាទិភាព ៣ គឺ (១). ការងារអប់រំ (២). ការងារបង្ការទប់ស្កាត់ (៣). ការងារអនុវត្តច្បាប់ បង្ក្រាបបទល្មើសពុករលួយជាវិធានការស្នូល និងបំពេញបន្ថែមដោយការងារសំខាន់ៗមួយចំនួនទៀត រួមមាន៖ (១). ការពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ (២). បន្តគាំទ្រកំណែទម្រង់គន្ថឹះសំខាន់ៗ និងជាក់ស្តែង របស់រដ្ឋ (៣). ពង្រឹង ភាពរឹងមាំ និងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងអភិបាលកិច្ចល្អក្នុងវិស័យ ឯកជន និងធុរកិច្ច (៤). ពង្រឹង កិច្ចសហប្រតិបត្តិការរវាងស្ថាប័នប្រឆាំងអំពើពុករលួយ និងដៃគូពាក់ព័ន្ធ ទាំងរដ្ឋ និងឯកជន (៥). បង្កើន កិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិលើការងារប្រយុទ្ធប្រឆាំង អំពើពុករលួយ និងប្រឆាំងការសម្អាតប្រាក់ឱ្យបានកាន់តែប្រសើរ។

ស្ថាប័នប្រឆាំងអំពើពុករលួយមានជំនឿយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤ ដែលត្រូវបានរៀបចំឡើងតាមបរិបទនៃការប្រែប្រួលនយោបាយ សេដ្ឋកិច្ច និងសង្គម ព្រមទាំងស្របតាមយុទ្ធសាស្ត្រកំណែទម្រង់មុតស្រួចរបស់រាជរដ្ឋាភិបាល ពិតជានឹងនាំមកនូវជោគជ័យ បន្ថែមទៀតជូនប្រជាជន រាជរដ្ឋាភិបាល និងសង្គមជាតិទាំងមូល។

១.២. វិចារណកម្មនៃផែនការយុទ្ធសាស្ត្រជាតិ (២០២៥-២០៣០)

១.២.១. ឧបការណ៍កោលនយោបាយជាតិ

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៣-២០២៨) ត្រូវបានប្រកាសឱ្យអនុវត្តដោយប្រមុខ រាជរដ្ឋាភិបាល អាណត្តិទី៧ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៅខែសីហា ឆ្នាំ២០២៤ ជាយុទ្ធសាស្ត្រដែលត្រូវបានបន្តសម្រួច និងកែសម្រួលទៅតាមការវិវឌ្ឍ នៃកាលៈទេសៈ និងបរិបទប្រទេស ពី យុទ្ធសាស្ត្រចតុកោណនាអាណត្តិកន្លងមក និងបានដើរតួរជាប្រទីបបង្ហាញផ្លូវ សម្រាប់ប្រតិបត្តិការរបស់រដ្ឋ ក្នុងក្របខណ្ឌម៉ាក្រូជារួមផង និងក្របខណ្ឌមីក្រូកម្រិតក្រសួង-ស្ថាប័ននានាអនុវត្ត និងជាក់ចេញផែនការ សកម្មភាព និងការងារសំខាន់ផងដែរ។ គោលដៅប្រកបដោយមហិច្ឆតាដែលជាក្តីប្រាថ្នាចង់បាន របស់រាជរដ្ឋាភិបាល គឺនាំនាវាកម្ពុជាឆ្ពោះទៅមុខប្រកបដោយភាពជឿជាក់ ធន់ បន្តកសាងអភិវឌ្ឍបន្ថែម ទៀត និងជម្នះឱ្យបានដាច់ខាតនូវរាល់ឧបសគ្គ ការលំបាក បញ្ហាប្រឈម ដែលអាចកើតមាន ទាំងក្នុងបរិ ការណ៍ក្នុងស្រុក និងអន្តរជាតិ ដែលពោរពេញដោយភាពមិនច្បាស់លាស់ និងការប្រកួតប្រជែងគ្រប់វិស័យ។ អភិក្រមទាំង៥ "**ឆ្នុះកញ្ចាក់ ងូតទឹក ជុសភ្លែ ព្យាបាល និងវះកាត់**" ត្រូវបានជំរុញបន្តឱ្យគោរព អនុវត្ត និង បញ្ជាបឱ្យកាន់តែជ្រួតជ្រាប ពីសំណាក់ប្រតិបត្តិករ ដែលជាមន្ត្រីរាជការទាំងអស់ក្នុងការបំពេញតួនាទីការ កិច្ចស្របតាមគោលនយោបាយ និងសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល។ យន្តការតាមដាន ត្រួតពិនិ ត្យ និងវាយតម្លៃ (M&E) ដើម្បីតាមដានការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ក៏ត្រូវបានសម្រួច និងអនុវត្ត កាន់តែមានលក្ខណៈវិទ្យាសាស្ត្រ ច្បាស់លាស់ ដើម្បីជានាប្រសិទ្ធភាព និងផ្ទៃផ្កា។ ជោគជ័យនៃការអនុវត្ត

ការងារដែលមានក្នុងស្នូល៤ នៃយុទ្ធសាស្ត្របញ្ចកោណ រួមមាន (១.) ការពង្រឹង និងការកែទម្រង់ស្ថាប័ន (២.) ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ (៣.) ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌ (៤.) ការពង្រឹងកិច្ចសហការវិស័យឯកជន និងធុរៈកិច្ច មានភាពប្រទាក់ក្រឡាគ្នា ជាមួយនឹងស្នូលទី៣ ដែលជំរុញការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ដោយផ្តោតការងារអាទិភាពដូចជា៖

ទី១- ការរៀបចំ និងការដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិ ក្នុងមុខងារសាធារណៈ ព្រមទាំងការជំរុញការគោរពខ្ជាប់ខ្ជួននូវគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍ក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ។

ទី២- ការពង្រឹងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ច និងសវនកម្មព្រមទាំងការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធអធិការកិច្ច និងសវនកម្ម ដើម្បីធានាសុខដុមនីយកម្មនៃមុខងារអធិការកិច្ច និងសវនកម្ម ក្នុងរដ្ឋបាលសាធារណៈ។

ទី៣- ការពង្រឹងយន្តការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ការផ្តល់ការលើកទឹកចិត្តផ្អែកលើគុណាធិបតេយ្យ និងការចាត់វិធានការមុឺងម៉ាត់តាមច្បាប់ក្នុងការអនុវត្តតួនាទី និងការកិច្ចដើម្បីបង្កើនជំនឿទុកចិត្ត និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ទី៤- ការបន្តពង្រឹង និងពង្រីកការងារអប់រំ និងបង្ការទប់ស្កាត់ជាចម្បង ព្រមទាំងការពង្រឹងការអនុវត្តច្បាប់យ៉ាងមុឺងម៉ាត់ ដើម្បីបង្ក្រាបបទល្មើសអំពើពុករលួយ។

ទី៥- ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពប្រឆាំងអំពើពុករលួយ និងស្ថាប័នសាធារណៈ ជាពិសេសតាមរយៈយន្តការជនបង្គោល ទាំងការងារអប់រំ និងការងារបង្ការទប់ស្កាត់ ដើម្បីរៀបចំដាក់ឱ្យអនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការលើកកម្ពស់ភាពស្អាតស្អំនៅតាមស្ថាប័នសាធារណៈ។

ជាស្មារតីក្រើនរំលឹកលើកទឹកចិត្ត និងជំរុញការងារបន្ថែម ប្រមុខរាជរដ្ឋាភិបាលតែងតែថ្លែងការជំរុញការងារអភិបាលកិច្ចល្អ និងប្រឆាំងអំពើពុករលួយជាបន្តបន្ទាប់ ជាក់ស្តែងសារលិខិតអបអរសាទរទិវាជាតិ-អន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ឆ្នាំ២០២៤ បានស្នើដល់អង្គភាពប្រឆាំងអំពើពុករលួយក៏ដូចជាស្ថាប័ន និងតួអង្គពាក់ព័ន្ធរួមគ្នាអនុវត្តនូវសកម្មភាពគន្លឹះសំខាន់ៗ ដែលគាំទ្រដល់កិច្ចប្រឹងប្រែង រួមគ្នាមានដូចជា៖

(១). ពង្រឹងការអប់រំស្តីពីការប្រឆាំងអំពើពុករលួយឱ្យមានវិសាលភាពគ្របដណ្តប់បានកាន់តែទូលាយចូលកាន់តែជ្រៅទៅក្នុងស្រទាប់សង្គម ទាំងក្នុងសាលា-ក្រៅសាលា ទាំងក្នុងស្ថាប័នសាធារណៈ ឯកជន និងសង្គមស៊ីវិល ទាំងមុនចេញធ្វើការ និងក្នុងពេលធ្វើការ។

(២). *ជំរុញការបង្ការទប់ស្កាត់ក្នុងវិស័យរដ្ឋបាលសាធារណៈ រួមមាន ការផ្តល់សេវាសាធារណៈបានកាន់តែមានតម្លាភាព និងគណនេយ្យភាព - ការគ្រប់គ្រងទំនាស់ផលប្រយោជន៍ - ការការពារបុគ្គលរាយការណ៍ - ការដាក់វិន័យ និងទោសទណ្ឌ ។ល។*

(៣). *ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នប្រឆាំងអំពើពុករលួយ និងដៃគូពាក់ព័ន្ធ ទាំងស្ថាប័នសាធារណៈ ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ស្ថាប័ននីតិប្បញ្ញត្តិ វិស័យឯកជន សង្គមស៊ីវិល ផ្នែកសិក្សាធិការ និងប្រព័ន្ធផ្សព្វផ្សាយ សំដៅពង្រឹង និងពង្រីកការងារអប់រំ និងបង្ការទប់ស្កាត់ឱ្យបានកាន់តែរលូន និងមានប្រសិទ្ធភាព។*

(៤). *ការងារប្រឆាំងអំពើពុករលួយ ត្រូវការការរួមគ្នាពីគ្រប់ភាគី ហើយភាពស្អាតស្អំត្រូវតែកើតចេញពីផ្ទះនៃភាគីនីមួយៗ ស្ថាប័ននីមួយៗ។ អង្គភាពប្រឆាំងអំពើពុករលួយដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលត្រូវដើរតួនាទីជំរុញ និងសម្របសម្រួលចំពោះកិច្ចសហប្រតិបត្តិការចាំបាច់នានា ទាំងក្នុងការងារអប់រំ និងបង្ការទប់ស្កាត់ជាមួយដៃគូទាំងអស់ ដោយផ្តោតជាពិសេសលើការអនុវត្តគោលនយោបាយ និងផែនការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល និងស្របជាមួយផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ដែលដាក់ចេញ ដោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។*

(៥). *ដើម្បីជានានូវអភិបាលកិច្ចល្អក្នុងការដឹកនាំ និងគ្រប់គ្រងស្ថាប័ន មន្ត្រីរាជការទាំងអស់ត្រូវចងចាំនូវអភិក្រមទាំង ៥ "**ខ្នុះកញ្ចក់ ងូតទឹក ដុសក្អែល ញាបាល និងរះកាត់**" ជាត្រីវិស័យបង្ហាញផ្លូវក្នុងការបំពេញតួនាទីភារកិច្ច និងការរស់នៅប្រកបដោយសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវ។*

បន្ថែមពីនេះរាជរដ្ឋាភិបាលក៏បានដាក់ចេញនូវយន្តការគាំទ្រ និងជំរុញការឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (២០១៥-២០៣០) ព្រមជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល អាណត្តិទី៧ ដែលផ្តោតសំខាន់លើសកម្មភាពការងារជាយុទ្ធសាស្ត្រអន្តរវិស័យដែលបម្រើដល់គោលដៅរួមមាន ចែងក្នុងយុទ្ធសាស្ត្របញ្ចកោណផងដែរ។

១.២.២. ឧបករណ៍គោលនយោបាយ តំបន់ និងអន្តរជាតិ

គោលនយោបាយតំបន់ និងអន្តរជាតិ ដូចជា គោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (Sustainable Developement Goals,SDGs) ២០១៥-២០៣០ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (United Nations Convention against Corruption, UNCAC) ស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force, FATF) ត្រូវបានប្រើប្រាស់ជាមូលដ្ឋានដើម្បីរៀបចំយុទ្ធសាស្ត្រជាតិនេះផងដែរ។

គោលដៅទី១៦ នៃ (SDGs) ជាគោលដៅជំរុញឱ្យមានសន្តិភាព ការអភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាព និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងស្ថាបនាស្ថាប័នឱ្យមានប្រសិទ្ធភាព គណនេយ្យភាពគ្រប់លំដាប់ថ្នាក់។ គោលដៅទី១៦ នេះបានកំណត់ចំណុចដៅពាក់ព័ន្ធនឹងការងារប្រឆាំងអំពើពុករលួយដូចខាងក្រោម៖

- ១៦.៣ លើកកម្ពស់នីតិរដ្ឋ និងធានាការទទួលបានយុត្តិធម៌ស្មើគ្នា
- ១៦.៤ ប្រយុទ្ធប្រឆាំងលំហូរអាវុធ និងហិរញ្ញវត្ថុខុសច្បាប់ ពង្រឹងការទាមទារ និងបញ្ជូនមកវិញនូវទ្រព្យសម្បត្តិដែលបាត់បង់
- ១៦.៥ កាត់បន្ថយអំពើពុករលួយ និងបទស៊ីសំណូក សូកប៉ាន់គ្រប់ទម្រង់
- ១៦.៦ រៀបចំស្ថាប័នឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព
- ១៦.៧ ធានាឱ្យមានតំណាងចូលរួមក្នុងការសម្រេចចិត្តប្រកបដោយបរិយាបន្ន និងប្រកបដោយការឆ្លើយតប
- ១៦.១០ ធានាថាសាធារណៈជនទទួលបានព័ត៌មាន និងការការពារសេរីភាពជាមូលដ្ឋាន។

អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) ដែលជាបទដ្ឋានអន្តរជាតិគម្រិតសកល ហើយដែលកម្ពុជាបានក្វាយជារដ្ឋភាគីតាំងពីឆ្នាំ២០០៧ បានផ្តល់នូវមូលដ្ឋានចំណេះ និងការយល់ដឹងទាំងក្នុងក្របខ័ណ្ឌ កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយថ្នាក់ជាតិ និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាដៃគូអន្តរជាតិ។ បទពិសោធន៍ល្អៗជាច្រើនដែលកម្ពុជាទទួលបានក្នុងការចូលរួមអនុវត្តយន្តការត្រួតពិនិត្យការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) ដំណាក់កាលទី១ ទាំងជុំទី១ និងទី២ (២០១១-២០២៥) ទាំងដោយការបើកទ្វារទទួលអ្នកជំនាញបរទេសឱ្យមកវាយតម្លៃពីចំណុចខ្លាំង ចំណុចខ្វះខាតក្របខណ្ឌច្បាប់ គោលនយោបាយ និងការអនុវត្តការងារប្រឆាំងអំពើពុករលួយ នៅកម្ពុជា និងការបញ្ជូនអ្នកជំនាញការខ្លួនទៅត្រួតពិនិត្យប្រទេសដទៃ ដូចជា អាហ្ស៊ីសាអូឌីត ម៉ាល់តា លីបង់ ជាដើម សុទ្ធតែត្រូវបានយកមកវាយតម្លៃ សំយោគ និងប្រើប្រាស់ជាធាតុចូលដ៏មានតម្លៃក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ។

បន្ថែមលើនេះ និយាមអនុវត្តរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ត្រូវបានពិនិត្យ និងដកស្រង់មកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រនេះផងដែរ។ ការស៊ើបអង្កេតប្រឆាំងការសម្អាតប្រាក់ដែលជាផលនៃបទល្មើសពុករលួយ វិធានការ និងវិធីសាស្ត្រផ្សេងៗក្នុងការប្រមូលមកវិញនៃទ្រព្យដែលជាផលនៃអំពើពុករលួយ ព្រមទាំងវិធានទាំងឡាយក្នុងការជួយគ្នាទៅវិញទៅមកក្នុងក្របខណ្ឌទ្វេភាគី ឬពហុភាគីលើការស៊ើបអង្កេត តាមរក និងរឹបអូសផលនៃបទល្មើសឆ្លងដែន សុទ្ធតែជាតម្រូវការគន្លឹះដែលត្រូវបន្តយកចិត្តទុកដាក់អនុវត្តក្នុងសកម្មភាព ៥ ឆ្នាំបន្តទៀត ដើម្បីបង្ហាញដល់សហគមន៍អន្តរជាតិពីការ ប្តេជ្ញាចិត្តខ្ពស់របស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

១.២.៣. បទពិសោធន៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៣ ដំណាក់កាលកន្លងមក

ផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ៣ដំណាក់កាលកន្លងមកត្រូវបានកសាង និងអនុវត្តដោយទទួលបានលទ្ធផលគួរជាទីមោទនៈ។ បណ្តាការងារអាទិភាព ដូចជា ការងារអប់រំពង្រឹងការយល់ដឹងអំពីច្បាប់ ផលវិបាកនិងយន្តការផ្សេងៗក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់គាគីពាក់ព័ន្ធទាំងឡាយ ការងារបង្ការទប់ស្កាត់ត្រូវបានពង្រឹងជាលំដាប់ ដើម្បីជំរុញអភិបាលកិច្ចល្អទាំងក្នុងវិស័យសាធារណៈនិងឯកជន ជាក់ស្តែងគឺវិធានការបង្ការអំពើពុករលួយ លើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ការប្រឡងប្រជែងផ្សេងៗ និងការប្រឡងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការ ការត្រួតពិនិត្យលើការងារលទ្ធកម្មសាធារណៈ ការចូលរួមផ្ទៀងផ្ទាត់ការប្រមូលថវិការដ្ឋជាដើមៗ ដោយឡែកការអនុវត្តច្បាប់និងការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការក៏ត្រូវបានអនុវត្តស្របគ្នាផងដែរ ហើយទទួលបានលទ្ធផលល្អទាំងបរិមាណនិងគុណភាព ខណៈកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់អាស៊ាននិងអន្តរជាតិក៏បានវិវត្តយ៉ាងវិជ្ជមានៗ បទពិសោធន៍ជោគជ័យដែលទទួលបានទាំងនេះ នឹងត្រូវប្រើប្រាស់ជាជាតុផ្សំ រួមជាមួយជាតុចូលដែលទទួលបានពីសំណាក់ដៃគូ និងភាគីពាក់ព័ន្ធទាំងអស់ទាំងក្នុងស្ថាប័នរដ្ឋ សង្គមស៊ីវិល វិស័យឯកជន និងពីសហគមន៍អន្តរជាតិក៏ដូចមហាជនទូទៅ ទាំងដោយផ្ទាល់និងដោយប្រយោល ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិដំណាក់កាលទី៤ (២០២៥-២០៣០) នេះផងដែរ។

១.៣. ប្រៀបធៀបផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៤ (២០២៥-២០៣០) និងផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៣ (២០២០-២០២៥)

យុទ្ធសាស្ត្រទាំង ៧ មុខព្រួញ រួមមាន (១). អប់រំ (២). បង្ការទប់ស្កាត់ (៣). អនុវត្តច្បាប់ (៤). គោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិ (៥). កិច្ចសហការជាតិ អន្តរជាតិ និងការរឹបអូសផលនៃបទល្មើស (៦). ពង្រឹងសមត្ថភាព អភិបាលកិច្ចផ្ទៃក្នុង និងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ (៧). យុទ្ធសាស្ត្របញ្ញាសិប្បនិម្មិត (AI) អភិវឌ្ឍន៍សមត្ថភាព សន្តិសុខ ព័ត៌មានប្រឆាំងបទល្មើសពុករលួយដោយ AI ដែលត្រូវបានរំលេចក្នុងផែនការយុទ្ធសាស្ត្រដំណាក់កាលទី៣ (២០២០-២០២៥) នឹងត្រូវបន្តអនុវត្ត ដោយក្នុងនោះចំណាត់ការ និងសកម្មភាពជាច្រើននឹងត្រូវសម្រួចសម្រិតសម្រាំងឱ្យស្របតាមគោលនយោបាយ និងអនុសាសន៍ណែនាំរបស់រាជរដ្ឋាភិបាល និងស្របតាមការវិវឌ្ឍផ្លាស់ប្តូរថ្មីៗ ទាំងក្នុងបរិបទជាតិ និងអន្តរជាតិក្នុងក្របខណ្ឌកំណែទម្រង់ជាបន្តបន្ទាប់របស់រដ្ឋ ជាពិសេសកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ យុត្តិធម៌ និងតុលាការ រឹមឆ្ងាការ និងវិសហមជ្ឈការ និងក្របខណ្ឌកាតព្វកិច្ចដែលកម្ពុជាមានទាំងក្នុងតំបន់ និងសកល ក្រោមយន្តការត្រួតពិនិត្យការអនុវត្ត UNCAC និងការវាយតម្លៃ

ទៅវិញទៅមកលើការអនុវត្តអនុសាសន៍ដាក់ចេញដោយអង្គការហិរញ្ញវត្ថុ FATF សម្របសម្រួលដោយ APG ។

១.៤. ការរៀបចំផែនការយុទ្ធសាស្ត្រជាតិដំណាក់កាលទី៤ (២០២៥-២០៣០)

បទពិសោធន៍ កំណត់ត្រា និងជាតុចូលជាអនេកត្រូវបានផ្តល់ឡើងដោយប្រតិបត្តិករគ្រប់ជាន់ថ្នាក់នៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយ និងដោយភាគីពាក់ព័ន្ធមកពីស្ថាប័នសាធារណៈ ស្ថាប័នរដ្ឋសភា ព្រឹទ្ធសភា វិស័យឯកជន សង្គមស៊ីវិល ផ្នែកសិក្សាធិការ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកជំនាញ UNODC។ ក្រោមការផ្តល់អនុសាសន៍ និងការណែនាំគន្លឹះៗពីសំណាក់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ទេសរដ្ឋមន្ត្រី ប្រធាន អ.ប.ព.** និងកិច្ចប្រឹងប្រែងរបស់ក្រុមការងារ អ.ប.ព. ជាតុផ្សំដែលប្រមូលបានត្រូវបានសំយោគ និងចងក្រងជាបណ្តុំគំនិតក្នុងទម្រង់ជាឯកសារដែលត្រូវពិនិត្យ ពិភាក្សា និងអនុម័ត ដោយ ក.ជ.ប.ព.។ ជាទម្រង់ផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៤ (២០២៥-២០៣០) ត្រូវបានរៀបចំឡើងជា ៧ ផ្នែករួមមាន ៖

១- សេចក្តីផ្តើម៖ ផ្តល់ខ្លឹមសារសង្ខេបអំពីដើមចម វិចារណកម្ម និងការរៀបចំផែនការយុទ្ធសាស្ត្រជាតិ (២០២៥- ២០៣០)។

២- ការត្រួតពិនិត្យឡើងវិញនូវការអនុវត្តផែនការយុទ្ធសាស្ត្រ ដំណាក់កាលទី ៣ (២០២០-២០២៥)៖ សង្ខេបនូវសមិទ្ធផលសំខាន់ៗ កត្តាជោគជ័យ បញ្ហាប្រឈម និងមេរៀនទទួលបាន។

៣-ការវិភាគអំពីបរិយាកាសជុំវិញ៖ ជាការពិនិត្យ និងវិភាគលើបរិយាកាសជុំវិញទាំង ៦ គឺ នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន (PESTLE) និងការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង (SWOT)។

៤-ទិសដៅយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ (២០២៥-២០៣០)៖ ការកំណត់អំពីចក្ខុវិស័យ បេសកកម្ម គោលនយោបាយ គុណតម្លៃ គោលដៅ យុទ្ធសាស្ត្រ សូចនាករតាមដាន និងការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រទៅនឹងគម្រោងថវិកា។

៥-ផែនការយុទ្ធសាស្ត្រ និងថវិកា៖ បង្ហាញពីការបន្សុីគ្នារវាងផែនការយុទ្ធសាស្ត្រ និងថវិកាកម្មវិធី និងការមានថវិកាគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ។

៦-ការត្រួតពិនិត្យ និងវាយតម្លៃ៖ បង្ហាញពីការពង្រឹងយន្តការត្រួតពិនិត្យ និងវាយតម្លៃ ការរាយការណ៍ និងការផ្សព្វផ្សាយ ក៏ដូចជាការកែសម្រួលផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី ៤ (២០២៥-២០៣០) តាមការចាំបាច់។

៧- សេចក្តីសន្និដ្ឋាន៖ លើកឡើងពីការសន្និដ្ឋាន ការប្តេជ្ញា និងការរំពឹងទុកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី ៤ (២០២៥-២០៣០) ។

២. ការត្រួតពិនិត្យឡើងវិញនូវការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៣ (២០២០-២០២៥)

២.១. សារធាន

ផែនការយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ដំណាក់កាលទី ៣ (២០២០-២០២៥) ដែលអមដោយផែនការសកម្មភាពរបស់ អ.ប.ព. ត្រូវបានដាក់ចេញដោយ ក.ជ.ប.ព. កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ រួមមានយុទ្ធសាស្ត្រចំនួន ៦ សកម្មភាពគោលចំនួន ៤៣ និងសកម្មភាពចំនួន ៧៨។ សមិទ្ធផលជាទីមោទនៈជាច្រើនត្រូវបានសម្រេចឡើងក្នុងរយៈពេល ៥ ឆ្នាំ កន្លងទៅនេះ។ ការពិនិត្យមើលឡើងវិញនូវការអនុវត្តផែនការនេះ ជាពិសេសពីសមិទ្ធផលសំខាន់ៗពីកត្តាជោគជ័យ ពីបញ្ហាប្រឈម ក៏ដូចជាពីមេរៀនទទួលបានកន្លងមក នឹងជួយសម្រួចនូវទស្សនទានចាំបាច់ក៏ដូចជាតម្រង់ទិសឱ្យចំគោលដៅសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី ៤ (២០២៥-២០៣០)។

២.២. សមិទ្ធផលសំខាន់ៗ

២.២.១. ការងារអប់រំ

*បេសកកម្មលើកកម្ពស់សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈវិធានការអប់រំ **"ដើម្បីឱ្យម្នាក់ៗ មិនចង់ពុករលួយ"** នៅតែបន្តជាយុទ្ធសាស្ត្រគោលចម្បង ជាសរសរស្តម្ភទី១ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយយុទ្ធសាស្ត្រគោលផ្សេងទៀតដែលក្នុងរយៈពេលជាង ១៥ ឆ្នាំ នៃការខិតខំប្រឹងប្រែងសម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ នាំឱ្យមានការប្រែប្រួលនូវផ្នត់គំនិតសង្គមចំពោះអំពើពុករលួយ បង្កើនជំនឿ-ទំនុកចិត្តលើរាជរដ្ឋាភិបាល ហើយការប្រែប្រួលនេះមានលក្ខណៈរឹងមាំ ចាក់ឫសគល់ជ្រៅ មិនអាចជាក់ថយក្រោយវិញបាន។*

លទ្ធផលនៃការងារអប់រំផ្សព្វផ្សាយដែលជាភារកិច្ចរបស់យើងទាំងអស់គ្នានេះ កើតចេញជាផ្លែផ្កាគឺដោយមានការចូលរួមចំណែកពីគ្រប់មជ្ឈដ្ឋាន រួមមាន វិស័យសាធារណៈ វិស័យឯកជន វិស័យអប់រំ សិក្សាធិការ ផ្នែកសារព័ត៌មាន ផ្នែកសិល្បៈ និងអង្គការសង្គមស៊ីវិលជាមួយ អ.ប.ព. ប្រកបដោយគោលដៅបត់បែនតាមបរិបទពិភពលោក និងប្រទេស និងបន្តដូចក្ងៀងរលឹម តាមរូបភាពផ្សេងៗ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនថាក្នុងពេលដែលប្រទេស និងពិភពលោកកំពុងជួបប្រទះវិបត្តិ ជាពិសេសវិបត្តិមហាសោកនាដកម្មជំងឺកូវីដ-១៩ និងអំឡុងពេលស្តារប្រទេសឡើងវិញ និងក្រោយវិបត្តិក្តី។ ជារួមសកម្មភាពអប់រំផ្សព្វផ្សាយស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានរៀបចំឡើងនៅ ២ មជ្ឈដ្ឋានសំខាន់គឺ ការអប់រំក្នុងសាលា និងការអប់រំក្រៅសាលា។

ការអប់រំក្នុងសាលា

ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយនៅក្នុងសាលា បានចាប់អនុវត្តតាំងពីឆ្នាំ២០១៣ ក្រោមកិច្ចសហការរវាង អ.ប.ព. និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងរូបភាពជាការបញ្ចូលការអប់រំស្តីពីការប្រឆាំងអំពើពុករលួយនៅកម្រិតទាំង៣ (បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ) នៃការអប់រំចំណេះទូទៅ ដោយបានរៀបចំសរុប 36 មេរៀន សម្រាប់គ្រូ និងសិស្ស និងបានបោះពុម្ពជាសៀវភៅជូនសម្រាប់សិក្សាសរុប 825,000 ក្បាល បណ្តុះបណ្តាលគ្រូបង្គោលសម្រាប់បង្រៀនបន្តជាង 500 នាក់ នៅទូទាំងប្រទេស ហើយមកដល់បច្ចុប្បន្នមានគ្រូសីលធម៌-ពលរដ្ឋវិជ្ជាសរុបជាង 5 ម៉ឺននាក់ បាន និងកំពុងបង្រៀនមុខវិជ្ជានេះ និងសិស្សជាង 2 លាននាក់បានទទួលការបណ្តុះបណ្តាល បំពាក់គុណតម្លៃសីលធម៌ស្អាតស្អំ សុចរិតភាព និងការខិតខំប្រឹងប្រែងផ្ទាល់ខ្លួនក្នុងការរស់នៅ ការបន្តការសិក្សា ក៏ដូចជាចាប់យកវិជ្ជាជីវៈការងារណាមួយប្រកបដោយសមាអាជីវៈ។

កម្រិតមធ្យមសិក្សាទុតិយភូមិ	កម្រិតមធ្យមសិក្សាបឋមភូមិ	កម្រិតបឋមសិក្សា



មេរៀនអប់រំស្តីពីការប្រឆាំងអំពើពុករលួយ ក៏ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធី MoEYS E-Learning Application និងគេហទំព័រ សាលារៀនបែបឌីជីថល សម្រាប់អ្នកបង្រៀន និងអ្នករៀនជំនាន់ថ្មី ដែលផ្តល់លទ្ធភាពកាន់តែងាយស្រួលដល់បុគ្គលគ្រប់រូបអាចស្វ័យសិក្សាដោយខ្លួនឯងបានគ្រប់កាល:ទេស:។ ចាប់តាំងពីឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្នប្រធានបទពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយបានក្លាយជាខ្លាតរាស់សមត្ថភាពត្រៀមសម្រាប់បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា និងការប្រកបការងារតាមរយៈការដាក់ចេញនូវសំណួរស្តីពីការប្រឆាំងអំពើពុករលួយនៅក្នុងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ដែលបានសបញ្ជាក់ពីការកាន់តែកើនឡើងនូវការចាប់អារម្មណ៍លើគុណតម្លៃនៃមេរៀនអប់រំស្តីពីការប្រឆាំងអំពើពុករលួយពីសំណាក់ប្រព័ន្ធអប់រំនៅកម្ពុជាក៏ដូចជាការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលលើការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ ដែលញ៉ាំងឱ្យយុវជនជំនាន់ក្រោយកាន់តែចង់ចេះចង់ដឹងលើមេរៀននេះ។

សម្រាប់ការបណ្តុះបណ្តាលនៅតាមសាលាវិជ្ជាជីវៈ និងកម្រិតឧត្តមសិក្សា គឺត្រូវបានយកចិត្តទុកដាក់ បញ្ជាបមេរៀនស្តីពីការប្រឆាំងអំពើពុករលួយនៅក្នុងកម្មវិធីសិក្សាតាមរយៈការធ្វើបាឋកថាច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងបង្រៀនមេរៀនស្តីពីការប្រឆាំងអំពើពុករលួយ ព្រមទាំងក្រមសីលធម៌ដែលមេរៀន អ.ប.ព. បានរៀបចំមានសរុប 6 មេរៀន រយៈពេលបង្រៀន 12-15 ម៉ោង ដោយចាត់ទុកជាមុខវិជ្ជាសំខាន់ និងជាគ្រឹះក្នុងការលើកកម្ពស់គុណភាពក្រមសីលធម៌ សុចរិតភាព ភាពស្អាតស្អំ និងការអនុវត្តវិជ្ជាជីវៈបានកាន់តែល្អប្រសើរ។

ការអប់រំក្រៅសាលា

ការអប់រំនៅក្រៅសាលា នៅតែមិនអាចខ្វះបាន និងមានសកម្មភាពជាបន្តបន្ទាប់ ដើម្បីបំផុសការចូលរួមប្រឆាំងអំពើពុករលួយ។

ស្ថានភាពប្រែប្រួលនៃការរស់នៅក្នុងសង្គម ជាពិសេសក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងក៏ជាឆ្នាំចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយដំណាក់កាលទី៣ ដែលបានកាត់ផ្តាច់ទំនាក់ទំនងផ្ទាល់ក្នុងសង្គមស្ទើរទាំងស្រុង និងការលេចឡើងកំណត់ជាអាទិភាពនូវគោលនយោបាយបច្ចេកវិទ្យា បរិវត្តន៍ឧស្សាហកម្ម 4.0 អ.ប.ព. បានចាប់យកជាគោលនូវការផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗ

បែបបុរាណនិងទំនើបតាមបណ្តាញទំនាក់ទំនងសង្គម ចំពោះឧបករណ៍អប់រំផ្សព្វផ្សាយសារគោលនយោបាយប្រឆាំងអំពើពុករលួយរបស់រាជរដ្ឋាភិបាល - វីដេអូព័ត៌មាន - បទយកការណ៍ - ចម្រៀង វីដេអូ ឬ ខ្លឹមសារអប់រំដែលក្នុងនោះការផ្សព្វផ្សាយខាងលើបានទៅដល់អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមនៅកម្ពុជាជាង 11 លាននាក់ នាំឱ្យការយល់ដឹងស្តីពីការប្រឆាំងអំពើពុករលួយទៅដល់សាធារណជនកាន់តែទូលំទូលាយ និងស្ទើរគ្រប់មជ្ឈដ្ឋាន។ ទន្ទឹមនឹងនេះ អ.ប.ព. ក៏បានចូលរួមជាវគ្គិនលើប្រធានបទពាក់ព័ន្ធការប្រឆាំងអំពើពុករលួយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗផងដែរ។



ទោះបីមានភាពជោគជ័យលើគោលដៅអប់រំតាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម ប៉ុន្តែសកម្មភាពចុះអប់រំផ្សព្វផ្សាយផ្ទាល់នៅតែបន្តអនុវត្តស្របគ្នាក្នុងបរិបទអនុគ្រោះក្រោយការគ្រប់គ្រង និងបញ្ចប់បាននូវការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីផ្សារភ្ជាប់ទស្សនៈនៃការអប់រំកាន់តែជិតស្និទ្ធជាមួយគោលដៅ ឆ្លើយតបរាល់សំណួរ ចម្ងល់ផ្សេងៗទាន់ពេលវេលា និងស្វែងយល់ប្រមូលជាតុចូលបន្ថែមផ្ទាល់ៗអំពីទស្សនៈការយល់ដឹង ការយល់ឃើញពីយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ការវិវត្តនៃអំពើពុករលួយក្នុងសង្គម ដើម្បីសម្រួចយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយឱ្យបានកាន់តែសមស្រប និងមានប្រសិទ្ធភាព។ អ្នកនាំសារប្រឆាំងអំពើពុករលួយ អ.ប.ព. បានចុះអប់រំផ្សព្វផ្សាយក្នុងទម្រង់ជាការផ្តល់បាឋកថាច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដល់មូលដ្ឋាន ខេត្ត-ស្រុក មន្ទីរ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈ-ឯកជន គ្រឹះស្ថានសិក្សា សាលាវិជ្ជាជីវៈ អង្គការ ទីកន្លែងងាយរងគ្រោះដោយអំពើពុករលួយ មានអ្នកចូលរួមដោយផ្ទាល់ ជាមន្ត្រីរាជការ កងកម្លាំង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស បុគ្គលិកគ្រឹះស្ថានឯកជន ធុរជន សរុបចំនួន 11,687 នាក់ ដោយមានការចែកជូននូវឧបករណ៍អប់រំ-ផ្សព្វផ្សាយ រៀបចំ និងផលិតដោយ អ.ប.ព. ផងដែរ។



ការបង្កើតកម្មវិធីនានាក្នុងគោលដៅបណ្តុះផ្នត់គំនិតស្អាតស្អំដល់សិស្សានុសិស្ស និងមហាជន ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ជាក់ស្តែង អ.ប.ព. តែងតែមានកម្មវិធីសំណួរ-ចម្លើយអំពីការយល់ដឹងស្តីពីការប្រឆាំងអំពើពុករលួយ ដោយបានផ្តល់រង្វាន់ និងការដូអនុស្សាវរីយ៍សម្រាប់អ្នកឆ្លើយត្រូវ និងអ្នកចូលរួម នៅតាមសាលារៀន តាមផ្សារ ទីប្រជុំជន និងទីសាធារណៈ ព្រមទាំងមានការបង្ហោះចំណេះដឹងខ្លីៗស្តីពីការប្រឆាំងអំពើពុករលួយនៅលើទំព័រហ្វេសប៊ុករបស់ អ.ប.ព. ផងដែរ។

អនុលោមតាមការកំណត់នៅក្នុងអនុក្រឹត្យលេខ ១៥០ អនក្រ.បក ស្តីពីទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ អ.ប.ព. ជារៀងរាល់ឆ្នាំ បានរៀបចំចាត់ចែងកិច្ចការនៃទិវានេះ ដោយរួមសហការជាមួយ ក្រសួង-ស្ថាប័ន សិល្បករ សិល្បការនី អ្នកសារព័ត៌មាន វិស័យឯកជន សំដៅលើកស្ទួយការយល់ដឹងរបស់សាធារណជនពីអំពើពុករលួយ និងជំរុញចលនាមហាជនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ក្រោមរូបភាពជាការប្រគំតន្ត្រីផ្សាយផ្ទាល់តាមកញ្ចក់ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយ ការចុះអប់រំផ្សព្វផ្សាយផ្ទាល់ និងប្រតិបត្តិការនាំសារប្រឆាំងអំពើពុករលួយដល់មូលដ្ឋាន ព្រមទាំងផ្សព្វផ្សាយសារប្រឆាំងអំពើពុករលួយតាមមធ្យោបាយផ្សេងៗ។ ចំពោះការចុះអប់រំផ្សព្វផ្សាយផ្ទាល់ និងប្រតិបត្តិការនាំសារប្រឆាំងអំពើពុករលួយ បានធ្វើឡើងក្នុងរូបភាពផ្សេងៗដែលក្នុងនោះរួមមាន ការបិទផ្សាយសារប្រឆាំងអំពើពុករលួយ ការសម្តែងសៀក ក្រុមតន្ត្រីតូចៗ ការសម្តែងតន្ត្រី Live Band តាមសាលារៀន តាមផ្សារ ទីប្រជុំជន ទីសាធារណៈ និងមានការសម្ភាសន៍ពីចំណាប់អារម្មណ៍អ្នកចូលរួមចំពោះទិវាជាតិ-អន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ព្រមទាំងមានការផ្សព្វផ្សាយខ្ទឹមសារដកស្រង់ចេញពីមេរៀនអប់រំស្តីពីការប្រឆាំងអំពើពុករលួយផងដែរ។

ការងារអប់រំ								
បរិយាយ	**2011 - 2015**	**2016 - 2020**	**2021**	**2022**	**2023**	**2024**	**2025**	**សរុប**
1. កម្មវិធីផ្សព្វផ្សាយច្បាប់								
អ្នកចូលរួម	84,182	89,862	1,518	1,886	4,060	3,245	978	**185,731 នាក់**
គោលដៅ/លើក	370	569	9	17	35	38	9	**1,047 លើក**
2. ឧបករណ៍អប់រំ ផ្សព្វផ្សាយ								
កម្រងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធ ការប្រឆាំងអំពើពុករលួយ	130,000	90,000	-	6,000	5,000	10,000	3,000	**244,000**
ប័ណ្ណផ្ទត់/Poster/ Sticker/ ប្រតិទិន	225,100	111,000	-	-	-	-	-	**336,100**
ចម្រៀង/ស្ប៉តអប់រំ/វីដេអូខ្លី-ព័ត៌មាន	13	33	23	25	74	61	25	**254**
សៀវភៅអប់រំស្តីពី ការប្រឆាំងអំពើពុករលួយ (ថ្នាក់ទី១០ ទី១១ និងទី១២)	145,000	-	-	-	-	-	-	**145,000**
សៀវភៅអប់រំស្តីពី ការប្រឆាំងអំពើពុករលួយ (ថ្នាក់ទី៧ ទី៨ និងទី៩)	200,000	-	-	-	-	-	-	**200,000**
សៀវភៅអប់រំស្តីពី ការប្រឆាំងអំពើពុករលួយ (ថ្នាក់ទី៤ ទី៥ និងទី៦)	-	480,000	-	-	-	-	-	**480,000**
3. សកម្មភាពបញ្ចូលមេរៀនស្តីពីការប្រឆាំងអំពើពុករលួយក្នុងកម្មវិធីសិក្សា								
បណ្តុះបណ្តាល គ្រូបង្គោលមធ្យមសិក្សា និងបឋមភូមិ ថ្នាក់ទី៤ ដល់ទី១២	100	436	-	-	-	-	-	**536**
ចុះសង្កេតការណ៍សម្របសម្រួល និងផ្តល់ជំនួយតាមការចាំបាច់ក្នុងវគ្គបណ្តុះបណ្តាលបន្តដល់គ្រូបង្រៀនមេរៀនប្រឆាំងអំពើពុករលួយ	-	1,618 9 *ខេត្ត*	-	-	-	-	-	**1,618 នាក់ 9 *ខេត្ត***
ចុះតាមដាន សង្កេតលើការអនុវត្តការបង្រៀន និងរៀន	4 *សាលារាជធានីភ្នំពេញ*	6	-	-	-	-	-	**10**

4. ទិវាជាតិប្រឆាំងអំពើពុករលួយ ៩ធ្នូ								
កម្មវិធីផ្សព្វផ្សាយទិវាជាតិ-អន្តរជាតិប្រឆាំងអំពើពុករលួយ៩ធ្នូ								
គោលដៅ	-	-	-	14	173	47	-	**234 គោលដៅ**
អ្នកចូលរួម (រូប)	-	-	-	តាមសាលារៀន និងទីសាធារណៈ	16,859 និងបេក្ខជនប្រឡងបាក់ឌុបមួយចំនួន	4,245	-	**21,104 នាក់ បេក្ខជនប្រឡងបាក់ឌុបមួយចំនួន សិស្ស និងមហាជន**
កម្មវិធីប្រារព្ធទិវាជាតិប្រឆាំងអំពើពុករលួយ៩ធ្នូ								
អ្នកចូលរួម (រូប)	11,385	32,625 សង្កេតការណ៍ការផ្តល់សេវាសាធារណៈ និងផ្សព្វផ្សាយខ្ទឹមសារប្រឆាំងអំពើពុករលួយ	327 សហការជាមួយក្រសួង-ស្ថាប័ន ចងបដាបំពាក់មេដាយ ផលិតវីដេអូផ្សព្វផ្សាយលើបណ្តាញសង្គម	846	2,000	700	-	**47,883 នាក់ និងជាង 218,000 នាក់ គណនី Like Page**
ផ្សាយផ្ទាល់	ទូរទស្សន៍អប្សរា និងអាស៊ីអាគ្នេយ៍	ទូរទស្សន៍អប្សរា 10 ស្ថានីយទូរទស្សន៍ និង៣វិទ្យុ ផ្សព្វផ្សាយតាមបណ្តាញសង្គម	ផ្សព្វផ្សាយតាមបណ្តាញសង្គម	ផ្សព្វផ្សាយតាមបណ្តាញសង្គម	ទូរទស្សន៍ ថោន ផ្សព្វផ្សាយតាមបណ្តាញសង្គម	ទូរទស្សន៍ ថោន ផ្សព្វផ្សាយតាមបណ្តាញសង្គម	-	**ផ្សាយផ្ទាល់ 11 លើក, ផ្សព្វផ្សាយខ្ទឹមសារតាមទូរទស្សន៍ 10 កន្លែង និងវិទ្យុ 3 កន្លែង**

២.២.២. ការជាវបង្ការទប់ស្កាត់

*សរសេរស្តម្ភសំខាន់ទី២នៃយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ដែលជាវិធានប្រទាក់ក្រឡាបំពេញបន្ថែមឱ្យយុទ្ធសាស្ត្រផ្សេងទៀត ជាពិសេសយុទ្ធសាស្ត្រអប់រំ គឺការបង្ការទប់ស្កាត់ "**ដើម្បីឱ្យម្នាក់ៗមិនអាចពុករលួយ**"។ យុទ្ធសាស្ត្របង្ការទប់ស្កាត់ ផ្សារភ្ជាប់នឹងទស្សនៈសកល "**ការពារប្រសើរជាងព្យាបាល**" ជាសំណាញ់ញឹក ២ ជាន់ ដែលមានលក្ខណៈ **បុរេសកម្ម (បង្ការ)** ដាក់ចេញនូវក្របខណ្ឌគតិយុត្ត យន្តការផ្សេងៗដើម្បីលុបបំបាត់ចន្លោះប្រហោងឱកាសប្រព្រឹត្តអំពើអសកម្មពុករលួយ និង**សកម្ម (ទប់ស្កាត់)** តាមដាន*

សង្កេត ពិនិត្យការអនុវត្តបទប្បញ្ញត្តិ និងយន្តការដែលបានដាក់ចេញ ព្រមទាំងមានចំណាត់ការធ្វើយតបភ្លាមៗពារាំងភាពមិនប្រក្រតីករណីឃើញមានចំណុចកត់សម្គាល់ណាមួយ និងចុងក្រោយធ្វើការវាយតម្លៃផ្តល់អនុសាសន៍កំណត់វិធានការបំពេញចន្លោះប្រហោងដែលមាន។

ក្នុងស្មារតីការបង្ការទប់ស្កាត់អំពើពុករលួយជាភារកិច្ចរបស់យើងទាំងអស់គ្នា រាជរដ្ឋាភិបាលក្នុងន័យៈមោះមុតគាំទ្រ និងជំរុញការប្រយុទ្ធប្រឆាំងអំពើពុករលួយ បានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវអភិក្រមការងារពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ពង្រឹងប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ តម្លាភាព សុចរិតភាព និងអនុវត្តនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យសំខាន់ៗ រួមមាន ហិរញ្ញវត្ថុសាធារណៈ យុត្តិធម៌និងតុលាការ និងរដ្ឋបាលសាធារណៈ ផ្តោតសំខាន់លើការចាក់គ្រឹះឱ្យកាន់តែរឹងមាំនៃគុណភាពប្រសិទ្ធភាព ទំនើបកម្ម និងការអភិវឌ្ឍដោយចីរភាពយូរអង្វែងដែលធ្វើឱ្យការបង្ការ និងទប់ស្កាត់អំពើពុករលួយកាន់តែមានប្រសិទ្ធភាព និងមានលក្ខណៈជាប្រព័ន្ធ។ យើងក៏កត់សម្គាល់ឃើញថា បណ្តាក្រសួង-ស្ថាប័ននានា មានភាពម្ចាស់ការក្នុងការបំពេញការងារ និងលុបបំបាត់ភាពអសកម្មរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព។

ភាពជោគជ័យនៃការប្រែប្រួលនូវផ្នត់គំនិតសង្គមចំពោះអំពើពុករលួយ ការបង្កើនជំនឿ-ទំនុកចិត្តលើរាជរដ្ឋាភិបាលដែលមានលក្ខណៈរឹងមាំ មិនធាក់ថយក្រោយ ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ការបង្កើនចំណូលជាតិ ជាសមិទ្ធផលសំខាន់នៃយុទ្ធសាស្ត្របង្ការទប់ស្កាត់ដែលក្នុងនោះសកម្មភាពនៃវិធានការបង្ការទប់ស្កាត់ដែលអនុវត្តផ្ទាល់ដោយ អ.ប.ព. និងសហការជាមួយភាគីពាក់ព័ន្ធផ្តោតលើការដ្ឋានការងារចំនួន 10 ។



ចាប់ផ្តើមពីយុទ្ធនាការតេជោ១ ក្នុងឆ្នាំ២០១២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នសាមីដែលមានការផ្តល់សេវាសាធារណៈ (បច្ចុប្បន្នសរុបមានចំនួន 23) និង អ.ប.ព. បានសហការរៀបចំដាក់ចេញជា

បន្តបន្ទាប់នូវក្របខណ្ឌគតិយុត្តគ្រឹះនៃការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឱ្យមានតម្លាភាព លឿន សាមញ្ញ គឺ**ប្រកាសរួម-អន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ ការពិន័យ និងការលើកទឹកចិត្ត** ដែលបច្ចុប្បន្នប្រកាសរួមអន្តរក្រសួងដាក់ចេញ និងស្ថិតនៅជាធរមានសរុបចំនួន 157 ប្រកាស ក្នុងនោះ ប្រកាស ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់មានចំនួន 96 ប្រកាសរួម និងប្រកាសពាក់ព័ន្ធនឹងការបែងចែកការប្រមូលចំណូលមានចំនួន 61 ប្រកាស។ ប្រកាសរួម-អន្តរក្រសួងចែងច្បាស់ពីប្រភេទសេវា កម្រៃសេវា ពេលវេលានៃការផ្តល់សេវា ការប្រើប្រាស់បង្កាន់ដៃទទួលប្រាក់ផ្ទៃការ យន្តការផ្តល់សេវាដែលមានលក្ខណៈជាប្រកបចេញចូលតែមួយ ការទទួល និងដោះស្រាយពាក្យបណ្តឹង និងមានលក្ខណៈជាឯកសារស់ អនុវត្តបណ្តើរ កែសម្រួល-លុប-ដាក់ចេញថ្មីបណ្តើរ បត់បែនតាមការវិវឌ្ឍនៃសង្គម តម្រូវការសេវា និងយន្តការផ្តល់សេវាផ្សេងៗតាមភាពច្នៃប្រឌិតនៃក្រសួង-ស្ថាប័នសាមីផ្តល់សេវា ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាស្ថាប័នបង្គោលលើគោលនយោបាយហិរញ្ញវត្ថុជាតិ និងចូលរួមផ្តល់ធាតុចូលដោយ អ.ប.ព. លើទិដ្ឋភាពនៃការបង្ការទប់ស្កាត់អំពើពុករលួយ។

ការអនុវត្តប្រកាសរួមអន្តរក្រសួង ត្រូវបានទទួលស្គាល់ថាបានកៀរគរបង្កើនចំណូលថវិកា បង្ការនិងបង្កើនភាពងាយស្រួលក្នុងការធ្វើពុរកិច្ច (Ease of Doing Business) និងសម្រេចគោលដៅធ្វើឱ្យការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព ជាពិសេសក្រោយក្រសួង-ស្ថាប័នមានផ្តល់សេវាសាធារណៈជាច្រើនទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានវិវឌ្ឍរៀបចំការគ្រប់គ្រង និងផ្តល់សេវាតាមប្រព័ន្ធព័ត៌មានវិទ្យាជាមួយប្រព័ន្ធកត់ត្រាដែលអាចតាមដានបាន កាត់បន្ថយឱកាសប្រព្រឹត្តអំពើអសកម្ម បានធ្វើឱ្យការប្រគល់ទទួលសេវាកម្មបានទាន់ពេល មានភាពងាយស្រួល សាមញ្ញជាងមុនក្នុងទិសដៅសម្រេចបាននូវទិសស្មោកដាក់ចេញដោយ ***សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** "សេវាសាធារណៈល្អពស្ត្រស្រឡាញ់គាំទ្រ"។

ការផ្តល់សេវាតាមប្រព័ន្ធឌីជីថល



ប្រកាសរួម-អន្តរក្រសួង ពាក់ព័ន្ធការផ្តល់សេវាសាធារណៈ

ទិន្នន័យចំណូលពីការផ្តល់សេវាសាធារណៈ និងការផាកពិន័យ (ឯកតា៖ លានរៀល)



សរុបកំណើនចំណូលរយៈពេល ១៤ឆ្នាំ មាន 16,585,960 លានរៀល (៥ឆ្នាំ ចុងក្រោយ 6,500,687 លានរៀល)

*វិស័យឯកជន និង អ.ប.ព. បានផ្តួចផ្តើមចុះ**អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយ** (MOU) ក្នុងឆ្នាំ២០១៣ ដែលបច្ចុប្បន្នកើនដល់ចំនួន 106 MOU មានវិសាលភាពគ្របដណ្តប់លើក្រុមហ៊ុនជាង 1,000 ដែលមាន 16 សញ្ញាតិ ដោយវិស័យឯកជនធ្វើការអប់រំ ប្តេជ្ញាមិនប្រព្រឹត្តអំពើពុករលួយ និងរាយការណ៍អំពីអំពើពុករលួយមក អ.ប.ព. ករណីជួបប្រទះតាមរយៈជនបង្ហោលប្រឆាំងអំពើពុករលួយដែលមានចែងក្នុងខ្លឹមសារនៃ MOU និង អ.ប.ព. ទទួលពិនិត្យ និងដោះស្រាយៗកាតព្វកិច្ច និងការប្តេជ្ញាចិត្តរវាងភាគី បានបន្តប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ បង្កើតជាបរិយាកាសធុរកិច្ចស្អាតស្អំ និងដោះស្រាយកង្វល់វិស័យឯកជនជួបប្រទះយ៉ាងទាន់ពេលវេលាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់*

ជាគំរូផ្ទៃផ្កា ទាក់ទាញការចូលរួមជាភាគីជាមួយ អ.ប.ព. បន្ថែមជាបន្តបន្ទាប់។ វិស័យឯកជនក៏បានទាញយកខ្លឹមសារសៀវភៅណែនាំអំពីកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ធុរកិច្ចនៅកម្ពុជាដែលរៀបចំដោយ អ.ប.ព. និងវិស័យឯកជនទៅប្រើប្រាស់ និងអនុវត្តជាប្រយោជន៍ក្នុងការកសាងសុចរិតភាពផ្ទៃក្នុង និងប្រយុទ្ធប្រឆាំងអំពើពុករលួយផងដែរ។



ការវាយតម្លៃហានិភ័យនៃអំពើពុករលួយតាមវិស័យ បានក្លាយជានិន្នាការសកល ត្រូវបានប្រើដើម្បីកំណត់ឫសគល់នៃបញ្ហាពុករលួយក្នុងគោលដៅដាក់ចេញ និងអនុវត្តវិធានបង្ការទប់ស្កាត់អំពើពុករលួយសមស្រប។ ក្រោយវិបត្តិកូវីដ-១៩ ក្នុងឆ្នាំ២០២២ អង្គការសហប្រជាជាតិទទួលបន្ទុកបទល្មើសនិងគ្រឿងញៀន (UNODC) សហការជាមួយ អ.ប.ព. ក្រសួងសុខាភិបាល និងភាគីពាក់ព័ន្ធ បានផ្តើមដកពិសោធន៍រៀបចំសិក្ខាសាលាគំរូដំបូងគេ វាយតម្លៃហានិភ័យនៃការកើតភាពមិនប្រក្រតីក្នុងវិស័យសុខាភិបាល ដើម្បីជាមូលដ្ឋានបន្តទៅអនុវត្តនៅវិស័យផ្សេងៗទៀតនាពេលណាមួយដែលសមស្រប។

កន្ធងមករាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** បានជំរុញការពង្រឹងអភិបាលកិច្ចល្អក្នុងរដ្ឋបាលសាធារណៈ ដោយបានកសាង និងអនុវត្តលិខិតបទដ្ឋានគតិយុត្តជាច្រើន ដូចជា ក្រមសីលធម៌វិជ្ជាជីវៈ និងកំណត់អភិក្រមការងារទាំង៥ ដែលក្រសួង-ស្ថាប័ន អង្គភាពនានាប្រកាន់ខ្ជាប់យកជាមាគ៌ាខ្លឹមសារកសាងឯកសារ និងយន្តការពង្រឹងសុចរិតភាពផ្ទៃក្នុង បង្កើតឥរិយាបទការងារប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាពក្នុងចំណោមមន្ត្រីសាធារណៈ។ ការកសាងក្រមប្រតិបត្តិសម្រាប់មន្ត្រីសាធារណៈ បានក្លាយជាគោលដៅបន្តក្នុងកិច្ចការកសាងរដ្ឋបាលសាធារណៈស្អាតស្អំដោយក្រមប្រតិបត្តិសម្រាប់មន្ត្រីសាធារណៈ ជាលិខិតបទដ្ឋានគតិយុត្តមួយដែលបានកំណត់ពីវិធានអាកប្បកិរិយាឱ្យមន្ត្រីសាធារណៈត្រូវប្រតិបត្តិតាមក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន។ ក្រមប្រតិបត្តិចែងផ្តោតសំខាន់ទៅលើសកម្មភាពអ្វីដែលត្រូវធ្វើ និងសកម្មភាពដែលបានហាមឃាត់ ព្រមទាំងទណ្ឌកម្មចំពោះការមិនប្រតិបត្តិតាមក្រមប្រតិបត្តិនេះ ក្នុងគោលដៅធ្វើឱ្យមន្ត្រីសាធារណៈប្រកាន់នូវសុចរិតភាពអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ មានការទទួលខុសត្រូវខ្ពស់ គោរពវិជ្ជាជីវៈ ចៀសវាងទំនាស់

ផលប្រយោជន៍ និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ។ ដោយកិច្ចការនេះផ្សារភ្ជាប់យ៉ាងខ្លាំង និងជាគន្លឹះក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ អ.ប.ព. UNODC ក្រសួងមុខងារសាធារណៈ និងភាគីពាក់ព័ន្ធ បានរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ប្រមូលធាតុចូលលើប្រធានបទ និងក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាល បានប្រគល់ភារកិច្ចដ៏សំខាន់នេះជូនក្រសួងមុខងារសាធារណៈជាស្ថាប័នបង្គោលជាអ្នករៀបចំ ជានាការអនុវត្ត និងការតាមដានវាយតម្លៃក្រមប្រតិបត្តិ។ កិច្ចការបន្តលើការដ្ឋាននេះ រាជរដ្ឋាភិបាលបច្ចុប្បន្នដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានបញ្ជាក់យ៉ាងមុតមាំក្នុងស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ នៅមុំទី៣ ការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ ត្រង់អាទិភាពទី១ អំពីការរៀបចំ និងការដាក់ឱ្យអនុវត្តក្រមប្រតិបត្តិក្នុងមុខងារសាធារណៈ។ ក្រសួងមុខងារសាធារណៈ បាននិងកំពុងបន្តសិក្សារៀបចំលើកិច្ចការនេះ ហើយ អ.ប.ព. ក៏បានចាត់តាំងមន្ត្រីបង្គោលចូលរួមប្រជុំពិភាក្សាផ្តល់ជាតុចូលនានាក្នុងទស្សនៈវិស័យនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងរួមគ្នាជំរុញការសម្រេចចេញជាផ្ទៃផ្កាលើកិច្ចការនេះ។

ការប្រកាសទ្រព្យសម្បត្តិ និងបំណុល ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានកំណត់ពីសមាសភាពបុគ្គលដែលមានកាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ហើយនិងទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់អង្គភាពប្រឆាំងអំពើពុករលួយ។ ការប្រកាសទ្រព្យសម្បត្តិ និងបំណុល ជាការងារប្រវត្តិសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីការពារ និងទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ ហើយការប្រកាសទ្រព្យសម្បត្តិ និងបំណុលនេះ ក៏ត្រូវបានប្រើប្រាស់ដើម្បីប្រសិទ្ធភាព នៃការស៊ើបអង្កេតបទល្មើសលើសំណុំរឿងជាច្រើនផង និងចូលរួមដល់ការងារបង្ការ ទប់ស្កាត់ផ្សេងទៀត ដូចជា៖ (១)ប្រើជាឧបករណ៍ត្រួតពិនិត្យផ្ទៀងផ្ទាត់ ឬប្រៀបធៀបការប្រកាសទ្រព្យសម្បត្តិ និងបំណុលចុងក្រោយ ជាមួយនឹងការប្រកាសលើកដំបូង និងបន្តបន្ទាប់ដើម្បីស្រាវជ្រាវរកឱ្យឃើញនូវទ្រព្យសម្បត្តិ ដែលកើនឡើងដោយគ្មានមូលហេតុ និងមិនអាចបកស្រាយបាន ឬការទទួលមានបានទ្រព្យសម្បត្តិដោយខុសច្បាប់ ឬប្រើប្រាស់ជាប្រព័ន្ធតាមដានការប្រែប្រួលទ្រព្យសម្បត្តិរបស់មន្ត្រីរាជការ (២)ប្រើប្រាស់ជាកស្តុតាងដើម្បីធ្វើជាសក្ខីកម្មនៅក្នុងសវនាការតុលាការ (៣)ជួយការពារមន្ត្រីរាជការណាដែលចង់ទទួលមានបានដោយខុសច្បាប់ ឬការប្រព្រឹត្តមិនត្រឹមត្រូវ(៤)ជួយការពារមន្ត្រីស្ងួតត្រង់ពីការចោទប្រកាន់ដោយអយុត្តិធម៌ (៥)ជួយបំពាក់ស្មារតីច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈដល់មន្ត្រីរាជការទូទៅ (៦)ជួយលើកកម្ពស់សុចរិតភាព និងសេចក្តីថ្លៃថ្នូរដល់មន្ត្រីរាជការ និង (៧)ជួយកសាងមន្ត្រីរាជការឱ្យស្អាតស្អំ ស្មោះត្រង់ មានការទទួលខុសត្រូវ។

ការប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវបានអនុវត្តដោយជោគជ័យ និងប្រកបដោយការទទួលខុសត្រូវខ្ពស់។ ទិន្នន័យនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមការកំណត់របស់ច្បាប់តាមរបប ២ ឆ្នាំ ម្តង ទទួលតំណែងថ្មី លាឈប់/ចប់អាណត្តិ បញ្ឈប់ ឬចូលនិវត្តន៍ មានរហូតដល់ស្ទើរតែ ១០០%។

ការប្រកាសទ្រព្យសម្បត្តិ និងបំណុល អាចនឹងត្រូវពង្រីកវិសាលភាពទៅដល់គោលដៅផ្សេងៗទៀតតាមការកំណត់របស់ច្បាប់។

	ការងារបង្ការ ទប់ស្កាត់ពាក់ព័ន្ធនឹងការទទួលឯកសារ នៃការប្រកាសទ្រព្យសម្បត្តិ និងចំណូល											
បរិយាយ	**2011-2015**	**2016**	**2017**	**2018**	**2019**	**2020**	**2021**	**2022**	**2023**	**2024**	**2025**	**សរុប**
តាមការកំណត់	24,196	00	00	00	00	00	00	00	00	00	00	**24,196**
របប ២ឆ្នាំ	46,128	7,129	21,445	5,747	21,841	12,503	24,386	14,510	22,525	17,967	22,353	**216,534**
តែងតាំងថ្មី	13,899	1,977	8,367	8,173	5,141	2,989	1,835	7,689	3,740	3,502	827	**58,139**
លាឈប់	6,464	137	4,127	500	1,496	361	276	4,698	512	2,266	364	**21,201**
បញ្ឈប់ពីតំណែង	107	10	1,035	3,888	54	30	35	29	28	34	04	**5,254**
ចូលនិវត្តន៍	346	90	202	97	790	706	1,024	942	1,263	1,074	215	**6,749**
តម្រូវការស៊ើបអង្កេត	20	10	00	00	21	03	01	02	01	05	03	**66**

ការព្រមាន *ជាវិធានការបង្ការក្នុងកម្រិតក្តៅមួយ ដែល អ.ប.ព. ចេញលិខិតមានខ្លឹមសារព្រមានដល់មុខសញ្ញាចំៗដែលក្នុងដំណាក់កាលដំបូងខកខានមិនបានអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមានជាក់លាក់ក្នុងន័យក្រើនរំលឹកឱ្យកែប្រែ និងជំរុញការគោរពលិខិតបទដ្ឋាននានា ព្រមទាំងការប្រព្រឹត្តត្រឹមត្រូវតាមវិជ្ជាជីវៈ។ មុខសញ្ញាទទួលការព្រមាន ត្រូវបានបិទផ្សាយលិខិតព្រមាននៅសាមីអង្គភាពខ្លួន និងត្រូវធ្វើស្វ័យរបាយការណ៍មក អ.ប.ព. រាល់ 3 ខែម្តង ក្នុងរយៈពេលកំណត់ណាមួយ (ជាទូទៅរយៈពេល 1 ឆ្នាំ) អំពីការអនុវត្តការងារនៅក្រសួង-ស្ថាប័នខ្លួន និងការកិច្ចដទៃទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ដើម្បីជាការធ្វើស្វ័យឆ្ទុះបញ្ចាំង ហើយ អ.ប.ព. បន្តតាមដានពីការប្រព្រឹត្តរបស់មុខសញ្ញា ដើម្បីកំណត់នូវចំណាត់ការបន្ទាប់ (អ.ប.ព.ចុះអប់រំ ឱ្យមុខសញ្ញាបញ្ចប់-បន្តការធ្វើស្វ័យរបាយការណ៍ ទទួលការព្រមានជាថ្មី ឬតម្រូវអនុវត្តវិធានការអនុវត្តច្បាប់បង្ក្រាប)។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ មុខសញ្ញាជាច្រើនបានទទួលការព្រមាន និងក្រើនរំលឹកឱ្យកែប្រែនូវការអនុវត្តមិនត្រឹមត្រូវ។*





ក្នុងយុទ្ធសាស្ត្រទប់ស្កាត់ អ.ប.ព. ក៏បានផ្តោតលើការងារសង្កេតការណ៍ ដែលរួមមាន (១)ការប្រឡង (២)លទ្ធកម្មសាធារណៈ (៣)ការដេញថ្លៃនានា និងការប្រមូលចំណូលមិនមែនសារពើពន្ធ និង (៤)កិច្ចការកំណែទម្រង់ និងគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈផ្សេងៗ។

*កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) "អ្នកចេះគឺជាប់" ចេញដំណើរតាំងពីឆ្នាំ២០១៤ ក្នុងរាជរដ្ឋាភិបាលអាណត្តិទី៥ ដឹកនាំដោយ **សម្តេចតេជោ ហ៊ុន សែន** ដែលទទួលបានជោគជ័យជាប្រវត្តិសាស្ត្រ នៅតែបន្តរក្សាបានភាពជោគជ័យ ការគាំទ្រ និងសាទរពីគ្រប់មជ្ឈដ្ឋានឥតឋមថយ ដោយមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការបង្ហោលទទួលបំពេញកិច្ចការនេះជូនរាជរដ្ឋាភិបាល និងមានការសហការគាំទ្រយ៉ាងក្លៀវក្លាពីស្ថាប័នផ្សេងៗថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមាន អ.ប.ព. ចូលរួមសង្កេតការណ៍សរុប 11 លើក ដោយមានពង្រាយអ្នកសង្កេតការណ៍ស្ម័គ្រចិត្តក្នុងមួយលើកៗជាង 5,000 រូប នៅទូទាំងរាជធានី-ខេត្ត គ្រប់មណ្ឌលប្រឡង ហើយអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសុទ្ធតែបានចូលរួមវគ្គបណ្តុះបណ្តាលលើការងារសង្កេតការណ៍។ ចំណុចកត់សម្គាល់ គឺសន្ទុះទឹកចិត្តចូលរួមចំណែករបស់យុវជនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការពារយុត្តិធម៌ការប្រឡងមិនដែលថមថយ។ ជាទូទៅក្នុងរវាង ១០ឆ្នាំនេះ ក្នុងរយៈពេលដ៏ខ្លី អ.ប.ព. អាចជ្រើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្តបានគ្រប់ចំនួនកំណត់ (១ថ្ងៃ អ.ប.ព. អាចកៀរគរអ្នកសង្កេតការណ៍ស្ម័គ្រចិត្តបានជាង3ពាន់នាក់) ហើយអ្នកសង្កេតការណ៍ស្ម័គ្រចិត្តទាំងនោះបំពេញការងារដោយយកចិត្តទុកដាក់ និងសម្រេចការកិច្ចដែល អ.ប.ព. ប្រគល់ជូនបានយ៉ាងល្អ។*

បរិយាយ	2014		2015	2016	2017	2018	2019	2020	2021	2022	2023	2024
មន្ត្រី អ.ប.ព.	166	174	179	225	305	349	75	-	75	277	296	325
អ្នកសង្កេតការណ៍ស្ម័គ្រចិត្ត	2,549	3,101	5,023	5,676	4,578	5,267	-	-	-	2,897	3,040	2,514
អំពីការប្រឡង												
មណ្ឌល	154	117	150	157	178	196	202	-	204	221	227	230
បន្ទប់ប្រឡង	3,683	2,752	3,576	3,781	4,154	4,655	4,725	-	4,615	5,174	5,543	5,636
បេក្ខជនប្រឡង	91,393	60,611	84,930	93,752	103,112	115,268	117,043	-	114,187	128,134	137,412	137,047
លទ្ធផលប្រឡង												
%ជាប់	25.72%	17.94%	55.88%	62.18%	63.84%	67.07%	68.62%	*ជាប់ស្វ័យប្រវត្តិ*	65.65%	72.33%	72.89%	79.00%
និទ្ទេស A (នាក់)	11	-	108	405	424	408	443	-	1,753	1,049	1,673	2,216

ក្នុងអាណត្តិទី៥ និងទី៦ ក្រសួង-ស្ថាប័ននានាក៏បានដំណើរការប្រឡងជ្រើសរើសក្របខណ្ឌ ជ្រើសរើសនិស្សិតសុទ្ធតែបានលទ្ធផល និងគុណភាពខ្ពស់ដូចការប្រឡងបាក់ឌុបដែរៗ នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** បន្តជ្រោងទង់កំណែទម្រង់ពង្រឹងគុណភាពលើគ្រប់ការប្រឡង ក្រោមទិសស្លោក **"ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត"** ដោយចាប់ផ្តើមតាំងពីដើមអាណត្តិ ដាក់ចេញនូវការអនុវត្តនិយាមការថ្មីសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល មានក្រសួងមុខងារសាធារណៈដឹកនាំដោយ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី** ជាសេនាធិការដឹកនាំការអនុវត្តផ្ទាល់ រៀបចំគ្រប់ការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល ឈរលើគោលការណ៍ **គុណាធិប្បតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព** ដើម្បីជានាតម្លាភាព ឱកាស និងភាពយុត្តិធម៌ស្មើៗគ្នាដល់គ្រប់បេក្ខជនប្រឡងដោយចាំបាច់មាន អ.ប.ព. ចូលរួមសង្កេតការណ៍។ ៥ឆ្នាំ ចុងក្រោយ(២០២០-២០២៥) ក្នុងតួអង្គជាកញ្ចក់តម្លាភាព អ.ប.ព. បានចូលរួមសង្កេតការណ៍៖

ក). ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល សិស្សមន្ត្រី មន្ត្រីកិច្ចសន្យា សរុប 13 ក្រសួង-ស្ថាប័ន ស្មើនឹង30 លើក ក្នុងនោះការប្រឡងតាមនិយាមថ្មីចំនួន8 ក្រសួង-ស្ថាប័ន ស្មើនឹង17លើក សម្រាប់ការជ្រើសរើសមន្ត្រីរាជការ និងសិស្សមន្ត្រីសរុប4,179 រូប ក្នុងចំណោមបេក្ខជនពេញសិទ្ធិចូលរួមប្រឡង 115,030 រូប

ខ). ការប្រឡងប្រជែងជ្រើសរើសសិស្ស-និស្សិត នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈដូចជា (១)បណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា (២)គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល (បេក្ខជនចូលរៀន/បញ្ចប់ការសិក្សា) (៣)សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល(ចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេស/វេជ្ជបណ្ឌិតឯកទេស) (៤) គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសរុប 25 លើក។







*អ.ប.ព. ចូលរួមសង្កេតការណ៍ក្នុងលទ្ធកម្មសាធារណៈ សំដៅជានាឱ្យការប្រើប្រាស់ថវិកាជាតិ ចំគោលដៅចំណាយតិចមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយកិច្ចការនេះធ្វើក្នុងទម្រង់បែបចំហ និងសម្ងាត់នៅគ្រប់ដំណាក់កាលនៃលទ្ធកម្មសាធារណៈ។ អ.ប.ព. ក៏បានរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យលទ្ធកម្មសាធារណៈ ប្រមូលផ្តុំព័ត៌មានអង្គភាពលទ្ធកម្ម ព័ត៌មានក្រុមហ៊ុនចូលរួមកិច្ចលទ្ធកម្ម និងកំណត់សម្គាល់ផ្សេងៗដែលមាន ដើម្បីងាយស្រួលវិភាគ វាយតម្លៃ តាមដាន និងដាក់ចេញចំណាត់ការតាមការចាំបាច់។ នៅក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ **សុចរិតភាពក្នុងលទ្ធកម្មសាធារណៈ** បានក្លាយជាប្រធានបទក្តៅ ជាពិសេសដោយសារតម្រូវការនូវទំនិញយុទ្ធសាស្ត្របន្ទាន់ ហើយកម្ពុជាដាក់ចេញនូវវិធានការបុរេសកម្ម សំដៅជានាសុចរិតភាព តម្លាភាពការអនុវត្តចំណាយ ដោយ៖*

- ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានផ្ញើសារក្រើនរំលឹក និងដាស់តឿនជាថ្មី ឱ្យប្រកាន់ខ្ជាប់អភិក្រម "**ឆ្នុះកញ្ចក់ ដូតទឹក ដុសក្អែល ព្យាបាល វះកាត់**" ក្នុងការអនុវត្តការងារ និងការមិនលើកលែង ឬអត់ឱនចំពោះការប្រព្រឹត្តអំពើពុករលួយរបស់បុគ្គលណាម្នាក់ ។
- បានបង្កើតបន្ទាន់នូវក្រុមការងារចំពោះកិច្ចគ្រប់គ្រងការផ្គត់ផ្គង់ និងថ្លៃទំនិញយុទ្ធសាស្ត្រក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានភារកិច្ច កំណត់ប្រភេទទំនិញយុទ្ធសាស្ត្រ ពិនិត្យគុណភាព គ្រប់គ្រងថ្លៃទំនិញជានាឱ្យមាននិរន្តរភាពនៃការផ្គត់ផ្គង់ ដោយមានសមាសភាពចម្រុះជាថ្នាក់ដឹកនាំជាន់ខ្ពស់ពីគ្រប់អង្គភាពពាក់ព័ន្ធចូលរួម ព្រមនឹងយន្តការត្រួតពិនិត្យតាមដាន ដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈកំណត់ថា លទ្ធកម្មសាធារណៈជាកម្មវត្ថុនៃការធ្វើសវនកម្ម និងអធិការកិច្ចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ច ក្នុងនោះមានអង្គភាពប្រឆាំងអំពើពុករលួយផងដែរ និងមានការបំពេញបន្ថែមដោយកិច្ចសវនកម្មតាមច្បាប់កំណត់ និងការតម្រូវរក្សាកស្តុតាងសវនកម្មរយៈពេលយ៉ាងតិច ១០ឆ្នាំ។
- ក្នុងកិច្ចលទ្ធកម្មទូទៅនៅតាមអង្គភាពលទ្ធកម្ម អ.ប.ព. បានបន្តចូលរួមទប់ស្កាត់ភាពមិនប្រក្រតីដោយផ្ទាស់ប្តូរពីការចុះសង្កេតការណ៍ផ្ទាល់ ទៅជាការពិនិត្យឯកសារពាក់ព័ន្ធក្នុងដំណើរការកិច្ចលទ្ធកម្មស្វែងរកចំណុចកត់សម្គាល់ និងមានវិធានការដោះស្រាយករណីមានភាពមិនប្រក្រតី ឬពាក្យប្តឹងពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម។



ក្នុងការពង្រឹងតម្លាភាព ប្រសិទ្ធភាពនៃការប្រមូលចំណូល និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព អ.ប.ព. ក៏បានចូលរួមសង្កេតការណ៍បានចំនួន 59 លើក។

ក្រៅពីការងារសង្កេតការណ៍ខាងលើ អ.ប.ព. ចូលរួមសង្កេតការណ៍ផ្សេងទៀតតាមការចាំបាច់ ឬតាមការស្នើសុំរបស់ ក្រសួង-ស្ថាប័ន អង្គភាព សហគ្រាសសាធារណៈរបស់រដ្ឋ ដើម្បីបង្ហាញតម្លាភាព និង

គណនេយ្យភាព ដូចជាការធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា កម្មវិធីផ្តល់ដីការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព និងការគ្រប់គ្រងដីរដ្ឋជុំវិញតំបន់ទន្លេសាប និងការពារដែនជម្រកសត្វព្រៃព្រៃឡង់ផងដែរៗ

ការងារបង្ការ ទប់ស្កាត់								
បរិយាយ	**2011-2015**	**2016-2020**	**2021**	**2022**	**2023**	**2024**	**2025**	***សរុប***
ពង្រឹងប្រសិទ្ធភាព និងតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ								
ក្រសួង-ស្ថាប័ន ដែលដាក់ចេញប្រកាសរួមពាក់ព័ន្ធនឹងសេវាសាធារណៈ	22	15	4	3	2	8	5	**23**
ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ	24	27	1	3	3	5	4	**67**
ប្រកាសរួមស្តីពីការកែសម្រួលកម្រងសេវាសាធារណៈ	3	6	-	1	0	1	-	**11**
ប្រកាសរួមស្តីពីការពិន័យជាប្រាក់	-	5	5	1	3	2	-	**18**
ប្រកាសរួមស្តីពីការផ្តល់រង្វាន់លើកទឹកចិត្ត	15	27	5	1	0	6	3	**57**
ការចុះត្រួតពិនិត្យផ្ទាល់ការផ្តល់សេវាសាធារណៈ	*1 ថ្នាក់ក្រោមជាតិ*	*12 ថ្នាក់ជាតិ 38 ថ្នាក់ក្រោមជាតិ*	-	-	-	-	-	***12 ថ្នាក់ជាតិ 39 ថ្នាក់ក្រោមជាតិ***
ពង្រឹងកិច្ចការសង្កេតការណ៍តាមគោលដៅ								
សង្កេតការណ៍លើការអនុវត្តលទ្ធកម្មសាធារណៈ:តាមក្រសួង-ស្ថាប័ន (ស្ថាប័ន/លើក)	59/659	182/4,025	133/787	193/1,261	176/1,280	148/1,143	111/633	**451/9,788**
ការដេញថ្លៃវត្ថុតាងផលបទល្មើស និងអនុផលព្រៃឈើ(ខេត្ត/លើក)	14/23	6/10	-	1/1	-	-	-	***15 រាជធានីខេត្ត/ 34លើក***

ដំណើរការដេញថ្លៃដាយត្រី ដាយត្រីលេញ និងបង្គ់ង (ខេត្ត/លើក)	3/11	3/33	3/3	3/3	3/3	3/6	-	**3 រាជធានី ខេត្ត/ 59 លើក**
សង្កេតការណ៍លើដំណើរការ ប្រឡងក្របខណ្ឌមន្ត្រីរាជការតាម ក្រសួង-ស្ថាប័ន (ក្រសួង-ស្ថាប័ន/លើក)	15/22	15/58	6/7	6/10	8/10	11/22	4/6	**28 ក្រសួង-ស្ថាប័ន 135 លើក**
ការសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ								
មន្ត្រី អ.ប.ព. (រូប)	179	349	75	277	296	325	-	**349**
អ្នកសង្កេតការណ៍ស្ម័គ្រចិត្ត (រូប)	10,673	15,521	-	2,897	3,040	2,514	-	**34,645**
ការអារចុះ MOU ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយ								
វិស័យឯកជន	20	72	3	2	1	1	0	**99**
សមាគម-អង្គការ	0	3	0	0	0	0	0	**3**
សភាពាណិជ្ជកម្ម	1	1	0	0	0	0	0	**2**
តំបន់សេដ្ឋកិច្ចពិសេស	0	1	0	0	0	0	0	**1**
គ្រឹះស្ថានសាធារណៈ	1	0	0	0	0	0	0	**1**

២.៣. ការជាអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ និងកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ

២.៣.១. ការជាអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ

ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ជាវិធានការមួយដែលត្រូវបានកំណត់ក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលមានគោលដៅធ្វើឱ្យម្នាក់ៗមិនហ៊ានពុករលួយ។ វិធានការ រួមមាន ការកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីឱ្យជនល្មើសទទួលខុសត្រូវចំពោះមុខច្បាប់ និងរឹបអូសមកវិញនូវទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើស។ រយៈពេល១៥ ឆ្នាំ ចាប់តាំងពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានប្រកាសឱ្យប្រើកាលពីឆ្នាំ២០១០ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយសុទ្ធតែបានបញ្ចូលការអនុវត្តច្បាប់បង្ក្រាបអំពើពុករលួយជាផ្នែកដ៏សំខាន់មួយ នៃយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ។ ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ត្រូវបានយកមកអនុវត្តទន្ទឹមគ្នានឹងការអប់រំ និងបង្ការទប់ស្កាត់។ ចំពោះការវិវឌ្ឍនៃក្របខណ្ឌច្បាប់ ក្រៅពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បទល្មើសពុករលួយត្រូវបានចែងនៅក្នុងច្បាប់មួយចំនួនទៀត ដូចជាច្បាប់ស្តីពីការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងទ្រព្យរដ្ឋ ច្បាប់ស្តីពីលទ្ធកម្ម

សាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ដែលច្បាប់ទាំងនេះសុទ្ធតែបានប្រគល់សមត្ថកិច្ចផ្តាច់មុខជូន អ.ប.ព. ក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ។

តាមរយៈបទពិសោធន៍ និងការវិវត្តនៃសភាពការរយៈពេលកន្លងមក និងដើម្បីលើកកម្ពស់ការដោះស្រាយពាក្យប្តឹងដែល អ.ប.ព. ទទួលបានឱ្យមានគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព យន្តការទទួល និងដោះស្រាយពាក្យប្តឹង ត្រូវបានកែលម្អជាបន្តបន្ទាប់ ដោយទទួលបាននូវការវាយតម្លៃជាវិជ្ជមាន ពីម្ចាស់បណ្តឹង សាធារណជន និងភាគីពាក់ព័ន្ធ។ អ.ប.ព. បានខិតខំអនុវត្តការងារពង្រីកវិសាលភាពមធ្យោបាយទទួលពាក្យប្តឹងរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង រួមមាន ការបង្កើតទម្រង់ពាក្យប្តឹងនៅក្នុងគេហទំព័រ អ.ប.ព. ការបន្ថែមប្រអប់សំបុត្រតាមដងផ្លូវ និងនៅទូទាំង ២៥ រាជធានី-ខេត្ត ការទទួលពាក្យប្តឹងតាមបណ្តាញសង្គមនានា និងការសហការជាមួយប្រៃសណីយ៍កម្ពុជា ក្នុងការដាក់ដំណើរការប្រអប់សំបុត្រសនៅតាមសាខាប្រៃសណីយ៍កម្ពុជាតាមបណ្តា រាជធានីខេត្ត ដោយឥតគិតថ្លៃ។ បណ្តឹងដែលបានដាក់មក អ.ប.ព. មានទាំងបណ្តឹងចេញឈ្មោះ បណ្តឹងអនាមិក និងបណ្តឹងពាក់កណ្តាលអនាមិក។ ជាការកត់សម្គាល់ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រដំណាក់កាលទី៣ (២០២០-២០២៥) បណ្តឹងចេញឈ្មោះមានច្រើនរហូតដល់ 63.7% ដែលនេះបង្ហាញពីភាពជឿជាក់របស់ម្ចាស់បណ្តឹងលើ អ.ប.ព.។



ពាក្យប្តឹងដែលទទួលបានទាំងអស់អាចជាការប្តឹងទៅលើមន្ត្រីណាម្នាក់ ឬក្រុមណាមួយ រួមមានមន្ត្រីសាមញ្ញ មន្ត្រីតែងតាំងដោយប្រកាស មន្ត្រីតែងតាំងដោយអនុក្រឹត្យ មន្ត្រីតែងតាំងដោយព្រះរាជក្រឹត្យ និងរហូតដល់ថ្នាក់ដឹកនាំនៅតាមក្រសួង-ស្ថាប័ន ព្រមទាំងសង្គមស៊ីវិល និងបុគ្គលឯកជនមួយចំនួនផងដែរ

ហើយបណ្តឹងទាំងនេះ ត្រូវបានពិនិត្យដោះស្រាយតាមករណីជាក់ស្តែងនីមួយៗ ដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈ។



ជានីតិវិធីក្នុងការដោះស្រាយបណ្តឹង ក្រុមការងារពាក្យប្តឹងបានរៀបចំ និងសម្របសម្រួលកិច្ចប្រជុំដើម្បីពិនិត្យ និងដោះស្រាយពាក្យប្តឹងនៅ ក្នុងកិច្ចប្រជុំអាហារពេលព្រឹក (BM= Breakfast Meeting) ដែលចាប់ផ្តើមនៅរៀងរាល់ព្រឹកម៉ោង០៧:៣០ នាទី នៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ពិភាក្សា និងមានចំណាត់ការលើពាក្យប្តឹងដែលបានដាក់មកនៅមួយថ្ងៃមុន ហើយកិច្ចប្រជុំក៏មានការបើកទ្វាជូនដល់ម្ចាស់បណ្តឹង រួមទាំងមេធាវីរបស់ម្ចាស់បណ្តឹងចូលស្តាប់ការវិភាគ វែកញែក និងផ្តល់នូវជាតុចូលបន្ថែមពីករណីដែលត្រូវបានប្តឹង។ ការចូលរួមពិនិត្យ ពិភាក្សាផ្ទាល់នៃពាក្យបណ្តឹងពីសំណាក់ម្ចាស់បណ្តឹង បានបង្កើតឱ្យមានទំនុកចិត្ត ការសាទរ និងការគាំទ្រចំពោះ កិច្ចខំប្រឹងប្រែងធ្វើយតបបណ្តឹងរបស់ អ.ប.ព. ជាបន្តបន្ទាប់។ ក្នុងដំណើរការដោះស្រាយបណ្តឹង ការប្រមូលព័ត៌មាន និងស៊ើបអង្កេត ក៏ត្រូវបានអនុវត្តសម្រាប់ព័ត៌មានដែលទទួលបានទាំងប្រភពចំហ និងចារកម្ម ក្រោមគោលការណ៍តឹងរឹង និងមិនអាចដោះដូរបាន លើការរក្សាការសម្ងាត់នៃប្រភពក៏ដូចជាសាក្សី ទាំងនៅក្នុង អ.ប.ព. និងនៅក្រៅ ជាពិសេសនៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅតុលាការ។



ពាក្យប្តឹងដែលបានប្រជុំវិភាគរួច អាចជាពាក្យប្តឹងមិនពាក់ព័ន្ធបទល្មើសពុករលួយ ឬជាពាក្យប្តឹងពាក់ព័ន្ធបទល្មើសពុករលួយ។ ចំពោះពាក្យប្តឹងដែលពុំមានខ្លឹមសារគ្រប់គ្រាន់អាចចាត់ការបាន ឬពុំមានតម្រុយនៃអំពើពុករលួយ នឹងត្រូវរក្សាទុកតាមដានបន្ត ឬធ្វើលិខិតឆ្លើយតបមិនពាក់ព័ន្ធសមត្ថកិច្ច អ.ប.ព. ជូនទៅម្ចាស់បណ្តឹង ឬធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ចលើពាក្យប្តឹងនោះ។ ដោយឡែក ពាក្យប្តឹងដែលអាចពាក់ព័ន្ធនឹងបទល្មើសពុករលួយ មន្ត្រីទទួលពាក្យប្តឹង ឬក្រុមការងារជំនាញ នឹងបន្តការងារស្នើសុំការបំភ្លឺពីបុគ្គលពាក់ព័ន្ធ ការងារស្រាវជ្រាវប្រមូលព័ត៌មាន ការស៊ើបអង្កេត ការធ្វើកោសលវិច័យ និងការពិនិត្យលទ្ធភាពកសាងសំណុំរឿងបញ្ជូនទៅតុលាការ។





តាមរយៈបទពិសោធន៍នៃការអនុវត្តកន្លងមកបានបង្ហាញឱ្យឃើញថា ការប្រយុទ្ធប្រឆាំងអំពើពុករលួយមិនមែនអាស្រ័យតែទៅលើការកសាងសំណុំរឿងបញ្ជូនទៅតុលាការតែមួយមុខនោះទេ។ ដោយហេតុថាការកសាងសំណុំរឿងបញ្ជូនទៅតុលាការត្រូវការកស្តុតាងរឹងមាំ ត្រូវការជំនាញ និងពេលវេលាច្រើន ជាដើម។ ក្រៅពីការបញ្ជូនសំណុំរឿងទៅតុលាការ បណ្តឹងដែលមិនទាន់មាន ឬមិនអាចមាន ឬក៏មានកស្តុតាង ប៉ុន្តែកស្តុតាងត្រូវបានរលត់ និងមិនអាចយកមកប្រើប្រាស់ដើម្បីបញ្ជូនសំណុំរឿងទៅតុលាការបាន ត្រូវបានយកមកដោះស្រាយតាមរយៈកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ តាមបែបរដ្ឋបាល និងវិន័យ។ ការដោះស្រាយតាមយន្តការក្រសួង-ស្ថាប័ននេះ បានចូលរួមចំណែកដល់ការពង្រឹងភាពស្អាតស្អំនៅតាមស្ថាប័នសាធារណៈ ហើយបង្កើតបាននូវឥទ្ធិពលដុំព្រិល (Snowball Effect) ពង្រីកនូវលទ្ធផលដែលចង់បាន និងធ្វើឱ្យកំហុសដដែលៗមិនអាចកើតឡើងជាថ្មី និងមានការកែលម្អ កាត់បន្ថយភាពមិនប្រក្រតី និងឈានទៅលុបបំបាត់បញ្ហាដែលបានកើតឡើង។ កំណើនៃចំណាត់ការរដ្ឋបាល និងវិន័យ ដែលជាលទ្ធផលនៃកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រមទាំងជាមួយនឹងតម្រូវការ និងភាពចាំបាច់ក្នុងការរកឱ្យបាននូវកស្តុតាងឱ្យបានរឹងមាំ និងច្បាស់លាស់ ដែលជាទូទៅត្រូវការពេលវេលាបទពិសោធន៍ និងជំនាញវិជ្ជាជីវៈ គួបផ្សំគ្នាបង្កើតបាននូវការពន្យល់ចំពោះបាតុភាព ២ ខាងក្រោម៖

(១) សំណុំរឿងទៅតុលាការ មិនមានច្រើនលើសលប់

(២) សំណុំរឿងទៅតុលាការទទួលបានជោគជ័យ ១០០%។

ដើម្បីមានសមត្ថភាពក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ និងបទល្មើសពាក់ព័ន្ធ ដែលមានលក្ខណៈស្មុគស្មាញ និងមានការវិវឌ្ឍតាមបរិបទថ្មីនៃសម័យបច្ចេកវិទ្យា និងសកលភាវូបនីយកម្មនេះ មន្ត្រីរបស់ អ.ប.ព. ត្រូវបានបន្តពង្រឹង និងពង្រីកសមត្ថភាព និងជំនាញជាប្រចាំទាំងសមត្ថភាពប្រមូលព័ត៌មាន តាមដាន ចារកម្ម

កោសលវិច័យហិរញ្ញវត្ថុ និងកុំព្យូទ័រ បច្ចេកទេស ការវិភាគហិរញ្ញវត្ថុ និងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ ជាដើម។ ក្រៅពីជំនាញ និងសមត្ថភាពមន្ត្រីរបស់ អ.ប.ព. ត្រូវបានពង្រឹងវិន័យ និងមានកិច្ចខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ចប្រកបដោយការទទួលខុសត្រូវមនសិកា និងវិជ្ជាជីវៈខ្ពស់ ព្រមទាំងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ រហូតដល់អាចបំបែកសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញជាច្រើនយ៉ាងជោគជ័យ។

សមិទ្ធផលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០២០ - ២០២៥) លើការងារអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ								
បរិយាយ	**2011-2015**	**2016-2020**	**2021**	**2022**	**2023**	**2024**	**2025 (មិថុនា)**	**សរុប**
១. ប្រភពពាក្យប្តឹង								
ប្រអប់សំបុត្រស	1,870	1,288	182	183	163	184	101	**3,971**
ប្តឹងផ្ទាល់នៅអ.ប.ព.	1,156	1,170	206	217	255	313	146	**3,463**
E-mail	457	112	15	12	8	26	21	**651**
អ្នកបញ្ជូនសារ	344	127	-	-	5	2	-	**478**
Facebook	-	128	15	13	14	5	6	**181**
ទូរសព្ទ	80	52	-	-	1	-	-	**133**
ប្រៃសណីយ៍	42	50	6	5	0	9	10	**122**
សារព័ត៌មាន	-	7	-	2	5	4	3	**21**
Telegram	-	3	12	-	2	2	-	**19**
ទូរសារ	6	-	-	-	-	-	-	**6**
ACU Page	-	1	-	-	-	-	-	**1**
YouTube	-	-	1	-	-	-	-	**1**
២. តួលេខពាក្យប្តឹង								
សរុប	**3,955**	**2,938**	**437**	**432**	**453**	**545**	**287**	**9,047**
អនាមិក	1,922	1,148	171	156	138	147	90	**3,772**
ពាក់កណ្តាលអនាមិក	-	145	21	9	12	25	13	**225**
ចេញឈ្មោះ	2,033	1,645	245	267	303	373	184	**5,050**

៣. ពាក្យប្តឹងពាក់ព័ន្ធនឹងមុខសញ្ញា								
មន្ត្រីតែងតាំងដោយព្រះរាជក្រឹត្យ	18%	24.43%	33.64%	25.00%	26.27%	21.28%	22.99%	-
មន្ត្រីតែងតាំងដោយអនុក្រឹត្យ	14%	11.72%	10.07%	13.66%	11.92%	14.68%	11.15%	-
មន្ត្រីតែងតាំងដោយប្រកាស	31%	32.99%	42.79%	41.44%	43.71%	43.12%	39.02%	-
មន្ត្រីសាមញ្ញ	22%	20.77%	4.58%	7.41%	6.84%	5.69%	9.76%	-
បុគ្គលឯកជន	12%	8.84%	5.49%	7.41%	7.28%	11.93%	10.45%	-
ក្រុមហ៊ុនឯកជន	-	-	2.52%	3.47%	2.87%	2.20%	2.79%	-
សង្គមស៊ីវិល	2%	1.25%	0.92%	1.62%	1.10%	1.10%	3.84%	-
៤. ការធ្វើលិខិតព្រមានមន្ត្រីរាជការ								
លិខិតព្រមាន	478	72	5	14	25	20	1	**615**
៥. ចំណាត់ការលើពាក្យប្តឹង								
បញ្ជូនទៅតុលាការ	52	34	7	5	1	14	7	**120**
ស្រាវជ្រាវប្រមូលព័ត៌មាន	0	0	22	17	192	156	111	**498**
រក្សាទុក (ពុំមានតម្រុយពុករលួយ)	3,230	2,178	317	363	134	168	108	**6,498**
បញ្ចប់ក្រោយបំភ្លឺ	406	696	84	31	106	200	54	**1,577**
ផ្ទេរទៅសមត្ថកិច្ចពាក់ព័ន្ធ	267	30	7	16	20	7	7	**354**
៦. ប្រភេទបទល្មើស								
សេវាសាធារណៈ	301	316	79	61	65	59	29	**910**
ដេញថ្លៃ និងលទ្ធកម្ម	84	66	6	5	12	7	8	**188**
កិបកេងផលប្រយោជន៍រដ្ឋ/គៃបំបាត់	1,143	631	120	135	140	121	93	**2,383**
បទល្មើសផ្សេងៗ	2,427	1,885	232	231	236	358	157	**5,526**
៧. ចំនួនសំណុំរឿង និងជនសង្ស័យបញ្ជូនទៅតុលាការ								
សំណុំរឿង	52	34	7	5	1	14	7	**120**
បញ្ជូនជនសង្ស័យ	61	37	9	8	1	27	22	**165**
៨. ការបើកអូសផលនៃបទល្មើស								
សាលក្រម	2	7	5	3	1	7	-	**25**

២.៣.២. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

នៅក្នុងបរិការណ៍ ដែលពិភពលោកកំពុងតែវិឌ្ឍផ្លាស់ប្តូរ ក្នុងល្បឿនដ៏លឿន ជាពិសេសក្នុងស្ថានភាព បរិវត្តកម្មបច្ចេកវិទ្យា និងនវានុវត្តន៍ ដែលពោរពេញដោយថាមភាព និងបុរេសកម្មដូចបច្ចុប្បន្ននេះ ការប្រយុទ្ធប្រឆាំងអំពើពុករលួយមិនអាចធ្វើឡើងបានជោគជ័យ និងប្រកបដោយប្រសិទ្ធភាព ដោយអនុវត្តតាមទម្លាប់នៃអតិក្រមតាមលក្ខណៈបែបសាមញ្ញជារបៀបប្រពៃណីបានតទៅទៀតទេ។ ក្នុងន័យនេះ វាពិតណាស់ថា យើងទាំងអស់គ្នាត្រូវធ្វើការរួមគ្នាក្នុងកិច្ចប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហានៃអំពើពុករលួយជាសកល ដែលជាបញ្ហារួមរបស់យើងឱ្យកាន់តែខ្លាំងក្លាមោះមុត និងមានទម្ងន់ថែមទៀត ដោយត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងកម្រិតជាតិ កម្រិតតំបន់ និងអន្តរជាតិ។ ភាពចាំបាច់ និងសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនេះ ក៏ត្រូវបានចែងយ៉ាងច្បាស់ក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

ក្នុងក្របខណ្ឌនៃកិច្ចសហការជាតិ អ.ប.ព. ដែលជាស្ថាប័នបង្កើតក្នុងការដឹកនាំការងារប្រយុទ្ធប្រឆាំងអំពើពុករលួយរួមសហការជាមួយក្រុមជនបង្កើតប្រឆាំងអំពើពុករលួយ ក្រសួង-ស្ថាប័នសាធារណៈ វិស័យឯកជន សង្គមស៊ីវិល បានអនុវត្តការងារជាច្រើនក្នុងគោលដៅអប់រំ និងបង្ការទប់ស្កាត់អំពើពុករលួយតាមរយៈកិច្ចសហការក្នុងការបណ្តុះបណ្តាល ផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ការរៀបចំឧបករណ៍អប់រំពីអំពើពុករលួយ ការសង្កេតការណ៍ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្រងសេវាសាធារណៈ និងការចុះ MOU ជាដើម។ ចំពោះការអនុវត្តច្បាប់វិញ អ.ប.ព. ក៏បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងស្ថាប័នតុលាការ ក្នុងការចែករំលែកព័ត៌មាន និងការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជាបន្តបន្ទាប់។

ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ អ.ប.ព. ដែលជាស្ថាប័នបង្កើតរបស់កម្ពុជាក្នុងការប្រឆាំងអំពើពុករលួយ បានសហការ និងធ្វើការងារយ៉ាងសកម្មជាមួយដៃគូអន្តរជាតិ និងបានពង្រឹង និងពង្រីកភាពជាដៃគូរនេះជាបន្តបន្ទាប់ដោយទទួលបានលទ្ធផលជាទីមោទនៈ។

(1). ***ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC)៖*** *អ.ប.ព. គឺជាស្ថាប័នបង្កើតក្នុងការសម្របសម្រួលលើដំណើរការទទួលការត្រួតពិនិត្យការអនុវត្ត UNCAC ជុំទី២ នៅកម្ពុជា ដែលត្រូវត្រួតពិនិត្យដោយអ្នកជំនាញប្រទេសថៃ និងអេស្វាទីនី ដោយមានការផ្តល់ជំនួយរបស់អ្នកជំនាញ UN ហើយមូលបទដែលត្រូវត្រួតពិនិត្យគឺការបង្ការទប់ស្កាត់អំពើពុករលួយ និងការទាមទារមកវិញនូវទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើស។ ដំណើរការនេះមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមមាន ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងផ្នែកសិក្សាធិការ ដោយទទួលបានការសាទរពីភាគីពាក់ព័ន្ធ ការថ្លែងអំណរគុណពីអង្គការសហប្រជាជាតិ និងបានបញ្ចប់ដោយជោគជ័យនូវដំណើរការត្រួតពិនិត្យ*

ការអនុវត្ត UNCAC *ជុំទី២នៅកម្ពុជា។ ទន្ទឹមនឹងនេះតំណាង អ.ប.ព. ក្នុងនាមកម្ពុជា និងអង្គការសហប្រជាជាតិ បានទៅត្រួតពិនិត្យការអនុវត្ត* UNCAC *ជុំទី២ នៅប្រទេសគិរីបាស និងលីបង់វិញដែរ។ ក្នុងពេលដែលតំណាង អ.ប.ព. បានទៅត្រួតពិនិត្យការអនុវត្ត* UNCAC *ដល់ប្រទេសលីបង់នៅឆ្នាំ២០២៤ តំណាង អ.ប.ព. ត្រូវបាននាយករដ្ឋមន្ត្រីរបស់ប្រទេសលីបង់អនុញ្ញាតឱ្យចូលជួបពិភាក្សាការងារប្រឆាំងអំពើពុករលួយប្រកបដោយស្មារតីស្ថាបនា។ បច្ចុប្បន្នការត្រួតពិនិត្យការអនុវត្ត* UNCAC *ជុំទី២ នៅប្រទេសគិរីបាស និងលីបង់ ត្រូវបានបញ្ចប់ដោយជោគជ័យ។*

(2). ***ការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ:*** *កិច្ចការនេះមានលក្ខណៈនយោបាយផង និងបច្ចេកទេសផង ហើយក៏ជាកិច្ចការដែលមានវិសាលភាពធំ ចរិតលក្ខណៈស្មុគស្មាញ និងអន្តរវិស័យ។ កន្ទងមកកម្ពុជាបានចាត់ទុកកិច្ចការនេះជាការងារសំខាន់ ចាំបាច់ និងបន្ទាន់ ហើយប្រៀបធៀប* ML/FT/PF *ដូចជាសន្ទុះសេដ្ឋកិច្ច ដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុ។ ហេតុនេះ រាជរដ្ឋាភិបាល អ.ប.ព. ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធ តែងតែយកចិត្តទុកដាក់ និងខិតខំអនុវត្តការងារនេះតាមសមត្ថកិច្ច។ ធនាគារជាតិនៃកម្ពុជា* (NBC) *ដែលមានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា* (CFIU) *ជាសេនាធិការ បានដើរតួនាទីសំខាន់ជាមួយគ្រប់ភាគីពាក់ព័ន្ធអនុវត្តការកិច្ចរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងសកម្មភាពការងារដែលបានកំណត់ដោយក្រុមអាស៊ីប៉ាស៊ីហ្វិកប្រឆាំងការសម្អាតប្រាក់* (APG)។ *អ.ប.ព. ដែលជាសមាជិកសកម្មមួយក្នុងការងារនេះ បានចូលរួមគ្រប់បែបយ៉ាងតាមការដឹកនាំរបស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធមហាប្រល័យ។ ក្នុងនាមជាអាជ្ញាធរអនុវត្តច្បាប់ អ.ប.ព. បាន៖* (១). *រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងរបស់ខ្លួន និងរចនាសម្ព័ន្ធក្នុងអង្គភាព ដើម្បីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម* (២). *រៀបចំឱ្យមានការស៊ើបអង្កេតដំណាលគ្នា* (Parallel Investigation) (៣). *កែសម្រួលស្តង់ដារប្រតិបត្តិការ* (SOP) *ដើម្បីស្របតាមស្តង់ដាររបស់* FATF (៦). *បង្កើតការិយាល័យប្រឆាំងការសម្អាតប្រាក់ និង* (៥). *បានបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនជាបន្តបន្ទាប់អំពីការងារពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ ជាពិសេសការស៊ើបអង្កេតហិរញ្ញវត្ថុ និងការរឹបអូសផលនៃបទល្មើស។ ក្នុងនាមប្រធានក្រុមការងារអនុវត្តច្បាប់ អ.ប.ព. បាន៖* (១). *បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្របសម្រួលការអនុវត្តច្បាប់សម្រាប់ការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ដែលមានតំណាង អ.ប.ព. ជាប្រធានក្រុមការងារនេះ (ក្រុមការងារនេះ បានប្រជុំ និងដំណើរការបានយ៉ាងល្អ ហើយនឹងបន្តសម្របសម្រួលការងារការអនុវត្តច្បាប់សម្រាប់ការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ឱ្យកាន់តែល្អប្រសើរថែមទៀត) (២). ជួយឱ្យក្រសួង-ស្ថាប័នអនុវត្តច្បាប់រៀបចំ និងដាក់ឱ្យអនុវត្តនូវស្តង់ដារប្រតិបត្តិសម្រាប់ការស៊ើបអង្កេត* (SOP) *របស់ខ្លួន*

(៣). បានរៀបចំ និងសហការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំជាច្រើនពាក់ព័ន្ធ នឹងការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាលក្ខណៈអន្តរស្ថាប័ន និងជាមួយដៃគូអន្តរជាតិ ដើម្បីបង្កើនសមត្ថភាព ជំនាញ និងប្រសិទ្ធភាពក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា (៤). សម្របសម្រួល ការចែករំលែកព័ត៌មាន និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ដើម្បីធ្វើឱ្យការប្រឆាំងការសម្អាតប្រាក់នៅកម្ពុជាកាន់តែមានភាពប្រសើរឡើង។ សមិទ្ធផលជាទីមោទនៈ គឺមហាសន្និបាតរបស់ FATF បានសម្រេចដកកម្ពុជាចេញពីបញ្ជីប្រផេះនៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ ដោយមិនបានតម្រូវឱ្យកម្ពុជារាយការណ៍ពីវឌ្ឍនភាពការងារ AML/CFT/CPF បន្តទៀតទេ។ ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (International Cooperation Review Group-Joint Group (ICRG-JG)) បានរកឃើញថា កម្ពុជាមានប្រព័ន្ធការងារ និងយន្តការការងារដែលត្រូវបានកែលម្អ ហើយត្រូវបានត្រៀមរួចជាស្រេចសម្រាប់ការអនុវត្តការងារ AML/CFT/CPF ដើម្បីឱ្យមានទិន្នភាព ការអភិវឌ្ឍ និងពង្រឹងបន្ថែមនាពេលអនាគត។ បច្ចុប្បន្ន ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា រួមទាំង អ.ប.ព. កំពុងបន្តអនុវត្តការងារតាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីការពារប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកម្ពុជា តាមរយៈការបន្តបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ជាដើម។ លើសពីនេះ ក្រោមការសម្របសម្រួលរបស់ CFIU កម្ពុជាកំពុងធ្វើការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីកំណត់បាននូវវិស័យ និងបទល្មើសហានិភ័យ និងដាក់ចេញនូវយុទ្ធសាស្ត្រ ដើម្បីដោះស្រាយនូវបញ្ហាទាំងនោះឱ្យមានប្រសិទ្ធភាព។ អ.ប.ព. ក៏បានបន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រី និងធ្វើការស៊ើបអង្កេត និងកសាងសំណុំរឿងសម្អាតប្រាក់បញ្ជូនទៅតុលាការជាបន្តបន្ទាប់ផងដែរ។

(3). **បណ្តាញប្រតិបត្តិការសកលនៃអាជ្ញាធរអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ (GlobE Network)**ៈ អ.ប.ព. បានចូលជាសមាជិកនៃ GlobE Network នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៤ និងបានចូលរួមក្នុងកិច្ចប្រជុំពេញអង្គរបស់បណ្តាញ ចំនួន 2 លើកគឺ កិច្ចប្រជុំពេញអង្គលើកទី៥ នៅថ្ងៃទី ២៤-២៧ ខែកញ្ញា ឆ្នាំ ២០២៤ នៅទីក្រុងប៉េកាំង ប្រទេសចិន និងកិច្ចប្រជុំពេញអង្គលើកទី៦ នៅថ្ងៃទី ២០-២៣ ខែ ឧសភា ឆ្នាំ ២០២៦ នៅទីក្រុងបាគូ សាធារណរដ្ឋអាស៊ែបៃហ្សង់។ GlobE Network ជាបណ្តាញអាជ្ញាធរអនុវត្តច្បាប់ ដែលមានគោលដៅផ្តល់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងការទាមទារមកវិញនូវផលនៃបទល្មើសពុករលួយ។

(4). **អាស៊ាន-ផេក (ASEAN-PAC)**ៈ ក្រៅពីចូលរួមសកម្មភាពនានាក្នុងនាមជាសមាជិក អ.ប.ព បានធ្វើជាប្រធានប្តូរវេនក្នុងអាណត្តិឆ្នាំ ២០២២-២០២៣ និងបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន-ផេក លើកទី១៨ នៅថ្ងៃទី ២២-២៣ ខែ វិច្ឆិកា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ ដែលក្នុងកិច្ចប្រជុំនោះ ជាប្រវត្តិសាស្ត្រ ឯកសារសំខាន់ៗ បំផុតរបស់អាស៊ាន-ផេកចំនួន ០៣ ត្រូវបានអនុម័ត

និងចុះហត្ថលេខា មានដូចជាអនុស្សរណៈនៃការយោគយល់គ្នារបស់អាស៊ាន-ផេក (ASEAN-PAC MoU) *ឯកសារគោល* (Terms of Reference -TOR) *និងឯកសារផែនការសកម្មភាព ០៣ ឆ្នាំរបស់អាស៊ាន-ផេក ២០២៣-២០២៥។ ទន្ទឹមនោះ អ.ប.ព. ក៏បានផ្តួចផ្តើមរៀបចំកូនសៀវភៅអេឡិកត្រូនិកអាស៊ាន-ផេក* (ASEAN-PAC E-Booklet) *ហើយសៀវភៅនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន-ផេក លើកទី១៩ នៅប្រទេសឡាវ ដោយត្រូវបានដាក់បង្ហាញជាផ្លូវការក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន-ផេក លើកទី២០ ប្រទេសឥណ្ឌូនេស៊ី ហើយនៅឆ្នាំបន្ទាប់ អ.ប.ព. បានរៀបចំធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំលេខាធិការដ្ឋាន អាស៊ាន-ផេក លើកទី១៩ នៅថ្ងៃទី ១៦-១៧ ខែសីហា ឆ្នាំ២០២៣ នៅខេត្តសៀមរាបផងដែរ។*

(5). ***កិច្ចសហប្រតិបត្តិការត្រីភាគី (ACU កម្ពុជា, SIA ឡាវ និងNACC ថៃ)៖*** *អ.ប.ព. បានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំក្រុមការងារត្រីភាគី លើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយ រវាងអង្គភាពប្រឆាំងអំពើពុករលួយ នៃព្រះរាជាណាចក្រកម្ពុជា* (ACU) *អាជ្ញាធរអធិការកិច្ចរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ* (SIA) *និងគណៈកម្មការជាតិប្រឆាំងអំពើពុករលួយ នៃព្រះរាជាណាចក្រថៃ* (NACC) *ដែលត្រូវបានប្រារព្ធឡើងនៅថ្ងៃទី៣១ ខែ កក្កដា ដល់ ០១ ខែ សីហា ឆ្នាំ ២០២៤ នៅខេត្តសៀមរាប។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្រោមប្រធានបទ "ការអប់រំ និងការបង្ការទប់ស្កាត់អំពើពុករលួយនៅក្នុងការផ្តល់សេវាសាធារណៈ" ដោយផ្តោតលើការពិភាក្សា និងចែករំលែកនូវយុទ្ធសាស្ត្រទាក់ទងនឹងការអប់រំ និងការបង្ការ-ទប់ស្កាត់អំពើពុករលួយ ព្រមទាំងដើម្បីពិភាក្សារាល់បញ្ហាដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈ ការពង្រឹងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរបស់មន្ត្រី ដែលបម្រើការងារនៅតាមព្រំដែន និងការងារពាក់ព័ន្ធផ្សេងៗទៀត។*

(6). ***ការចុះអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការ៖*** *អ.ប.ព. បានចុះអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការបានចំនួន ៤ គឺជាមួយ គណៈកម្មការជាតិប្រឆាំងអំពើពុករលួយ* (NACC) *ថៃ គណៈកម្មការជាតិប្រឆាំងអំពើពុករលួយ* (ACC) *មីយ៉ាន់ម៉ា អាជ្ញាធរអធិការកិច្ចរដ្ឋឡាវ* (SIA) *និងជាមួយគណៈកម្មការជាតិអធិការកិច្ចរដ្ឋ* (NSC) *នៃសាធារណរដ្ឋប្រជាមានិតចិន។ កិច្ចសហប្រតិបត្តិការទ្វេភាគីនេះ ធ្វើឡើងក្នុងគោលបំណងលើកស្ទួយ និងបង្កើនកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចផ្លូវការរវាងគ្នា និងការផ្លាស់ប្តូរព័ត៌មានចំណេះដឹង និងបទពិសោធន៍លើមូលដ្ឋាននៃសមភាព ការគោរពគ្នា និងផ្តល់ផលប្រយោជន៍ជូនគ្នាទៅវិញទៅមក។ ដោយអនុវត្តតាមអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគីទាំងនេះ ចាប់ពីឆ្នាំ ២០២០ អ.ប.ព. បានទទួលដំណើរទស្សនកិច្ចជាផ្លូវការមកកាន់ព្រះរាជាណាចក្រកម្ពុជាចំនួន 5 លើក និងបានធ្វើដំណើរទស្សនកិច្ចជាផ្លូវការទៅក្រៅប្រទេសចំនួន 3 លើក។*

(7). ***កិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងៗទៀត៖*** *ក្រៅពីកិច្ចសហប្រតិបត្តិការអន្តរជាតិខាងលើ អ.ប.ព. បានអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងបានចូលរួមយ៉ាងសកម្មក្នុងវេទិកា និងកិច្ចប្រជុំនានាដែលរៀបចំដោយអង្គការអន្តរជាតិ ក្នុងនាមខ្លួនជាសមាជិក ដែលមានជាអាទិ៍៖ ចូលរួមកិច្ចប្រជុំ ADB/OECD, សន្និសីទ/កិច្ចប្រជុំ IAACA, កិច្ចប្រជុំ IACA កិច្ចប្រជុំ សន្និសីទ និងសិក្ខាសាលាជាច្រើនទៀតទាំងក្នុង និងក្រៅតំបន់លើឆាកអន្តរជាតិ។*

សកម្មភាពការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ (លើក)								
ប្រភេទ	**2011-2015**	**2016-2020**	**2021**	**2022**	**2023**	**2024**	**2025 ខែមិថុនា**	***សរុប***
កិច្ចប្រជុំអាស៊ានផេក ASEAN-PAC	10	10	2	2	2	2	1	**29**
កិច្ចប្រជុំ UNCAC	15	11	1	2	2	3	2	**36**
កិច្ចប្រជុំ ADB/OECD	5	5	1	-	1	1	-	**13**
សន្និសីទ/កិច្ចប្រជុំ IAACA	7	2	-	1	1	1	1	**13**
កិច្ចប្រជុំ IACA	3	5	1	1	1	1	2	**14**
កិច្ចប្រជុំ GlobE Network	-	-	-	-	-	1	1	**2**
Star-Interpol	5	1	1	-	-	-	-	**7**
ទទួលដំណើរទស្សនកិច្ច	3	4	-	-	2	3	2	**14**
ធ្វើដំណើរទស្សនកិច្ចក្រៅប្រទេស	3	3	-	-	1	2	-	**9**
កិច្ចប្រជុំ សន្និសីទសិក្ខាសាលាផ្សេងៗ	39	72	14	10	15	15	7	**172**
សរុប	90	113	**20**	**16**	**25**	**29**	**16**	**309**

បន្ថែមលើយន្តការខាងលើ អ.ប.ព. ក៏បានធ្វើការស្រាវជ្រាវប្រមូលព័ត៌មានតាមប្រភពចំហ និងអត្ថបទសារព័ត៌មានផងដែរ។ ក្នុងនោះ អ.ប.ព. បានធ្វើព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃ ចំនួន 9,007 ព្រឹត្តិបត្រ ដែលជាព័ត៌មានជាតិតាមបណ្តាក្រសួង-ស្ថាប័ន និងថ្នាក់ក្រោមជាតិ ចំនួន 6,231 អត្ថបទព័ត៌មានអន្តរជាតិ ចំនួន 2,776 ព័ត៌មាន។

ស្ថិតិព័ត៌មានជាតិ និងអន្តរជាតិ

ល.រ.	***បរិយាយ***	**2011-2015**	**2016-2020**	**2021**	**2022**	**2023**	**2024**	**2025 (មិថុនា)**	***សរុប***
១	*ព័ត៌មានជាតិ តាមបណ្តាក្រសួង-ស្ថាប័ន*	2,108	2,828	583	434	163	115	-	**6,231**

២	ព័ត៌មានអន្តរជាតិតាមបណ្តាប្រទេសផ្សេងៗ	451	465	409	330	708	878	-	**2,776**
សរុប		**2,559**	**3,293**	**992**	**764**	**871**	**993**	-	-

២.៤. អភិបាលកិច្ចផ្ទៃក្នុង(ក.វ.ត.ផ.)

ក្នុងបុព្វហេតុនៃភាពជោគជ័យនៃការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ និងប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា ការអនុវត្តការងារប្រកាន់ខ្ជាប់គោលការណ៍អភិបាលកិច្ចល្អរបស់ អ.ប.ព. ឈរលើអភិក្រមទាំង៥នៃការដឹកនាំ "ទុះកញ្ចក់ ជូតទឹក ដុសក្អែល ព្យាបាល និងវះកាត់" និងគោលនយោបាយ "ភាពស្អាតស្អំ ត្រូវតែកើតចេញពីស្ថាប័នសាមីនីមួយៗ" ជាបុរេលក្ខខណ្ឌដ៏សំខាន់នាំមកនូវការសម្រេចបានសមិទ្ធផលជាផ្ទៃផ្ការនៃយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយដែលបានដាក់ចេញទាំង ៣ អាណត្តិកន្លងមក។

ក្រុមប្រឹក្សាវិន័យ និងត្រួតពិនិត្យផ្ទៃក្នុងនៃ *អ.ប.ព. ហៅកាត់* ***ក.វ.ត.ផ.*** *ត្រូវបានបង្កើតនៅខែធ្នូ ឆ្នាំ២០១៤ និងបានកែសម្រួលតួនាទី-ភារកិច្ចនិងពង្រីកសមាសភាពបន្ថែមរហូតដល់ ១៣ រូប ក្នុងឆ្នាំ២០២៣ សហការជាមួយក្រុមស៊ើបអង្កេតផ្ទៃក្នុង ជាសេនាធិការដ៏មោះមុតទទួលបន្ទុកពង្រឹងវិន័យ សុចរិតភាព សាមគ្គីភាពផ្ទៃក្នុង និងគ្រប់គ្រងទំនាស់ផលប្រយោជន៍ ដើម្បីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងប្រតិបត្តិការការងាររបស់ អ.ប.ព. តាមរយៈការកសាង-ផ្សព្វផ្សាយបទប្បញ្ញត្តិពាក់ព័ន្ធអភិបាលកិច្ចផ្ទៃក្នុង ជំរុញ ពង្រឹង និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិទាំងនោះឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់។*

បទប្បញ្ញត្តិពាក់ព័ន្ធអភិបាលកិច្ចផ្ទៃក្នុងទាំងអស់ដែលបានដាក់ចេញ ត្រូវបានជានាថាបានផ្សព្វផ្សាយទៅដល់គ្រប់មន្ត្រី និងជាបន្តបន្ទាប់ដាស់ស្មារតីដូចភ្លៀងរលឹម តាមរយៈ (១).ការបង្ហោះផ្សព្វផ្សាយតាមប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុងអង្គភាពរួម តាមនាយកដ្ឋាន/ក្រុមការងារ (២).វគ្គបណ្តុះបណ្តាលតម្រង់ទិសសម្រាប់មន្ត្រីថ្មីដែលគ្រប់មន្ត្រីទើបចូលបម្រើការងារត្រូវចាំបាច់ឆ្លងកាត់ និងវគ្គរំលឹករៀបចំជារៀងរាល់ឆ្នាំ (៣).កិច្ចប្រជុំប្រចាំសប្តាហ៍-ខែតាមនាយកដ្ឋាន និងកិច្ចប្រជុំផ្សេងៗរបស់ អ.ប.ព.។ កម្រិតនៃការយល់ដឹងអំពីបទប្បញ្ញត្តិក៏ត្រូវបានស្ទាបស្ទង់ដោយមានការរៀបចំជាកម្រងសំណួរឱ្យមន្ត្រីបំពេញឆ្លើយតបផងដែរ។ យន្តការនិងចំណាត់ការផ្សេងៗ ត្រូវបានដាក់ចេញដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងការគោរពវិន័យផ្ទៃក្នុង

ដោយឈរលើគោលការណ៍តម្លាភាព និងការលើកទឹកចិត្ត-ការដាក់វិន័យតាមការប្រព្រឹត្តផ្ទាល់ខ្លួនដោយគ្មានលម្អៀង។ មន្ត្រី អ.ប.ព. មុនចូលបម្រើការងារទាំងអស់ត្រូវចុះកិច្ចសន្យាគោរពបទប្បញ្ញត្តិនិងវិន័យផ្ទៃក្នុង និងស្ម័គ្រចិត្តធ្វើតេស្តប៉ូលិក្រាហ្វតាមគោលការណ៍របស់អង្គភាព។ គ្រប់ថ្នាក់ដឹកនាំ និងមន្ត្រី អ.ប.ព. ទាំងអស់ត្រូវរាយការណ៍(ហាន:ចាប់ពីឧបការីឡើង) និង/ឬស្នើសុំការអនុញ្ញាត ក្នុងការទទួលបាយក្រៅ ទទួលបដិសណ្ឋារកិច្ច(ការកំសាន្ត ស្នាក់នៅ សេវាសុខភាព ការសិក្សា...) ទទួលអំណោយ និងទំនាស់ផលប្រយោជន៍ (ពាក់ព័ន្ធសំណុំរឿងស៊ើបអង្កេត, ការចូលរួមសង្កេតការណ៍ក្នុងដំណើរការដេញថ្លៃ ប្រឡងក្របខណ្ឌ ប្រឡងយកតួនាទី, ការចូលរួមជាគណៈកម្មការ ឬក្នុងក្រុមការងារនានា...) ទៅប្រធាន ក.វ.ត.ផ. និងប្រធាន អ.ប.ព. ដោយការរាយការណ៍ និង/ឬស្នើសុំការអនុញ្ញាត ការសម្រេច/ចំណាត់ការ ធ្វើឡើងដោយតម្លាភាពតាមប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុង អ.ប.ព. ដោយមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយឃ្លាំមើលតាមដានក្នុងនោះ និងត្រូវបានកត់ត្រារក្សាទុកយ៉ាងត្រឹមត្រូវ ដើម្បីជាមូលដ្ឋានតាមដាន និងវាយតម្លៃ។ ក.វ.ត.ផ. ក៏បានចូលរួមផ្តល់យោបល់លើការជ្រើសរើសមន្ត្រីកិច្ចសន្យា ចូលរួមពិនិត្យការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌ អ.ប.ព. ពិនិត្យវាយតម្លៃលើលទ្ធផលការតម្លើងថ្នាក់ ហានន្តរសក្តិ ផ្តល់គ្រឿងឥស្សរិយយសតួនាទីក្នុង អ.ប.ព.។ ក៏ដូចជាពិនិត្យ ដោះស្រាយសំណូមពរ ករណីល្មើសបទប្បញ្ញត្តិពាក់ព័ន្ធអកិបាលកិច្ចផ្ទៃក្នុង ករណីមានភាពមិនប្រក្រតីក្នុងការអនុវត្តតួនាទី-ការកិច្ចរបស់មន្ត្រីរាជការ អ.ប.ព. តាមព័ត៌មានទទួលបានពីក្រុមស៊ើបអង្កេតផ្ទៃក្នុង ប្រអប់សំបុត្រសដាក់តាមបន្ទប់ទឹក អ.ប.ព. និងប្រភពចំហ/សម្ងាត់ផ្សេងៗទៀត ដើម្បីរក្សាសេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ និងប្រសិទ្ធភាពប្រតិបត្តិការការងារ អ.ប.ព.។ ដោយគ្មានការលើកលែង អ.ប.ព. ក៏បានចាប់កសាងសំណុំរឿង និងបញ្ជូនមន្ត្រី អ.ប.ព. ដែលបានប្រព្រឹត្តអំពើពុករលួយទៅតុលាការចំនួន 2 ករណី ដើម្បីពង្រឹងភាពស្អាតស្អំផ្ទៃក្នុង។ ការបញ្ជូនទៅតុលាការករណីក្លែងហាន:ជាមន្ត្រី អ.ប.ព. និងឆបោកមានស្ថានទម្ងន់ទោស ដើម្បីទារប្រាក់ពីជនរងគ្រោះ ក៏ត្រូវបានបង្ក្រាបចំនួន 2 ករណីផងដែរ។

ការងារវិន័យ និងត្រួតពិនិត្យផ្ទៃក្នុង								
ល.រ	***បរិយាយ***		**2020**	**2021**	**2022**	**2023**	**2024**	***សរុប***
១	បណ្តុះបណ្តាលបទប្បញ្ញត្តិពាក់ព័ន្ធអកិបាលកិច្ចផ្ទៃក្នុង (មិនរាប់បញ្ចូលកិច្ចប្រជុំផ្សព្វផ្សាយផ្សេងៗដូចក្លៀងរលឹម)		9	-	1	5	1	**16**
២	ការប្រកាស/ស្នើសុំការអនុញ្ញាតនានា	ការស្នើសុំបាយក្រៅ (លើក)	47	-	139	64	48	**298**
		ការទទួលអំណោយ និងបដិសណ្ឋារកិច្ច (លើក)	10	-	18	17	17	**62**
៣	ការលើកទឹកចិត្ត និងដាក់វិន័យផ្ទៃក្នុង	ការប្រជុំវាយតម្លៃតែងតាំងស៊ប់(រូប)	0	3	74 (មិនបានតាំងស៊ប់1)	4	8	**89 (មិនបានតាំងស៊ប់1)**

		ការប្រជុំវាយតម្លៃផ្តល់គ្រឿងឥស្សរិយយស(រូប)	34	43	87	160	88	**412**
		ការប្រជុំវាយតម្លៃដំឡើងឋានន្តរសក្តិ និងថ្នាក់(រូប)	203 (បង្គក 1)	147	257 (បង្គក6)	150 (បង្គក 3)	235 (បង្គក 9)	**992 (បង្គក 19)**
៨	ការពិនិត្យដោះស្រាយសំណូមពរ និងពាក្យប្តឹងផ្ទៃក្នុង		6 (លុបក្របខណ្ឌ 2)	1	4	3	6	**20**
៩	កសាងសំណុំរឿងបញ្ជូនទៅតុលាការ	ករណីមន្ត្រី អ.ប.ព. ប្រព្រឹត្តអំពើពុករលួយ	-	-	1	-	1	**2**
		ករណីក្វែងឋាន:ជាមន្ត្រី អ.ប.ព. និងឆបោកមានស្ថានទម្ងន់	-	2	-	-	-	**2**

២.៤. ត្រួតពិនិត្យ និងវាយតម្លៃ និងការងារមិនចានអនុវត្ត

២.៤.១. ការងារត្រួតពិនិត្យ និងវាយតម្លៃ

ផ្អែកលើយុទ្ធសាស្ត្រ គោលការណ៍អភិបាលកិច្ចល្អ និងគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់ ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ (Monitoring and Evaluating Group-MEG) ត្រូវបានបង្កើតឡើងដែលមានសមាសភាពថ្នាក់ដឹកនាំ អ.ប.ព. និងមកពីនាយកដ្ឋាន និងក្រុមការងារពាក់ព័ន្ធនានា បានដើរតួនាទីដ៏សំខាន់លើកិច្ចការនេះ និងមានតួនាទី ភារកិច្ចក្នុងការត្រួតពិនិត្យ តាមដាន ផ្តល់អនុសាសន៍ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ សិក្ខាសៀងយល់ វិភាគ និងសំយោគនូវព័ត៌មាន ទិន្នន័យ ស្ថិតិ និងរបាយការណ៍អនុវត្តការងារ ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃនេះ នឹងជួយកំណត់បាននូវភាពជោគជ័យ ការអនុវត្តល្អៗ បញ្ហាប្រឈម និងមេរៀនទទួលបាន ដើម្បីកែលម្អផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយឱ្យកាន់តែល្អប្រសើរថែមទៀត ទាំងនៅក្នុងដំណាក់កាលរៀបចំ និងដំណើរការអនុវត្ត ។

យន្តការ និងវិធីសាស្ត្រនៃការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានក្រុមការងារ MEG តម្រូវឱ្យនាយកដ្ឋាន ក្រុមការងារ និងផ្នែកពាក់ព័ន្ធនានារៀបចំផែនការសកម្មភាពការងារប្រឆាំងអំពើពុករលួយរបស់ខ្លួនសម្រាប់អនុវត្ត អនុលោមតាមផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ និងធ្វើការរាស់ស្ទង់នូវកម្រិតប្រសិទ្ធភាព នៃការអនុវត្ត និង

លទ្ធផលនៃការអនុវត្តការងាររបស់ខ្លួនដែលបានកំណត់ជាសូចនាករជាក់លាក់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈរបាយការណ៍ការអនុវត្តការងាររបស់ខ្លួនប្រចាំខែ ឆមាស ប្រចាំឆ្នាំ និងរយៈពេល ៥ ឆ្នាំ ព្រមទាំងធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល។

លទ្ធផល នៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី១ រយៈពេល ៥ ឆ្នាំ (២០១១-២០១៥) ដែលមានសកម្មភាពគោល/សកម្មភាពចំនួន 81 និងដំណាក់កាលទី២ រយៈពេល ៥ ឆ្នាំ (២០១៥-២០២០) ដែលមានសកម្មភាពគោលចំនួន 40 និងសកម្មភាពចំនួន 70 និងដំណាក់កាលទី៣ រយៈពេល ៥ ឆ្នាំ (២០២០-២០២៥) កន្ទងមក ដែលមានសកម្មភាពគោលចំនួន 43 និងសកម្មភាពចំនួន 78 ទទួលបានលទ្ធផលដូចខាងក្រោម៖

ឆ្នាំ	សកម្មភាពគោល	សកម្មភាព	លទ្ធផល %	សកម្មភាពឥតគ្រោងទុក	នៅសល់ %
2011-2015	81	81	100	0	0
2015	37	57	78	0	0
2016	30	52	76	0	24
2017	36	68	79	32	21
2018	35	69	89.15	46	10.85
2019	40	70	94.04	32	5.96
2020	38	68	93.84	0	6.16
2021	37	76	88.11	4	11.89
2022	35	64	98.34	3	1.66
2023	35	60	99.84	2	0.16
2024	32	59	100	2	0
2025 (មករា-មិថុនា)	30	57	100	2	0

ដោយឡែក សម្រាប់លទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៣ (២០២០-២០២៥) រយៈពេល ៥ ឆ្នាំ កន្ទងមកនេះ នាយកដ្ឋានក្រុមការងារ និងផ្នែកពាក់ព័ន្ធនានា សម្រេចអនុវត្តបានទៅតាមផែនការដែលបានគ្រោងទុកចំនួន 97 % នៅសេសសល់ចំនួន 3% ទៀតប៉ុណ្ណោះ នឹងបន្តជាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ ដំណាក់កាលទី៤ (២០២៥-២០៣០) សម្រាប់អនុវត្តបន្ត។ លើសពីនេះ នៅមានផែនការឥតគ្រោងទុកចំនួន 2 សកម្មភាព ត្រូវបានអនុវត្តបន្ថែមទៀត ដូចខាងក្រោម ៖

2020	2021	2022	2023	2024	2025	សរុប %	ស.ឥតគ្រោងទុក
93.84	88.11	98.34	99.84	100	100	97	2

ការវាយតម្លៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៣ រយៈពេល ៥ ឆ្នាំ (២០២០-២០២៥) កន្ទងមក ទទួលបានលទ្ធផលល្អប្រសើរ ដោយសម្រេចបានតាមផែនការដែលបានគ្រោង

ទុកផង និងផែនការឥតគ្រោងទុកមួយចំនួនតូចបន្ថែមទៀត។ លទ្ធផលខាងលើនេះ បានឆ្លុះបញ្ចាំងឱ្យ ឃើញអំពីការយកចិត្តទុកដាក់ខ្ពស់របស់នាយកដ្ឋាន ក្រុមការងារ និងផ្នែកពាក់ព័ន្ធនានា ដែលបានខិតខំ ប្រឹងប្រែងអនុវត្តការងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងវិជ្ជាជីវៈខ្ពស់ជាពិសេសលើការងារ អប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសពុករលួយ ហើយក៏មានការចូលរួមសហការពីសំណាក់អាជ្ញាធរ និងក្រសួង-ស្ថាប័នគ្រប់លំដាប់ថ្នាក់ផងដែរ។

២.៥.២. ការងារមិនទាន់ចានអនុវត្ត

សមិទ្ធផលសំខាន់ៗដូចបានរៀបរាប់ខាងលើ ត្រូវបានអនុវត្តស្របទៅតាមផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៣ (២០២០-២០២៥) ដែលមានសកម្មភាពគោលចំនួន 43 និងសកម្មភាពចំនួន 78 ទៅតាម ផែនការដែលបានគ្រោងទុក និងដោយមានការតម្រង់ទិសពីសំណាក់ ក.ជ.ប.ព. ផង សម្រេចបានលទ្ធផល សរុបចំនួន 96%។ ទន្ទឹមនោះ នៅមានសកម្មភាពការងារនៃផែនការយុទ្ធសាស្ត្រមួយចំនួនតូចដែលអនុវត្ត បានមួយចំនួនហើយប៉ុន្តែនៅមិនទាន់បានពេញលេញប្រមាណ 4% នៅសល់ដែលមិនទាន់បានអនុវត្តចប់ សព្វគ្រប់ ហើយចាំបាច់ត្រូវបន្តការអនុវត្តដោយដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំង អំពើពុករលួយ ដំណាក់កាលទី៤ (២០២៥-២០៣០) នេះ។ សកម្មភាពទាំងនោះរួមមាន៖

១. ការពង្រីកវិសាលភាពនៃអង្គភាពប្រឆាំងអំពើពុករលួយ
២. ការងារពង្រីកវិសាលភាពគោលដៅដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល
៣. ការជំរុញក្រសួង-ស្ថាប័នសាធារណៈ និងវិស័យឯកជនឱ្យមានកម្មវិធី ឬផែនការសកម្មភាព ប្រឆាំងអំពើពុករលួយ យន្តការការងារអនុវត្តផែនការសកម្មភាព និងយន្តការតាមដាន និងវាយ តម្លៃការអនុវត្តផែនការសកម្មភាពទាំងនោះ
៤. ការបង្កើត និងការអនុវត្តប្រព័ន្ធសម្រាប់ផ្តល់ចំណាត់ថ្នាក់ទំនាស់ផលប្រយោជន៍ និងការធ្វើសុចរិត ភាពនៅតាមក្រសួង-ស្ថាប័នសាធារណៈ និងវិស័យឯកជន។

២.៦. កត្តាជោគជ័យ-បញ្ហាប្រឈម-មេរៀនឧទ្ធរណ៍

២.៦.១. កត្តាជោគជ័យ

កត្តាជោគជ័យដែលត្រូវបានរំលេចឡើងក្នុងផែនការយុទ្ធសាស្ត្រ ដំណាក់កាលទី៣ (២០២០-២០២៥) នៅតែជាគន្លឹះនាំមកនូវលទ្ធផលវិជ្ជមានក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ កត្តាទាំងនេះរួមមាន៖

១. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់៖ ពីយុទ្ធសាស្ត្រចតុកោណ ច្បាប់ប្រឆាំងអំពើពុករលួយដល់ ការគ្រប់គ្រង និងប្រតិបត្តិការរបស់ អ.ប.ព. ជាមួយធនធានថវិកាគ្រប់គ្រាន់ដោយឯករាជ្យ និងគ្មាន ការជ្រៀតជ្រែក
២. ការចូលរួមពីគ្រប់មជ្ឈដ្ឋាន៖ គ្រប់ផ្នែក គ្រប់វិស័យ គ្រប់ការដ្ឋាន (អប់រំ-បង្ការទប់ស្កាត់) ទាំងកម្រិត ជាតិ និងអន្តរជាតិ

៣. ការដឹកនាំ និងការគ្រប់គ្រង៖ ប្រសិទ្ធភាព នៃការបំពេញតួនាទីជាអ្នកពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ ក.ជ.ប.ព. ក៏ដូចជាការដឹកនាំដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈពីសំណាក់ថ្នាក់ដឹកនាំ អ.ប.ព.

៤. ការវិវឌ្ឍកម្រិតជាតិ និងអន្តរជាតិ៖ ពីកម្មវិធីកំណែទម្រង់របស់រដ្ឋជាបន្តបន្ទាប់ ដល់ចលនាប្រឆាំងអំពើពុករលួយ ដែលមាន UNCAC ជានិមិត្តរូប។

*៥. ការពង្រឹងធនៈនយោបាយពីសំណាក់ប្រមុខរាជរដ្ឋាភិបាល៖ ដើម្បីជានាទូរអភិបាលកិច្ចល្អក្នុងការដឹកនាំ និងគ្រប់គ្រងស្ថាប័នស្របតាមអភិក្រមទាំង៥ ដែលបានកំណត់ "**ទ្រុះកញ្ចក់ ផ្លូតទឹក ជុសភ្លែ ព្យាបាល និងវះកាត់**" ។ អភិក្រមទាំង ៥ បានដើរតួជាត្រីវិស័យសម្រាប់បង្ហាញផ្លូវដល់មន្ត្រីរាជការទូទៅក្នុងការបំពេញតួនាទីការកិច្ច និងការរស់នៅប្រកបដោយសីលធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវ។*

៦. ការឆ្លើយតបបានកាន់តែប្រសើរចំពោះគោលនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយរបស់រដ្ឋពីសំណាក់ប្រមុខស្ថាប័នសាធារណៈ ៖ តាមរយៈកំណែទម្រង់ផ្ទៃក្នុងស្ថាប័នជាបន្តបន្ទាប់ក៏ដូចជាការសហការបានកាន់តែមានប្រសិទ្ធភាពជាមួយ អ.ប.ព. ទាំងលើការងារអប់រំ បង្ការ ទប់ស្កាត់ និងការអនុវត្តច្បាប់បង្ក្រាប។

៧. ធនធានមនុស្សរបស់ អ.ប.ព. ត្រូវបានពង្រឹង និងពង្រីក៖ ទាំងបរិមាណ និងគុណភាពជំនាញ។

កត្តាជោគជ័យទាំងនេះ ក៏ត្រូវបានបំពេញបន្ថែមដោយការវិវឌ្ឍប្រកបដោយភាពវិជ្ជមាន និងអំណោយផលជាបន្តបន្ទាប់ដល់បុព្វហេតុប្រឆាំងអំពើពុករលួយមានជាអាទិ៍៖

១. ការសម្រួចកិច្ចសហប្រតិបត្តិការរវាងស្ថាប័នសាធារណៈ ពាក់ព័ន្ធនឹង អ.ប.ព. លើមូលបទការងារជាក់លាក់៖ កិច្ចប្រឹងប្រែងរួមគ្នាក្រោមស្មារតីផ្តុំកម្លាំងគ្នា ដើម្បីប្រសិទ្ធភាពការងារកំណែទម្រង់រដ្ឋលើការងារមួយចំនួនដូចជា ការទប់ស្កាត់ និងបង្ក្រាបបទល្មើសរ៉ែ ទន្ទ្រានព្រៃលិចទឹកបឹងទន្លេសាប ការបង្កើនការប្រមូលចំណូលចូលរដ្ឋ ការសន្សំចំណាយ ការងារកំណែទម្រង់យុត្តិធម៌ និងតុលាការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសលើការប្រឡងនានា។

២. យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៣-២០២៨)៖ ជាមួយនឹងការកំណត់កម្មវិធីគោលនយោបាយកាន់តែមហិច្ឆតាពីសំណាក់ប្រមុខរាជរដ្ឋាភិបាលអាណត្តិទី៧ កិច្ចប្រឹងប្រែងពហុវិស័យត្រូវបានពង្រឹងពង្រីក និងដាក់ចេញថ្មី ដើម្បីឆ្លើយតបទៅនឹងគោលដៅដែលបានដាក់ចេញឆ្ពោះទៅឆ្នាំ២០៣០ និង២០៥០ ក៏ដូចជាជម្នះនៅវាល់បញ្ហាប្រឈម កើតចេញពីភាពមិននឹងនរ វិបត្តិសេដ្ឋកិច្ចសកល។ ល្បឿនសន្ទុះ និងកម្លាំងថ្មី ដែលពោរពេញដោយថាមពល និងភាពក្លៀវក្លា បានជំរុញដល់ការងារកំណែទម្រង់អភិបាលកិច្ចល្អ ចោះបង់ទម្លាប់មិនល្អ ចាប់យកទម្លាប់ថ្មី និងទំនើបកម្មការងារនានា ដែលបានចូលរួមលុបបំបាត់ទប់ស្កាត់ និងដោះស្រាយបញ្ហាសង្គមនានា រួមទាំងការងារប្រយុទ្ធ

ប្រឆាំងអំពើពុករលួយ។ ប្រសិទ្ធភាពនៃអ្នកដឹកនាំថ្មី ត្រូវបានជ្រោមជ្រែងដោយអ្នកដឹកនាំមុន ក្រោមទិសស្លោកចាស់ **"ក្មេងមានកម្លាំង ចាស់ស្គាល់ផ្លូវ"** កែសម្រួលជា **"ក្មេងមានកម្លាំង ស្គាល់ផ្លូវ និងចាស់មានបទពិសោធន៍"**។

២.៦.២. បញ្ហាប្រឈម

បញ្ហាប្រឈមមួយចំនួនដែលត្រូវបានរំលេចឡើងនៅក្នុងផែនការយុទ្ធសាស្ត្រ ដំណាក់កាលទី៣ (២០២០-២០២៥) បន្តនៅជាឧបសគ្គ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ បញ្ហាប្រឈមទាំងនេះរួមមាន៖

១. ការផ្លាស់ប្តូរគំនិត ទស្សន: និងទម្លាប់៖ ការប្តូរគំនិត ទស្សន: និងទម្លាប់របស់សង្គម ត្រូវការពេលវេលា និងការចូលរួម។

២. ការអនុវត្ត និងរៀនសូត្របណ្តើរ កសាងកម្លាំង និងសមត្ថភាពបណ្តើរ៖ តម្រូវការនៃការបំពាក់បំប៉នសមត្ថភាពជំនាញជាប្រចាំ និងភាពយឺតយ៉ាវនៃការពង្រីកវិសាលភាពតាម រាជធានី-ខេត្ត។

៣. ក្របខណ្ឌច្បាប់ នីតិវិធី និងយន្តការពាក់ព័ន្ធ៖ ការអនុវត្តអនុសាសន៍ទទួលបានពីការត្រួតពិនិត្យឡើងវិញនៅមិនទាន់បានធ្វើយតបតាមតម្រូវការ ទាំងលើការការពារសាក្សី និងបុគ្គលរាយការណ៍ការរឹបអូសផលនៃបទល្មើស និងការផ្តល់ និងការទទួលជំនួយផ្នែកច្បាប់ទៅវិញទៅមកជាដើម។

៤. ការងារប្រឆាំងអំពើពុករលួយត្រូវចូលរួមធ្វើឱ្យបានព្រមគ្នា៖ តម្រូវការនៃការចូលរួមឱ្យបាន និងបានព្រមគ្នាបន្ថែមទៀតពីសំណាក់វិស័យសាធារណៈ និងវិស័យឯកជន។

៥. ការសម្របសម្រួលអន្តរស្ថាប័ន៖ បើទោះបីជាមានភាពវិជ្ជមាន និងរលូនច្រើនហើយក៏ដោយក៏ចាំបាច់ត្រូវការពង្រឹង និងការយល់ដឹងឱ្យបានព្រមគ្នាបន្ថែមទៀត ទាំងផ្នែកស្ថាប័នសាធារណៈ និងស្ថាប័នតុលាការ ជាពិសេសលើការងារអាទិភាពថ្មីៗ ដូចជាការប្រឆាំងការសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើសជាដើម។ ការផ្គុំកម្លាំងឱ្យបានរឹងមាំ និងស៊ីចង្វាក់គ្នា នឹងជួយបង្កើនល្បឿន និងប្រសិទ្ធភាពក្នុងការប្រឆាំងអំពើពុករលួយ។

៦. ធនធានជំនាញ៖ ការងារជំនាញ ដូចជាការវិភាគឯកសារហិរញ្ញវត្ថុ ការធ្វើកោសលវិច័យកុំព្យូទ័រ និងគណនេយ្យនៅមានកម្រិត ជាពិសេសនៅពេលប្រតិបត្តិការលើសំណុំរឿង ដែលស្មុគស្មាញ និងឆ្លងដែន។

៧. កិច្ចសហប្រតិបត្តិការអន្តរជាតិ៖ ទោះបីជា អ.ប.ព. មានបទពិសោធន៍ល្អមួយចំនួនក្នុងកិច្ចសហការជាមួយសមភាគីបរទេសក៏ដោយ ក៏ការងារនេះនៅតែជាការប្រជែងមួយដែលតម្រូវឱ្យមានការកសាងបន្ថែម ចំណេះដឹង ចំណេះធ្វើ និងការពង្រីកទូទំនាក់ទំនងទាំងទ្វេ និងពហុភាគីឱ្យបានច្រើនថែមទៀតតាមដែលអាចធ្វើទៅបាន។

បន្ថែមពីលើបញ្ហាប្រឈមដែលត្រូវបានកត់សម្គាល់ខាងលើ ការងារប្រឆាំងអំពើពុករលួយនាពេលកន្លងមកក៏ពើបប្រឈមជាមួយនឹងបញ្ហាមានជាអាទិ៍៖

១. ការងារនៅតែថ្មី បន្ទាន់ មមាញឹក៖ ត្រង់នេះអាចនិយាយបានថាជាបញ្ហាប្រឈមផង ជាកាលានុវត្តភាពផងក៏បាន ព្រោះថ្មី បន្ទាន់ មមាញឹក តម្រូវឱ្យដើរខ្លះ រត់ច្រើនតែក៏ផ្តល់នូវឱកាសពង្រីក និងដុសខាត់ចំណេះជំនាញបន្ថែម។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រឈមនឹងស្ថានភាពបែបនេះក៏អាចពន្យឺត និងបង្វែរការយកចិត្តទុកដាក់លើការងារគន្លឹះៗផ្សេងទៀតផងដែរ។

២. ការវិវឌ្ឍដ៏មហាលឿននូវបច្ចេកវិទ្យា ការចាប់ផ្តើមនូវជួរកាលបញ្ញាសិប្បនិម្មិត (AI) របស់មនុស្សជាតិ៖ ដូចគ្នាដែរបច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត (AI) អាចជាបញ្ហាប្រឈមផង និងកាលានុវត្តភាពផង ដោយចាំបាច់តម្រូវឱ្យអាជ្ញាធរអនុវត្តច្បាប់ជំរុញការវិវឌ្ឍខ្លួន ទាំងការបំពាក់នូវឧបករណ៍ទំនើបៗ និងបន្ថែមជំនាញថ្មីៗដើម្បីដើរឱ្យទាន់សភាពការ និងការវិវឌ្ឍនៃបទល្មើស។

២.៦.៣. មេរៀនឧទ្ធូលចាន

មេរៀនទទួលបានទាំង ៧ ដែលបានរំលេចឡើងក្នុងផែនការយុទ្ធសាស្ត្រ ដំណាក់កាលទី៣ (២០២០-២០២៥) ក៏នៅបន្តសមស្របក្នុងការប្រឆាំងអំពើពុករលួយ។ មេរៀនទាំងនេះរួមមាន៖

១.គោលនយោបាយ និងផែនការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលជាបុរេលក្ខណៈ៖ ពីធន្ទៈនយោបាយដល់ផែនទីបង្ហាញផ្លូវ តម្រង់ទិសប្រឆាំងអំពើពុករលួយ ដាក់ចេញដោយរាជរដ្ឋាភិបាល។

២.កំណែទម្រង់រដ្ឋផ្តល់ផលវិជ្ជមានដល់ការងារប្រឆាំងអំពើពុករលួយ៖ កំណែទម្រង់ទាំងនេះបានដើរតួដូចជាក្បាលរថភ្លើងដែលមានកម្លាំងអូសទាញ និងជំរុញបាននូវកំណែទម្រង់តាមវិស័យ និងតាមក្រសួង-ស្ថាប័នឱ្យនាំមកនូវផ្លែផ្កា ក្នុងទ្រង់ទ្រាយធំប្រកបដោយសង្គតិភាព និងចីរភាពយូរអង្វែង។

៣.ការចូលរួមជាកត្តាចាំបាច់សម្រាប់នាំមកនូវជោគជ័យ៖ កម្រិត និងប្រសិទ្ធភាព នៃការចូលរួមបានមកទាំងដោយការកៀរគរ និងដោយការស្ម័គ្រចិត្ត និងកំណត់នូវភាពជោគជ័យក្នុងការប្រឆាំងអំពើពុករលួយ។

៤. វិធានការបង្ការទប់ស្កាត់ជាមុន៖ ចំណាយតិច តែចំណេញច្រើន។

៥.ការពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ៖ ចាំបាច់សម្រាប់ការរាស់ស្ទង់កម្រិតជោគជ័យ បញ្ហាប្រឈម និងដកស្រង់មេរៀន និងបទពិសោធន៍ល្អៗសម្រាប់ការងារទៅមុខ។

៦.ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយដើរតួនាទីសំខាន់ក្នុងការកសាងស្ថាប័នស្អាតស្អំ៖ កិច្ចសហការដែលក្រុមជនបង្គោលប្រឆាំងអំពើពុករលួយបានផ្តល់ការចូលរួមចំណែកដល់ការលុបបំបាត់កំហុសជដែលៗ ការបិទឱកាសពុករលួយ ការកសាងបរិយាកាសអំណោយផលដល់ការពង្រឹងសុចរិតភាពនៅតាមស្ថាប័ន។ ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ គឺជាសក្ខីភាពនៃសារសំខាន់ក្នុងការរួបរួមគ្នាក្នុងបុព្វហេតុរួម។

៧.ការបំពេញកាតព្វកិច្ចអន្តរជាតិនាំមកនូវការអភិវឌ្ឍផ្នែកក្នុង៖ កាតព្វកិច្ចកម្ពុជាមានក្នុងឧបករណ៍អន្តរជាតិដូចជា UNCAC និង FATF បានជំរុញឱ្យមានការដាក់ចេញក្របខណ្ឌច្បាប់ និងការពង្រឹងការអនុវត្តរបស់តួអង្គពាក់ព័ន្ធ សំដៅធ្វើឱ្យប្រសើរឡើងនូវការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន រួមទាំងការប្រឆាំងអំពើពុករលួយ និងការសម្អាតប្រាក់ ការបំពេញតម្រូវការកំណត់ជាអន្តរជាតិ ហើយក៏ផ្តល់ផលវិជ្ជមានរយៈពេលយូរអង្វែង។

បន្ថែមពីលើមេរៀនទាំងនេះ មេរៀនថ្មីៗទៀតមានដូចជា៖

១. ការងារច្បាស់លាស់ តម្កល់ប្រយោជន៍សាធារណៈជាធំ កសាងបានទូរជំនឿ និងទំនុកចិត្ត។ កិច្ចប្រឹងប្រែងដឹកនាំ និងបំពេញការងារប្រកបដោយការទទួលខុសត្រូវ វ័យឆ្ងាត ច្នៃប្រឌិតពីសំណាក់ថ្នាក់ដឹកនាំ អ.ប.ព. និងសហការីក្នុងឋានៈជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយបាននាំមកនូវជំនឿទុកចិត្តពីសំណាក់ប្រមុខរាជរដ្ឋាភិបាល និងស្ថាប័នសាធារណៈពាក់ព័ន្ធ វិស័យឯកជនក៏ដូចជាសាធារណៈជនទូទៅដែលបានចូលរួមលើកស្ទួយការងារកសាងស្ថាប័នស្អាតស្អំ ការងារកំណែទម្រង់ការងារអភិបាលកិច្ចល្អ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

២. អំណាចនៃការផ្ដុំកម្លាំង និងបទពិសោធន៍ទាំងចាស់ទាំងថ្មីនៃកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នជាច្រើន បាននាំមកនូវប្រសិទ្ធភាពការងារ លទ្ធផលទទួលយកបាន ចំណាយត្រូវបានសន្សំ ចំណូលត្រូវបានបង្កើន ហើយក៏ឈានដល់ការទប់ស្កាត់ និងបង្ក្រាបបទល្មើសបានជាបន្តបន្ទាប់ផងដែរ។ ការផ្តត់ផ្តង់សហការគ្នាជាមួយ អ.ប.ព. ប្រៀបបាននឹងការបំពាក់បំប៉នសមត្ថកិច្ចជំនាញដល់ស្ថាប័នសាធារណៈដែលមិនអាចធ្វើអ្វីលើសពីក្របខណ្ឌច្បាប់បាន (ដៃខ្វី) ឧទាហរណ៍ក្នុងការចេញអាជ្ញាបណ្ណ ខណៈ អ.ប.ព. មានលទ្ធភាពរឹងមាំជាងលើការស៊ើបអង្កេត ការយកព័ត៌មានចារកម្មផ្សេងៗ (ដៃវែង) ដើម្បីសម្រេចបាននូវគោលដៅរួមដែលរដ្ឋដាក់ចេញ។

៣. តួនាទីល្អបំផុតរបស់ អ.ប.ព. គឺសេនាធិការ។ អ.ប.ព. បានចូលរួមគាំទ្រកិច្ចប្រឹងប្រែងអនុវត្តចំណាត់ការថ្មីៗដាក់ចេញដោយក្រសួង-ស្ថាប័ននានាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ហើយបានរួមគ្នាពាំនាំមកនូវសមិទ្ធផលវិជ្ជមានជាច្រើនគួរជាទីមោទនៈ។

៣. ការវិភាគអំពីបរិយាកាសជុំវិញ

៣.១. ការវិភាគបរិយាកាសនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ បរិស្ថាន (PESTLE)

៣.១.១. បរិយាកាសនយោបាយ

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ (២០២៣-២០២៨) មិនគ្រាន់តែជាការបន្តនូវការប្តេជ្ញានូវគោលនយោបាយគាំទ្រដល់កិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយដែលបានដាក់ចេញតាំងពីរាជរដ្ឋាភិបាលអាណត្តិមុនៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានសម្រួច និងពង្រឹងពង្រីកបន្ថែមនូវគោលដៅយុទ្ធសាស្ត្រ និងចំណាត់ការកាន់តែប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយដែលបម្រើដល់គោលដៅរួម គឺការអភិវឌ្ឍ និងកសាងប្រទេសឱ្យកាន់តែទំនើប រីកចម្រើនរុងរឿង។ ជាមួយនឹងមហិច្ឆតាជំរុញការដឹកនាំប្រទេសឆ្ពោះទៅជាប្រទេសមានកម្រិតចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ កម្មវិធីកំណែទម្រង់គ្រប់វិស័យ និងប្រតិបត្តិករដឹកនាំពោរពេញដោយថាមពល និងភ្នែវក្ខា និងប្រកបដោយឆន្ទៈមោះមុត សង្គមជាតិ និងពលរដ្ឋមានក្តីសង្ឃឹម។

*សារដាស់តឿន ក្រើនរំលឹក និងចំណាត់ការជាក់ស្តែងជាបន្តបន្ទាប់ ឆ្ទុះបញ្ចាំងពីការប្តេជ្ញាចិត្តកម្រិតខ្ពស់ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយដឹកនាំដែលបានដាក់ចេញជាមួយនឹងអភិក្រមទាំង ៥ "**ឆ្ទុះកញ្ចាក់ ងូតទឹក ដុសក្អែល ព្យាបាល វះកាត់**" ដែលត្រូវបានទទួលការជ្រួតជ្រាបពីសំណាក់មន្ត្រីសាធារណៈ និងអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" គឺការអភិវឌ្ឍស្ថាប័នការពង្រឹងអភិបាលកិច្ចល្អ ការពង្រឹងប្រសិទ្ធភាពការងារក្នុងវិស័យសាធារណៈ ដោយពង្រឹងគុណភាពប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏បានជំរុញការពង្រឹងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងកម្មវិធីដែលបានដាក់ចេញឱ្យកាន់តែមានភាពវិទ្យាសាស្ត្រ និងទំនើប សំដៅបង្កើនប្រសិទ្ធភាព និងដោះស្រាយបញ្ហាប្រឈម និងឧបសគ្គដែលអាចមានជាយថាហេតុ។*

នៅតាមវិស័យនានា ដូចជាហិរញ្ញវត្ថុសាធារណៈ - រដ្ឋបាលសាធារណៈ - យុត្តិធម៌ និងតុលាការ - វិមជ្ឈការ និងវិសហមជ្ឈការ - ដីធ្លី - កងកម្លាំង កំណែទម្រង់ជាច្រើនត្រូវបានអនុវត្តប្រកបដោយភាពសកម្ម និងគត់មត់។ ការបន្តកំណែទម្រង់មិនចេះនឿយហត់ទាំងនេះ និងធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច តម្លាភាព និងចូលរួមចំណែកដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ក្រសួង-ស្ថាប័ននានាតែងបានចូលរួមចំណែកក្នុងកិច្ចប្រឹងប្រែងអប់រំផ្សព្វផ្សាយអំពីផលវិបាកនៃអំពើពុករលួយ - បង្ការទប់ស្កាត់អំពើពុករលួយ តាមរយៈការកែលម្អការអនុវត្តការងារ និងកិច្ចសហការជាមួយ អ.ប.ព. និងដាក់ចេញចំណាត់ការវិនិយ ចំពោះការប្រព្រឹត្តកំហុសឆ្គងរបស់មន្ត្រីក្រោមឱវាទជាបន្តបន្ទាប់។

ក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ រាជរដ្ឋាភិបាលបានគាំទ្រ និងជំរុញយ៉ាងសកម្មដល់ស្ថាប័នប្រឆាំងអំពើពុករលួយ ចូលរួមក្នុងយន្តការប្រឆាំងអំពើពុករលួយ ជាមួយបណ្តាប្រទេសជាដៃគូ ទាំងលើការផ្ទាស់ប្តូរបទពិសោធន៍ - ការផ្តល់ជំនួយឱ្យគ្នាទៅវិញទៅមកក៏ដូចជាការបំពេញកាតព្វកិច្ចរបស់កម្ពុជាក្នុងនាមជារដ្ឋភាគី ជាសមាជិកនៃយន្តការរួមគ្នាប្រឆាំងអំពើពុករលួយ ដូចជា អាស៊ានផេក (ASEAN-PAC) - UNCAC - APG ជាដើម។ លទ្ធផលការងារដែលសម្រេចបានពីការចូលរួមយន្តការទាំងនេះ តែងតែត្រូវបានអនុញ្ញាតឱ្យមានការផ្សព្វផ្សាយជាសាធារណៈ ហើយចំណាត់ការខ្លះដែលតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងសង្គម ដូចជាស្ថាប័នសាធារណៈ - វិស័យឯកជន - សង្គមស៊ីវិល ជាដើម ក៏ត្រូវបានអនុញ្ញាតឱ្យមានការចូលរួមផ្តល់ជាតុចូលផងដែរ ដូចជា យន្តការត្រួតពិនិត្យការអនុវត្ត UNCAC ជាដើម។

លើការងារប្រតិបត្តិការ និងការអនុវត្តការងារ ស្ថាប័នប្រឆាំងអំពើពុករលួយក៏ត្រូវបានផ្តល់នូវឯករាជ្យភាពក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួនបានពេញលេញ ព្រមជាមួយការផ្តល់នូវការគាំទ្រយ៉ាងពេញលេញពីសំណាក់រាជរដ្ឋាភិបាល ទាំងលើធនធានថវិកា និងធនធានមនុស្ស។

៣.១.២. បរិយាកាសសេដ្ឋកិច្ច

រាជរដ្ឋាភិបាល បានបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជា ខិតខំបន្តស្តារ និងជំរុញកំណើនជាបណ្តើរៗឡើងវិញ បន្ទាប់ពីវិបត្តិកូវីដ-១៩ ដោយសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៥% ក្នុងឆ្នាំ២០២៣ និងប្រមាណជា ៦% ក្នុងឆ្នាំ២០២៤។ ភាពរឹងមាំ និងកំណើនធ្ងុបញ្ចាំងពីគុណភាព និងសមត្ថភាពដឹកនាំរបស់រាជរដ្ឋាភិបាល ខណៈដែលកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់ក្នុងការជំរុញកំណើន ការពង្រីកការកសាងនិងអភិវឌ្ឍ ការកាត់បន្ថយភាពក្រីក្រ ការកៀរគរ ការវិនិយោគជាតិ-អន្តរជាតិ ការបង្កើនប្រាក់បៀវត្សមន្ត្រីរាជការ ការគិតគូរដល់គ្រប់មជ្ឈដ្ឋានពលរដ្ឋក្នុងសង្គមជាមួយនឹងគោលនយោបាយ និងកម្មវិធីគាំពារនានា បង្ហាញពីការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាព និងការប្រកបរបរចិញ្ចឹមជីវិតរបស់ពលរដ្ឋកម្ពុជាក៏ដូចជាការនាំប្រទេសទៅកាន់ភាពសម្បូរបែប និងរីកចម្រើន។

រាជរដ្ឋាភិបាលក៏បានជំរុញគោលនយោបាយសេដ្ឋកិច្ច ដោយបង្កើនការចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចពីសំណាក់វិស័យឯកជន តាមរយៈការអនុវត្តនូវចំណាត់ការកៀរគរ និងជំរុញលើកទឹកចិត្តដែលគាំទ្រដល់ការវិនិយោគ ទាំងចាស់ ទាំងថ្មី ទាំងក្នុងស្រុក និងក្រៅស្រុក។ កិច្ចប្រឹងប្រែងជំរុញការបណ្តាក់ទុនវិនិយោគជាមួយនឹងការដាក់ចេញ និងផ្តល់ជូននូវការលើកទឹកចិត្តប្រកបដោយភាពទាក់ទាញ និងការប្រកួតប្រជែង ត្រូវបានដឹកនាំ និងប្រតិបត្តិឈានមុខផ្ទាល់ដោយប្រមុខរាជរដ្ឋាភិបាល និងបាននាំមកនូវផ្លែផ្កាជាលំហូរវិនិយោគ - ជាពលកម្មការងារជាបន្តបន្ទាប់គួរជាទីមោទនៈ។

តាមរយៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ឯករាជ្យនៃថវិកាជាតិ ជាពិសេសប្រសិទ្ធភាពនៃការកៀរគរចំណូល, ការអនុវត្តចំណាយថវិកា, និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ព្រមជាមួយនឹង ចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈក៏ត្រូវបានពង្រឹងកាន់តែប្រសើរឡើងជាលំដាប់។ ដើម្បីសម្រេចចក្ខុវិស័យ

នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យបានតាមកាលកំណត់, រាជរដ្ឋាភិបាលបានសម្រេចជ្រើសរើសយកយុទ្ធសាស្ត្រចោះដំហានតាមដំណាក់កាល ឬ អភិក្រមជាខឿនតាមរយៈក្របខណ្ឌ ផែនការសកម្មភាពរួមដែលផ្សំឡើងពីៈ បណ្តាសកម្មភាពចាំបាច់សម្រាប់កសាងមូលដ្ឋានគ្រឹះនៅតាម ដំណាក់កាលនីមួយៗ និងសកម្មភាពចាំបាច់នានាដែលត្រូវចាប់ផ្តើមកសាងដោយដកបទពិសោធន៍ ជាលក្ខណៈប្រុងប្រយ័ត្ន តែមានធន្ទះទៅមុខ ដើម្បីបង្ហាញពីមហិច្ឆតាក្នុងការប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងក្នុងបរិបទនៃប្រទេសស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបែងចែកជា ៤ ដំណាក់កាល រួមមានៈ

- ដំណាក់កាលទី១ ផ្តោតលើ "ការជឿទុកចិត្តនៃថវិកា"
- ដំណាក់កាលទី២ ផ្តោតលើ "គណនេយ្យភាពហិរញ្ញវត្ថុ"
- ដំណាក់កាលទី៣ ផ្តោតលើ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" និង
- ដំណាក់កាលទី៤ ផ្តោតលើ "ការកសាងគណនេយ្យភាពសមិទ្ធកម្ម" ។

ទោះបីជាយ៉ាងណាក៏ដោយ ភាពមិននឹងនរ និងការដុនដាបនៃសេដ្ឋកិច្ចពិភពលោក សង្គ្រាមពាណិជ្ជកម្មដែលកាន់តែក្តៅគគុកវាងមហាអំណាច និងបណ្តាប្រទេសសំខាន់ៗនានា និងការប្រកួតប្រជែងកាន់តែស្រួចស្រាល់ពីគ្រប់ទិសទី និងគ្រប់កាលៈទេសៈ នឹងបន្តតម្រូវឱ្យរាជរដ្ឋាភិបាលកាន់តែប្រុងប្រយ័ត្ន វៃឆ្លាត បត់បែន រស់រវើក និងរត់តាមឱ្យទាន់សភាពការណ៍ ចាប់ឱ្យបាននូវឱកាស និងបន្តកែទម្រង់ឱ្យជាប់ជាប្រចាំ។

៣.១.៣. បរិយាកាសសង្គម

១៥ ឆ្នាំ នៃយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីច្បាប់ប្រឆាំងអំពើពុករលួយ - ពីគោលនយោបាយប្រឆាំងអំពើពុករលួយរបស់រាជរដ្ឋាភិបាល - ពីផលវិបាកនៃអំពើពុករលួយ និងភាពចាំបាច់ក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយត្រូវចាប់ផ្តើមពីបុគ្គលម្នាក់ៗក្នុងសង្គម ពីការកសាងស្តាប័នស្អាតស្អំ សង្គមសស្អាតជូនដល់គ្រប់មជ្ឈដ្ឋាន ទាំងក្នុងស្តាប័នសាធារណៈ វិស័យឯកជន - សាលារៀន - ទីសាធារណៈ ដោយផ្ទាល់ដោយប្រយោល តាមមធ្យោបាយជាប្រពៃណី និងទំនើប តាមរយៈបណ្តាញសង្គមជាច្រើន អ.ប.ព. មានជំនឿថាសង្គមកម្ពុជាទទួលបានការជ្រួតជ្រាប - យល់ដឹងច្រើនពីអំពើពុករលួយ។ ការជ្រួតជ្រាប - យល់ដឹងទាំងនេះក៏ត្រូវបានជំរុញធ្ងន់បញ្ចាំងឱ្យឃើញ ដោយការចូលរួមសហប្រតិបត្តិការពីសំណាក់ស្តាប័នរដ្ឋ - កងកម្លាំង - អាជ្ញាធរមូលដ្ឋាន -សិស្សនិស្សិត មាតាបិតាក៏ដូចជាសាធារណជនទូទៅ នៅក្នុងវេទិកា - ព្រឹត្តិការណ៍ និងការកែទម្រង់នានារបស់រដ្ឋ ដូចជា ការប្រឡងបាក់ឌុប ប្រឡងជ្រើសរើសមន្ត្រីរាជការជាដើម។ ការប្រារព្ធទិវាជាតិ និងអន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ជារៀងរាល់ឆ្នាំ ដោយមានការចូលរួមពីស្តាប័នសាធារណៈ - វិស័យឯកជន - ប្រព័ន្ធផ្សព្វផ្សាយ -សិល្បករ និងមហាជនទូទៅ ក៏ដូចជាពីសំណាក់ប្រមុខរាជរដ្ឋាភិបាល តាមរយៈការផ្ញើជូនជនរួមជាតិនូវសារអបអរសាទរទិវាជាតិ-អន្តរជាតិប្រយុទ្ធប្រឆាំង

អំពើពុករលួយ ៩ដួ បានចូលរួមបន្ថែមការជ្រួតជ្រាបកាន់តែច្រើនឡើងៗ អំពីផលវិបាកនៃអំពើពុករលួយ និងកាតព្វកិច្ចក្នុងការប្រឆាំងអំពើពុករលួយដែលចាំបាច់ត្រូវចេញពីម្នាក់ៗផង និងរួមគ្នាផង ទើបអាចកសាងបាននូវសង្គមមួយសស្អាតទៅបាន។

ការចូលរួមផ្តល់ព័ត៌មាន - និយាយពីអំពើពុករលួយ - ការដាក់ពាក្យបណ្តឹងមក អ.ប.ព. ទាំងដោយអនាមិក និងដោយបញ្ចេញអត្តសញ្ញាណកាន់តែមានច្រើន គិតជាភាគរយនៃអ្នកបានដាក់ពាក្យ សុទ្ធតែជាសក្ខីភាពបង្ហាញថាសង្គមកាន់តែជ្រួតជ្រាប និងយល់ដឹង និងមិនអត់ឱនដល់ការប្រព្រឹត្តអំពើពុករលួយឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ស្របជាមួយនឹងចំណាត់ការបង្ការទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាប ការងារអប់រំពីអំពើពុករលួយ ត្រូវបន្តពង្រីកទាំងក្នុងសាលា ទាំងក្រៅសាលា ត្រូវផ្តោតឱ្យកាន់តែចំគោលដៅ ទាំងក្នុងស្រទាប់យុវវ័យ អ្នកត្រៀមចេញធ្វើការ អ្នកកំពុងធ្វើការ ទាំងក្នុងរដ្ឋ - មិនមែនរដ្ឋ និងតាមមធ្យោបាយឱ្យកាន់តែចម្រុះ ដើម្បីឱ្យការជ្រួតជ្រាបការយល់ដឹងពីអំពើពុករលួយ កាន់តែចាក់ឫសចូលកាន់តែជ្រៅទៅក្នុងសង្គម ហើយភាពសស្អាតកាន់តែត្រូវបានដុសខាត់ រំលេចឱ្យកាន់តែស ឱ្យកាន់តែស្អាតដល់មនុស្សជំនាន់ក្រោយៗ។

៣.១.៤. បរិយាកាសបច្ចេកវិទ្យា

ក្នុងយុគសម័យព័ត៌មានបច្ចេកវិទ្យាបានផ្តល់នូវសារៈប្រយោជន៍ដល់គ្រប់វិស័យ និងគ្រប់តួអង្គ ទាំងបុគ្គល រដ្ឋ ឯកជន។ រាជរដ្ឋាភិបាលអាណត្តិទី៧ បានកំណត់ថា បច្ចេកវិទ្យាឌីជីថលក្នុងការដឹកនាំគ្រប់គ្រងគឺជាអនាគត និងការចង់បានរបស់រដ្ឋ។ កំណែទម្រង់ជាច្រើនទៅមុខ ទាំងលើការគ្រប់គ្រងរដ្ឋបាល - ហិរញ្ញវត្ថុ - យុត្តិធម៌ - សេវាសាធារណៈ និងការអនុវត្តច្បាប់ នឹងត្រូវផ្តល់អាទិភាពឱ្យដល់ការធ្វើសមាហរណកម្មបច្ចេកវិទ្យាចូលទៅក្នុងប្រតិបត្តិការ និងការអនុវត្តតួនាទី - ភារកិច្ច។ គោលដៅនេះនឹងបម្រើ និងគាំទ្រជាវិជ្ជមាន ដល់កិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ជាការពិត បច្ចេកវិទ្យានឹងបន្តដើរតួជាផ្នែកមួយសំខាន់ក្នុងការងារអប់រំផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ។ ទាំងការជំរុញឱ្យមានការយល់ដឹងពីច្បាប់ ការបិទឱកាសពុករលួយ ការស៊ើបអង្កេត ការប្រមូលព័ត៌មាន ការរាយការណ៍ ការការពារប្រគព ការដាក់ និងដោះស្រាយបណ្តឹង និងការកសាងសំណុំរឿងទៅតុលាការ បច្ចេកវិទ្យាបានចូលរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាព ទំនុកចិត្ត ល្បឿន ភាពងាយស្រួល និងទាន់ពេលវេលា។ ព្រមជាមួយគ្នានេះដែរបច្ចេកវិទ្យាក៏ត្រូវបានប្រើប្រាស់ដោយជនល្មើសជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ហើយបង្កើនទៅភាពស្មុគស្មាញ និងការលំបាកដល់ការប្រឆាំង - ទប់ស្កាត់។ ការបំពាក់ឧបករណ៍បច្ចេកវិទ្យាទំនើប និងការបង្កើនសមត្ថភាពគ្រប់គ្រង និងទាញចំណេញឱ្យបានអស់លទ្ធភាពពីបច្ចេកវិទ្យាដែលអាចមានគឺជាកត្តាចាំបាច់ក្នុងយុគព័ត៌មានដែលវិឌ្ឍផ្លាស់ប្តូរក្នុងល្បឿនដ៏លឿន និងដែលមិនអាចប៉ាន់ស្មានបាននៃនវានុវត្តបច្ចេកវិទ្យាថ្មីៗ ក្នុងទម្រង់ជាបញ្ញាសិប្បនិម្មិត (AI)។

៣.១.៤. បរិយាកាសច្បាប់

ក្រោមការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល ច្បាប់ជាច្រើនត្រូវបានអនុម័ត ដើម្បីដាក់ចេញនូវបទដ្ឋានគតិយុត្ត ចាំបាច់សម្រាប់នីតិរដ្ឋ និងការដឹកនាំគ្រប់គ្រង និងកសាងសង្គមទំនើប។ ជាមួយនឹងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (MLA) ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML) ច្បាប់ជាច្រើនទៀតត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ ក្នុងនេះបញ្ញត្តិនៃច្បាប់ជាច្រើនដែលមានភាពប្រទាំងប្រទិសនឹងបញ្ញត្តិដែលគាំទ្រដល់ការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ តែងត្រូវបានសម្របសម្រួលដោយរាជរដ្ឋាភិបាល ដើម្បីស្វែងរកការកែសម្រួល និងសម្របឱ្យបានដើម្បីធានានូវការអនុវត្តច្បាប់បង្ក្រាបបទល្មើសអំពើពុករលួយដោយឯករាជ្យពីសំណាក់ អ.ប.ព. ក្នុងឋានៈជាសេនាធិការជូនរាជរដ្ឋាភិបាល។

បន្ថែមពីនេះ ក្រោមកាតព្វកិច្ចជារដ្ឋភាគី UNCAC និងជាសមាជិក APG កម្ពុជាបានធ្វើការត្រួតពិនិត្យការអនុវត្ត UNCAC និងក្រោមយន្តការវាយតម្លៃទៅវិញទៅមកក្នុងការអនុវត្តអនុសាសន៍ដាក់ចេញដោយក្រុម FATF ដោយក្នុងនេះបទប្បញ្ញត្តិសំខាន់ៗបន្ថែមទៀត ត្រូវបានរំលេច និងលើកទឹកចិត្តឱ្យកម្ពុជា បន្តអនុម័តដាក់ចេញរួមមានបញ្ញត្តិពាក់ព័ន្ធក្រមប្រតិបត្តិមន្ត្រីសាធារណៈ - ការការពារសាក្សី - ការពារបុគ្គលរាយការណ៍ - ការទប់ស្កាត់ទំនាស់ផលប្រយោជន៍ - ការពង្រីកការផ្តល់នូវព័ត៌មាន និងការរាយការណ៍ពីការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ - ការគាំទ្រដល់ការជួយគ្នាទៅវិញទៅមកលើការងារប្រឆាំងការសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើសជាដើម។ កិច្ចប្រឹងប្រែងបន្តដាក់ចេញប្បញ្ញត្តិថ្មីៗទៀតចាំបាច់ ត្រូវផ្អែកលើភាពច្នៃប្រឌិតលើបរិបទ និងការវិវឌ្ឍរបស់ប្រទេសស្របតាមកាលៈទេសៈ និងលទ្ធភាពអនុវត្តជាក់ស្តែង។

៣.១.៦. បរិយាកាសបរិស្ថាន

គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ២០១៥ ត្រូវបានបញ្ជ្រាប និងជំរុញការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីសំណាក់រាជរដ្ឋាភិបាល។ គោលដៅទី ១៦ ដែលបានកំណត់គោលដៅពាក់ព័ន្ធនឹងការងារប្រឆាំងអំពើពុករលួយដូចជាការកាត់បន្ថយបទល្មើសស៊ីសំណូកសូកប៉ាន់ - ការពង្រឹងប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពស្ថាប័ន និងការរឹបអូសផលនៃបទល្មើសជាដើម ត្រូវបានរាជរដ្ឋាភិបាលដាក់ចេញជាការងារអាទិភាពក្នុងគោលនយោបាយ និងកម្មវិធីដឹកនាំជាបន្តបន្ទាប់។ ការបន្ថែមសន្ទុះនៃកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយពីសំណាក់សហគមន៍អន្តរជាតិ និងតំបន់ ដូចជា សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ (UNGASS) ស្តីពីការប្តេជ្ញាចិត្តរួមក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈម និងការអនុវត្តវិធានការបង្ការ និងប្រឆាំងអំពើពុករលួយ និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឆ្នាំ២០២១ ការចុះ MoU ឡើងវិញស្តីពីកិច្ចសហប្រតិបត្តិការរបស់សមាគមន៍ភ្នាក់ងារប្រឆាំងអំពើពុករលួយអាស៊ាន

(ASEAN-PAC) ឆ្នាំ២០២២ ជាដើម និងចំណាត់ការដឹកនាំជំរុញការងារអភិបាលកិច្ចល្អ ការងារកំណែទម្រង់គ្រប់វិស័យពីសំណាក់រាជរដ្ឋាភិបាល សុទ្ធតែបានចូលរួមចំណែកដល់ការកសាងអភិវឌ្ឍ និងបានបង្កើតឡើងនូវបរិយាកាសមួយដែលអំណោយផលដល់ការរីកចម្រើនទាំងរដ្ឋ ទាំងឯកជន ទាំងសង្គមទាំងមូល ក៏ដូចជាបង្កើនទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការពីគ្រប់តួអង្គ ក្រោមគោលបំណងរួមគ្នា ដើម្បីសង្គមជាតិ និងពិភពលោកសស្អាត។

៣.២. ការវិភាគចំណុចខ្លាំង-ចំណុចខ្សោយ-ឱកាស- ការគំរាមកំហែង (SWOT)

៣.២.១. ចំណុចខ្លាំង

- មានធន្ធ:នយោបាយ គោលនយោបាយ និងផែនការអភិវឌ្ឍជាតិ ជាកម្លាំងជំរុញ គាំទ្រ និងចង្អុលបង្ហាញផ្លូវ
- មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលធានាឯករាជ្យភាព និងផ្តល់នូវមូលធនមនុស្ស និងថវិកាគ្រប់គ្រាន់សម្រាប់ ស.ប.ព. បំពេញតួនាទី ភារកិច្ច
- ក.ជ.ប.ព. ដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ព្រមទាំងផ្តល់នូវការពិគ្រោះយោបល់ និងអនុសាសន៍
- អ.ប.ព. មានផែនការសកម្មភាព និងរចនាសម្ព័ន្ធគ្រប់គ្រង សម្រាប់អនុវត្តយុទ្ធសាស្ត្រគោលទាំង ៣ គឺ អប់រំ បង្ការ ទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាបបទល្មើស
- មានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលជំរុញ និងធានាការអនុវត្តបាននូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព និងការពង្រឹងប្រសិទ្ធភាពការងារ
- មានបទប្បញ្ញត្តិ និងយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលពង្រឹងនូវស្មារតីទទួលខុសត្រូវខ្ពស់ តម្លាភាព គណនេយ្យភាព សេចក្តីថ្លៃថ្នូរ និងជៀសវាងទំនាស់ផលប្រយោជន៍
- មានបទពិសោធន៍ និងមានការពង្រឹងសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ
- មានទំនុកចិត្តលើភាពម៉ឺងម៉ាត់ និងតម្លាភាព ពីក្រសួង-ស្ថាប័ន វិស័យឯកជន និងសាធារណជនទូទៅ
- មានកិច្ចសហប្រតិបត្តិការល្អក្នុងតំបន់ និងអន្តរជាតិ

៣.២.២. ចំណុចខ្សោយ

- ធនធានមនុស្ស និងសមត្ថភាពជំនាញ នៅត្រូវការពង្រីក និងពង្រឹងបន្ថែម ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃសង្គម និងសេដ្ឋកិច្ច
- ការអប់រំ ផ្សព្វផ្សាយ នៅតាមវិស័យសាធារណៈ វិស័យឯកជន និងតាមសហគមន៍ មូលដ្ឋាន មិនទាន់ទូលំទូលាយ

- *មិនទាន់មានការិយាល័យប្រឆាំងអំពើពុករលួយ នៅតាមរាជធានី-ខេត្ត*
- *កិច្ចសហការជាមួយក្រសួង-ស្ថាប័នលើការងារ បង្ការ ទប់ស្កាត់ នៅមានកម្រិត*
- *ប្រព័ន្ធផ្តល់សេវាសាធារណៈនៅមិនទាន់ប្រែក្លាយជាប្រព័ន្ធស្វ័យប្រវត្តកម្មគ្រប់ជ្រុងជ្រោយ។*

៣.២.៣. ឱកាស

- *មានធនៈនយោបាយ និងក្របខណ្ឌច្បាប់ ដែលផ្តល់គ្រប់គ្រាន់នូវមូលធនមនុស្ស និងថវិកាលើការងារប្រឆាំងអំពើពុករលួយ*
- *ការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចត្រូវបានកំណត់ជាការងារអាទិភាពក្នុងកម្មវិធីនយោបាយ និងជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល*
- *មានការអនុវត្តកំណែទម្រង់ស៊ីជម្រៅនៅតាមក្រសួង-ស្ថាប័ន*
- *មានការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ រួមមាន ក្រសួង-ស្ថាប័ន វិស័យឯកជន សង្គមស៊ីវិលសាធារណជនទូទៅ*
- *យន្តការថ្នាក់ជាតិ និងអន្តរជាតិលើការងារប្រឆាំងអំពើពុករលួយ មានសន្ទុះកាន់តែខ្លាំង និងរឹងមាំ។*

៣.២.៤. ការគំរាមកំហែង

- *ការផ្ទាស់ប្តូរគំនិត ទស្សនៈ និងទម្លាប់ ត្រូវការពេលវេលា*
- *អភិបាលកិច្ចល្អ សុចរិតភាព និងសីលធម៌នៅតាមក្រសួង-ស្ថាប័ន និងវិស័យឯកជន នៅមានកម្រិត*
- *ការអនុវត្តវិធានការអប់រំ បង្ការទប់ស្កាត់ ដោយក្រសួង-ស្ថាប័ន និងវិស័យឯកជន មិនទាន់បានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ*
- *ការយល់ដឹងពីផលប៉ះពាល់ នៃអំពើពុករលួយ នៅមានកម្រិត*
- *ស្មារតីភ្ញាក់រលឹកប្រកាន់យកភាពស្អាតស្អំរបស់បុគ្គលពាក់ព័ន្ធមិនទាន់រឹងមាំ។*

៤. ទិសដៅយុទ្ធសាស្ត្រ (២០២៥-២០៣០)

៤.១. ចក្ខុវិស័យ

សង្គមកម្ពុជាពោរពេញដោយភាពសុខសន្តិ ប្រកាន់ខ្ជាប់នូវសុចរិតភាព ពលរដ្ឋគ្រប់ជាន់ថ្នាក់គោរពតាមគោលការណ៍នីតិរដ្ឋ និងយល់ដឹងច្បាស់ពីផលប៉ះពាល់នៃអំពើពុករលួយ។

៤.២. បេសកកម្ម

ដើម្បីលើកកម្ពស់សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់នៅកម្ពុជាតាមរយៈការចាត់វិធានការអប់រំ បង្ការ ទប់ស្កាត់ និងអនុវត្តច្បាប់ ដោយមានការចូលរួមពីសាធារណជន និងសហប្រតិបត្តិការអន្តរជាតិ។

៤.៣. គោលនយោបាយ

គោលនយោបាយក្នុងការប្រឆាំងអំពើពុករលួយ គឺការពង្រឹងអភិបាលកិច្ចល្អតាមរយៈការលុបបំបាត់អំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ដោយគ្មានការលើកលែង (Zero tolerance) សំដៅសម្រេចឱ្យបានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចមួយប្រកបដោយចីរភាព ស្ថិរភាព និងសមធម៌។

៤.៤. តុណាតម្លៃ

គុណតម្លៃនៃការប្រឆាំងអំពើពុករលួយ គឺសុចរិតភាព តម្លាភាព ឯកភាពជ្យភាព ជំនាញវិជ្ជាជីវៈកក្តីភាព ចំពោះច្បាប់ ក្លាហាន សាមគ្គីភាព ស្មារតីការងារជាក្រុម ភាពច្នៃប្រឌិត គណនេយ្យភាព និងការទទួលខុសត្រូវ។

៤.៥. គោលដៅ

ស្ថាប័នប្រឆាំងអំពើពុករលួយលើកកម្ពស់ឱ្យបាននូវការយល់ដឹងជ្រួតជ្រាបរបស់សាធារណជន និងធ្វើការបង្ក្រាបជនប្រព្រឹត្តអំពើពុករលួយ សំដៅកាត់បន្ថយអំពើពុករលួយទាំងបទល្មើស និងឱកាសប្រព្រឹត្តអំពើពុករលួយឱ្យបានលទ្ធផលគួរជាទីមោទនៈ។ លទ្ធផលនេះនឹងជួយពង្រឹងដល់អភិបាលកិច្ចល្អនីតិរដ្ឋ រួមចំណែកកសាងសង្គមមួយស្អាតស្អំ និងយុត្តិធម៌ ព្រមទាំងបានចូលរួមចំណែកកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក៏ដូចជាជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

៤.៦. ការជាវអាទិភាពដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងភាគីពាក់ព័ន្ធ

សកម្មភាពជាច្រើន នឹងត្រូវរំលេចឡើងនៅក្នុងយុទ្ធសាស្ត្រទាំង៧ ដែលបានកំណត់ដាក់ចេញ (១). អប់រំ (២). បង្ការទប់ស្កាត់ (៣). អនុវត្តច្បាប់បង្ក្រាប (៤). ក្របខណ្ឌគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិ (៥). កិច្ចសហការជាតិ អន្តរជាតិ និងការរឹបអូសផលនៃបទល្មើស (៦). ពង្រឹងសមត្ថភាព និងសុចរិតភាព

ស្ថាប័នសាធារណៈ និងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ (៧). យុទ្ធសាស្ត្របញ្ញាសិប្បនិម្មិត (AI) អភិវឌ្ឍន៍សមត្ថភាព សន្តិសុខ ព័ត៌មានប្រឆាំងបទល្មើសពុករលួយដោយ AI ដោយក្នុងនេះសកម្មភាពនៃយុទ្ធសាស្ត្រនីមួយៗនឹងត្រូវផ្គុំគ្នាក្រោមគោលបំណងដែលរំពឹងទុកជាក់លាក់។ សកម្មភាពក៏ត្រូវផ្គុំចូលគ្នាក្នុងទម្រង់ជាសកម្មភាពគោល អមដោយសកម្មភាពសំខាន់ៗ ដែលស្ថិតនៅក្នុងផែនការ អនុវត្តរយៈពេល៥ ឆ្នាំ ទៅមុខ(២០២៥-២០៣០)។ ការអនុវត្តសកម្មភាពទាំងនេះនឹងត្រូវតាមដានការអនុវត្តដោយសូចនាករមួយចំនួនដែលបានដាក់ចេញសម្រាប់ជាមូលដ្ឋានក្នុងការត្រួតពិនិត្យ និងវាយតម្លៃដែលត្រូវធ្វើជាប្រចាំដើម្បីតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងតាមដានប្រសិទ្ធភាពផង និងតាមដានបញ្ហាប្រឈម និងដាក់ចេញដំណោះស្រាយឱ្យបានទាន់សភាពការណ៍ និងពេលវេលាផង។

ខាងក្រោមជាការងារអាទិភាព គន្លឹះសំខាន់ៗមួយចំនួនដែលយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី៤ (២០២៥-២០៣០) ផ្តោតលើ៖

- ១.ពង្រីកវិសាលភាពនៃគោលដៅអប់រំ ចំណេះ-យន្តការបម្រើដល់សុចរិតភាព - តម្លាភាព - ប្រឆាំងអំពើពុករលួយដល់ និស្សិតឧត្តមសិក្សា - គ្រឹះស្ថានជំនាញវិជ្ជាជីវៈ មន្ត្រីវ័យក្មេង ថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ បុគ្គលិកវិស័យមិនមែនរដ្ឋ តាមរយៈយន្តការបណ្តុះបណ្តាលផ្ទាល់ - បណ្តុះបណ្តាលបន្តដោយគ្រូឯកភាជ្ជដែលទទួលបានការបំពាក់បំប៉ន ច្បាស់លាស់ និងតាមយន្តការជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន
- ២.ពង្រីកវិសាលភាពនៃគោលដៅអប់រំ ចំណេះ-យន្តការបម្រើដល់សុចរិតភាព - តម្លាភាព - ប្រឆាំងអំពើពុករលួយ(ឧទាហរណ៍ លទ្ធកម្ម - ទទួល និងដោះស្រាយពាក្យបណ្តឹង - ការការពារបុគ្គលភយការណ៍ - សាក្សី - ការវាយតម្លៃហានិភ័យសេវាផ្តល់អាជ្ញាប័ណ្ណ ។ល។) ក្នុងទម្រង់ដែលអាចផ្សព្វផ្សាយបានទាំងបូរាណ និងទំនើប (ឌីជីថល)
- ៣.គាំទ្រចលនា "សេវាសាធារណៈ:ល្អ ភស្ត្រស្រលាញ់គាំទ្រ" និងជំរុញការងារទំនើបកម្ម កែសម្រួលឱ្យកាន់តែងាយ - លឿន - សាមញ្ញ នូវការផ្តល់សេវាសាធារណៈ
- ៤.គាំទ្រការលើកម្ពស់ក្របខណ្ឌសុចរិតភាពក្នុងលទ្ធកម្មសាធារណៈ និងការជំរុញការអនុវត្តច្បាប់ និងយន្តការលទ្ធកម្មសាធារណៈឱ្យកាន់តែល្អប្រសើរ កាត់បន្ថយចំណាយ បង្កើនប្រសិទ្ធភាព និងឆ្ពោះទៅកាន់ការអនុវត្តលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ៥. ពង្រីកវិសាលភាពការប្រកាសទ្រព្យសម្បត្តិ និងបំណុលដល់គោលដៅដែលងាយនឹងការប្រឈមហានិភ័យអំពើពុករលួយ
- ៦.គាំទ្រជំរុញទំនើបកម្មការប្រឡងប្រជែងជ្រើសរើសនានាតាមមធ្យោបាយឌីជីថលផង ផ្ទាល់ផង
- ៧.ពង្រីកយន្តការ និងមធ្យោបាយទទួលពាក្យប្តឹង (រាជធានី-ខេត្ត) និងពន្លឿនចំណាត់ការដោះស្រាយឆ្លើយតប និងតាមដាន

៨.អភិវឌ្ឍ និងទំនើបកម្មធនធានសម្ភារ ឧបករណ៍ជំនាញ និងសមត្ថភាពលើការងារស៊ើបអង្កេត តាមរកឹបអូសផលនៃបទល្មើស និងបញ្ជូនសំណុំរឿងទៅតុលាការ

៩.គាំទ្រការរៀបចំក្រមប្រតិបត្តិសម្រាប់មន្ត្រីសាធារណៈ ដោយរួមមានទូវធាតុផ្សំដូចជា ការទប់ស្កាត់ទំនាស់ផលប្រយោជន៍ - យន្តការទទួលពាក្យប្តឹង ដោះស្រាយ និងការការពារបុគ្គលរាយការណ៍ - សាក្សី - និងការរាយការណ៍ និងទទួលបានព័ត៌មានពីការកសាងភាពស្អាតស្អំ

១០.រៀបចំលិខិតបទដ្ឋានគតិយុត្តពង្រឹងតួនាទី ការកិច្ចរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ

១១.គាំទ្រការរៀបចំដាក់ចេញនូវបទដ្ឋានគតិយុត្តដែលបម្រើដល់ការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក - ការប្រឆាំងការលាងសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស

១២.គាំទ្រជំរុញការអនុវត្តតួនាទី-ការកិច្ចក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ (អប់រំ-បង្ការទប់ស្កាត់-បណ្តុះបណ្តាល-លទ្ធកម្ម-ការអនុវត្តអភិក្រមទាំង៥-ការត្រួតពិនិត្យ និងវាយតម្លៃ និងការរាយការណ៍)

១៣.រៀបចំ-ទទួលកិច្ចសន្ទនា / ការពិភាក្សាការងារជាមួយតួអង្គពាក់ព័ន្ធរួមមាន គណៈកម្មការទី១០ ទាំងពីរនៃរដ្ឋសភា-ព្រឹទ្ធសភា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ទីភ្នាក់ងារអនុវត្តច្បាប់ ផ្នែកឯកជន (រួមមានការបន្តចុះ MOU) សង្គមស៊ីវិល-ផ្នែកសិក្សាធិការ-សារព័ត៌មាន

១៤.ពង្រីកដៃគូសហប្រតិបត្តិការអន្តរជាតិតាមរយៈការចូលរួម យន្តការប្រឆាំងអំពើពុករលួយ តំបន់-អន្តរជាតិ និងការចុះ MOU ស្តីពីកិច្ចសហប្រតិបត្តិការ និងជំរុញការចូលរួមកាន់តែសកម្មក្នុងវេទិកា UNCAC OECD GLOBE Network APG...

១៥. ពង្រឹងយន្តការ និងថ្នាលកសាងនវានុវត្តន៍ថ្មីៗ ប្រកបដោយការច្នៃប្រឌិត និងស្របតាមតម្រូវការជាក់ស្តែងរបស់ស្ថាប័នប្រឆាំងអំពើពុករលួយក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ

១៦. សិក្សាយន្តការអន្តរជាតិ-ផ្តល់អនុសាសន៍ដើម្បីបង្កើតការវាយតម្លៃល្អសម្រាប់កម្ពុជា

១៧. ពង្រឹងយន្តការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃ (M&E) ការអនុវត្តយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយឱ្យកាន់តែមានភាពវិទ្យាសាស្ត្រទំនើប

១៨. រៀបចំបង្កើតរចនាសម្ព័ន្ធការិយាល័យប្រឆាំងអំពើពុករលួយតាមរាជធានី-ខេត្ត ទទួលបន្ទុកអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើពុករលួយនៅថ្នាក់ក្រោមជាតិលើការងារ អប់រំ បង្ការ និងទប់ស្កាត់ (មិនមែនការងារកសាងសំណុំរឿងបញ្ជូនទៅតុលាការទេ)

១៩. រៀបចំការងារបញ្ញាសិប្បនិម្មិត (AI) សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ។

៤. យុទ្ធសាស្ត្រ សកម្មភាពគោល សកម្មភាព និងសូចនាករ នៃការអនុវត្តការងារ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
I. យុទ្ធសាស្ត្រអប់រំ			
<u>គោលបំណងទី១</u>: ពង្រីកវិសាលភាពអប់រំ និងបង្កើនការយល់ដឹងអំពីការប្រឆាំងអំពើពុករលួយ			
១. ជំរុញសកម្មភាពនិងបង្កើនប្រសិទ្ធភាពនៃការអប់រំប្រឆាំងអំពើពុករលួយនៅគ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈ	១.១. កសាងមេរៀនប្រឆាំងអំពើពុករលួយ និងដាក់បញ្ចូលក្នុងកម្មវិធីសិក្សា សម្រាប់គ្រឹះស្ថានសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ សាលាវិជ្ជាជីវៈ- គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ	១.១.១. ចំនួនមេរៀនប្រឆាំងអំពើពុករលួយ ដែលបានកសាង និងដាក់ឱ្យអនុវត្ត ១.១.២. ចំនួនគ្រឹះស្ថាន សិក្សា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ សាលាវិជ្ជាជីវៈ គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈដែល អនុវត្តមេរៀនប្រឆាំងអំពើពុករលួយ	អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាណាព្យាបាលគ្រឹះស្ថានសិក្សា សាលាវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
	១.២. រៀបចំសកម្មភាពអប់រំប្រឆាំងអំពើពុករលួយនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ សាលាវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា -គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ	១.២.១. ចំនួនសកម្មភាពអប់រំប្រឆាំងអំពើពុករលួយនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ សាលាវិជ្ជាជីវៈ -គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ១.២.២. ចំនួនអ្នកចូលរួម	អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាណាព្យាបាលគ្រឹះស្ថានសិក្សា សាលាវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
	១.៣. បណ្តុះបណ្តាលគ្រូបង្គោលអំពីមេរៀនប្រឆាំងអំពើពុករលួយសម្រាប់គ្រឹះស្ថានឧត្តមសិក្សា	១.៣.១. ចំនួនគ្រូបង្គោលត្រូវបានបណ្តុះបណ្តាល	អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	សាលាវិជ្ជាជីវៈ-គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ		
	១.៤. *ចុះសង្កេតការណ៍ ដកពិសោធន៍ និងផ្តល់ជំនួយក្នុងការបង្រៀន និងរៀននៅតាមគ្រឹះស្ថានគោលដៅ*	១.៤.១. *ចំនួនគ្រឹះស្ថានគោលដៅដែលបានចុះ* ១.៤.២. *ចំនួនគ្រូដែលទទួលបានការបណ្តុះបណ្តាល និងចូលរួម*	*អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាណាព្យាបាល គ្រឹះស្ថានសិក្សា សាលាវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ*
២. *ជំរុញសកម្មភាពអប់រំប្រឆាំងអំពើពុករលួយនៅក្រៅសាលា (សាធារណជន)*	២.១. *រៀបចំសកម្មភាពអប់រំអំពីការប្រឆាំងអំពើពុករលួយនៅតាមគោលដៅជាក់លាក់*	២.១.១. *មានមេរៀនអប់រំប្រឆាំងអំពើពុករលួយនៅតាមគោលដៅជាក់លាក់* ២.១.២. *ចំនួនការផ្សព្វផ្សាយ* ២.១.៣. *ចំនួនអ្នកទទួលបានការផ្សព្វផ្សាយ*	*អ.ប.ព.-ភាគីពាក់ព័ន្ធ*
	២.២. *ប្រារព្ធទិវាជាតិប្រឆាំងអំពើពុករលួយ ៩ ធ្នូ*	២.២.១. *មានព្រឹត្តិការណ៍អបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ* ២.២.២. *ចំនួនអ្នកចូលរួម*	*អ.ប.ព.-ភាគីពាក់ព័ន្ធ*
៣. *ជំរុញសកម្មភាពអប់រំប្រឆាំងអំពើពុករលួយ*	៣.១. *រៀបចំវគ្គបណ្តុះបណ្តាល/បាឋកថាច្បាប់ប្រឆាំងអំពើពុករលួយ សម្រាប់ស្ថាប័នសាធារណៈ*	៣.១.១. *ចំនួនវគ្គបណ្តុះបណ្តាល/បាឋកថា* ៣.១.២. *ចំនួនអ្នកចូលរួម*	*អ.ប.ព.-ស្ថាប័នសាធារណៈ*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
សម្រាប់ក្រសួង-ស្ថាប័នសាធារណៈ	*៣.២. រៀបចំមេរៀនពាក់ព័ន្ធនឹងការកសាងភាពស្អាតស្អំតាមមូលបទសម្រាប់ក្រសួង-ស្ថាប័នសាធារណៈ*	*៣.២.១. មានមេរៀនការកសាងភាពស្អាតស្អំ*	*អ.ប.ព. -ស្ថាប័នសាធារណៈ -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន*
	៣.៣. រៀបចំ និងដាក់ចេញយន្តការបណ្តុះបណ្តាលភាពស្អាតស្អំតាមក្រសួង-ស្ថាប័នសាធារណៈ	*៣.៣.១. មានយន្តការបណ្តុះបណ្តាលភាពស្អាតស្អំតាមស្ថាប័នសាធារណៈ* *៣.៣.២. ចំនួនកម្មវិធីបណ្តុះបណ្តាល* *៣.៣.៣. ចំនួនក្រសួង-ស្ថាប័ន* *៣.៣.៤. ចំនួនអ្នកចូលរួម*	*អ.ប.ព. -ស្ថាប័នសាធារណៈ -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន*
	៣.៤. រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល (សម្រាប់បណ្តុះបណ្តាលបន្ត)	*៣.៤.១. ចំនួនវគ្គបណ្តុះបណ្តាល* *៣.៤.២. ចំនួនគ្រូបង្គោលដែលបានទទួលការបណ្តុះបណ្តាល*	*អ.ប.ព. -ស្ថាប័នសាធារណៈ -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន*
	៣.៥. រៀបចំវគ្គបណ្តុះបណ្តាលក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈ	*៣.៥.១. ចំនួនវគ្គបណ្តុះបណ្តាល* *៣.៥.២. ចំនួនក្រុមជនបង្គោលចូលរួម*	*អ.ប.ព. -ស្ថាប័នសាធារណៈ -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
៤. ជំរុញសកម្មភាពអប់រំប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន	៤.១. សហការផ្សព្វផ្សាយកម្មវិធីប្រឆាំងអំពើពុករលួយ និងចែករំលែកបទពិសោធន៍ជោគជ័យដែលវិស័យឯកជនសហការជាមួយ អ.ប.ព. ទៅដល់វិស័យឯកជនដទៃទៀត	៤.១.១. ចំនួនការផ្សព្វផ្សាយ ៤.១.២. ចំនួនវិស័យឯកជន/អ្នកទទួលបានការផ្សព្វផ្សាយ	អ.ប.ព. -វិស័យឯកជន
<u>គោលបំណងទី២</u>៖ បំផុសការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ			
១. ពង្រឹង និងពង្រីកកិច្ចការទំនាក់ទំនងសាធារណៈលើការងារប្រឆាំងអំពើពុករលួយ	១.១. សហការជាមួយភាគីពាក់ព័ន្ធក្នុងការបង្កើតកម្មវិធីអប់រំផ្សព្វផ្សាយអំពីការប្រឆាំងអំពើពុករលួយ	១.១.១. មានសកម្មភាពសហការជាមួយភាគីពាក់ព័ន្ធក្នុងការអប់រំផ្សព្វផ្សាយអំពីការប្រឆាំងអំពើពុករលួយ	អ.ប.ព. -ភាគីពាក់ព័ន្ធ
	១.២. រៀបចំកម្មវិធីសិក្សាស្វែងយល់ពីការងារប្រឆាំងអំពើពុករលួយ	១.២.១. មានកម្មវិធីសិក្សាស្វែងយល់ពីការងារប្រឆាំងអំពើពុករលួយ ១.២.២. ចំនួនអ្នកចូលរួម	អ.ប.ព. -ភាគីពាក់ព័ន្ធ
២. បង្កើតកម្មវិធីប្រកួតប្រជែងពាក់ព័ន្ធនឹងការអប់រំ-បណ្តុះភាពស្អាតស្អំ	២.១. រៀបចំកម្មវិធីប្រកួតអត្ថបទផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តល្អៗក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមគ្រប់រូបភាព	២.១.១. មានកម្មវិធីប្រកួតអត្ថបទស្រាវជ្រាវពាក់ព័ន្ធនឹងការអនុវត្តល្អៗក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ២.១.២. ចំនួនអ្នកចូលរួម/ជ័យលាភី	អ.ប.ព. -ភាគីពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	២.២. រៀបចំកម្មវិធីប្រកួតការផលិតឧបករណ៍អប់រំ-បណ្តុះភាពស្អាតស្អំ (ឃ្លីបវីដេអូ សិល្បៈក្នុងទម្រង់ផ្សេងៗ)	២.២.១. មានកម្មវិធីប្រកួតឃ្លីបវីដេអូពាក់ព័ន្ធនឹងការអនុវត្តល្អៗក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ២.២.២. ចំនួនអ្នកចូលរួម/ជ័យលាភី	អ.ប.ព. -ភាគីពាក់ព័ន្ធ
	២.៣. រៀបចំកម្មវិធីប្រកួតកំណាព្យពាក់ព័ន្ធនឹងការអនុវត្តល្អៗក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ	២.៣.១. មានកម្មវិធីប្រកួតកំណាព្យពាក់ព័ន្ធនឹងការអនុវត្តល្អៗក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ២.៣.២. ចំនួនអ្នកចូលរួម/ជ័យលាភី	អ.ប.ព. -ភាគីពាក់ព័ន្ធ
៣. ស្ថាបស្ទង់/វាយតម្លៃការយល់ដឹង/ផលទទួលបានពីការអប់រំផ្សព្វផ្សាយអំពីអំពើពុករលួយ	៣.១. រៀបចំការស្ទាបស្ទង់/ការវាយតម្លៃការយល់ដឹង/ផលទទួលបានពីការអប់រំអំពីអំពើពុករលួយ	៣.១.១. មានលទ្ធផលស្ទាបស្ទង់/ការវាយតម្លៃ	អ.ប.ព.
<u>គោលបំណងទី៣</u>៖ ពង្រីកវិសាលភាព និងពង្រឹងការផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើពុករលួយ			
	១.១. កសាងឧបករណ៍អប់រំ-ផ្សព្វផ្សាយពីការប្រឆាំងអំពើពុករលួយ	១.១.១. ចំនួនឧបករណ៍អប់រំ-ផ្សព្វផ្សាយពីការប្រឆាំងអំពើពុករលួយដែលបានផលិត	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
១. ពង្រីកវិសាលភាពនៃការផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើពុករលួយ	១.២. ធ្វើទំនើបកម្មយន្តការផ្សព្វផ្សាយឧបករណ៍អប់រំ-ផ្សព្វផ្សាយពីការប្រឆាំងអំពើពុករលួយ	១.២.១. មានយន្តការផ្សព្វផ្សាយឧបករណ៍អប់រំ-ផ្សព្វផ្សាយពីការប្រឆាំងអំពើពុករលួយតាមបែបទំនើប	អ.ប.ព.
	១.៣. បង្កើនកិច្ចសហការផ្សព្វផ្សាយកម្មវិធីប្រឆាំងអំពើពុករលួយជាមួយប្រព័ន្ធផ្សព្វផ្សាយសាធារណៈ	១.៣.១. មានកិច្ចសហការផ្សព្វផ្សាយកម្មវិធីប្រឆាំងអំពើពុករលួយ	អ.ប.ព. -ស្ថាប័នពាក់ព័ន្ធ
II. យុទ្ធសាស្ត្របង្ការ ឧប់ស្កាត់			
<u>គោលបំណងទី១</u>៖ គាំទ្រការពង្រឹងអភិបាលកិច្ចល្អ និងរដ្ឋបាលសាធារណៈស្អាតស្អំ			
១. ជំរុញការរៀបចំកម្មវិធីពង្រឹងភាពស្អាតស្អំនៅតាមស្ថាប័នសាធារណៈ (យោងក្រមប្រតិបត្តិការរាយការណ៍ ...)	១.១. រៀបចំកម្មវិធីពង្រឹងភាពស្អាតស្អំនៅតាមក្រសួង-ស្ថាប័នសាធារណៈ (យោងក្រមប្រតិបត្តិការរាយការណ៍...)	១.១.១. មានកម្មវិធីពង្រឹងភាពស្អាតស្អំនៅតាមក្រសួង-ស្ថាប័នសាធារណៈ	អ.ប.ព. -ក្រសួងមុខងារសាធារណៈ -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន
	១.២. ផ្តល់ការគាំទ្រ និងតាមដានការអនុវត្តកម្មវិធីពង្រឹងភាពស្អាតស្អំនៅតាមក្រសួង-ស្ថាប័នសាធារណៈ	១.២.១. ចំនួនក្រសួង-ស្ថាប័នដែលបានអនុវត្តកម្មវិធីពង្រឹងភាពស្អាតស្អំនៅតាមស្ថាប័នសាធារណៈ	អ.ប.ព. -ក្រសួងមុខងារសាធារណៈ -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
<u>គោលបំណងទី២</u>៖ ជំរុញការផ្តល់សេវាសាធារណៈល្អ			
១. ជំរុញការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាព ប្រកបដោយភាពស្អាតស្អំ	១.១. ជំរុញការអនុវត្តចលនា "សេវាសាធារណៈល្អ រាស្ត្រស្រលាញ់គាំទ្រ" នៅតាមស្ថាប័នសាធារណៈ	១.១.១. ចំនួនសកម្មភាពចលនា "សេវាសាធារណៈល្អ រាស្ត្រស្រលាញ់គាំទ្រ" ១.១.២. ចំនួនអង្គ/ទីកន្លែង/អ្នកផ្តល់សេវាចូលរួមចលនា "សេវាសាធារណៈល្អ រាស្ត្រស្រលាញ់គាំទ្រ"	អ.ប.ព.-ស្ថាប័នសាធារណៈ/ទីកន្លែងផ្តល់សេវាសាធារណៈ
	១.២. ជំរុញការដាក់ចេញ និងកែលម្អប្រកាសពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ	១.២.១. ចំនួនប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈដែលបានដាក់ចេញ និងកែសម្រួល	អ.ប.ព.-ស្ថាប័នសាធារណៈ/ទីកន្លែងផ្តល់សេវាសាធារណៈ
	១.៣. ជំរុញការធ្វើទំនើបកម្មសេវាសាធារណៈ	១.៣.១. ចំនួនសេវាសាធារណៈត្រូវបានធ្វើទំនើបកម្ម	អ.ប.ព.-ស្ថាប័នសាធារណៈ/ទីកន្លែងផ្តល់សេវាសាធារណៈ
	១.៤. សហការសម្រួលនីតិវិធី យន្តការរយៈពេល និងរបៀបរបបការងារក្នុងការផ្តល់សេវាសាធារណៈ	១.៤.១. ចំនួនកិច្ចសហការសម្រួលនីតិវិធី យន្តការរយៈពេល និងរបៀបរបបក្នុងការផ្តល់សេវាសាធារណៈ	អ.ប.ព.-ស្ថាប័នសាធារណៈ/ទីកន្លែងផ្តល់សេវាសាធារណៈ
<u>គោលបំណងទី៣</u>៖ ជំរុញធុរកិច្ចស្អាតស្អំនៅក្នុងវិស័យឯកជន			
១. ជំរុញធុរកិច្ចស្អាតស្អំ	១.១. ពង្រីកកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយជាមួយវិស័យឯកជន (MoU)	១.១.១. ចំនួន MoU និងចំណាត់ការសហប្រតិបត្តិការក្នុងទម្រង់ផ្សេងៗ	អ.ប.ព.-វិស័យឯកជន

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	១.២. រៀបចំកិច្ចសន្ទនា/ពិគ្រោះយោបល់ ស្តាប់ និង ដោះស្រាយបញ្ហាប្រឈមក្នុងធុរកិច្ច	១.២.១. ចំនួនកិច្ចសន្ទនា/ពិគ្រោះយោបល់ ១.២.២. ចំនួនក្រុមហ៊ុន/ផ្នែកឯកជនបានចូលរួម	អ.ប.ព.-វិស័យឯកជន
<u>គោលបំណងទី៤</u>៖ ពង្រឹងប្រសិទ្ធភាពការទប់ស្កាត់បាតុភាពក្នុងការប្រឡង លទ្ធកម្មសាធារណៈ ការលក់ជាសាធារណៈ			
១. ជំរុញការអនុវត្តគោលការណ៍អនុលោមភាពតម្លាភាព និងយុត្តិធម៌នៃការប្រឡង	១.១. ជំរុញការធ្វើទំនើបកម្ម នៃការប្រឡង	១.១.១. ចំនួនការប្រឡងត្រូវបានរៀបចំតាមបែបទំនើបកម្ម	អ.ប.ព. -ភាគីពាក់ព័ន្ធ
	១.២. ទំនើបកម្មការងារសង្កេតការណ៍	១.២.១. ចំនួនការចូលរួមសង្កេតការណ៍ការប្រឡងដែលបានធ្វើទំនើបកម្ម	អ.ប.ព.-ភាគីពាក់ព័ន្ធ
២. ពង្រឹងតម្លាភាព ការប្រកួតប្រជែងយុត្តិធម៌ និងសន្សំសំចៃក្នុងលទ្ធកម្មសាធារណៈ	២.១. ជំរុញការចូលរួមទប់ស្កាត់បាតុភាពមិនប្រក្រតីក្នុងលទ្ធកម្មសាធារណៈ	២.១.១. ចំនួនដងនៃការចូលរួមសង្កេតការណ៍ ២.១.២. ចំនួនគម្រោងដែលបានចូលរួមសង្កេតការណ៍ ២.១.៣. ចំនួនស្ថាប័នអនុវត្តលទ្ធកម្មដែលបានចូលរួមសង្កេតការណ៍	អ.ប.ព.-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ស្ថាប័នអនុវត្តលទ្ធកម្ម
	២.២. បន្តរៀបចំកម្រងព័ត៌មានអ្នកដេញថ្លៃដែលមានភាពមិនប្រក្រតី (Red Flag) សម្រាប់ជូន ក.ស.ហ.វ.	២.២.១. ចំនួនដងនៃការបញ្ជូនកម្រងព័ត៌មានទៅ ក.ស.ហ.វ. ២.២.២. ចំនួនក្រុមហ៊ុន/អ្នកដេញថ្លៃ	អ.ប.ព.
	២.៣. ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងការសង្កេតការណ៍កិច្ចលទ្ធកម្ម	២.៣.១. ចំនួនធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងការសង្កេតការណ៍កិច្ចលទ្ធកម្ម	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	២.៤. ជំរុញ និងពន្លឿនការរៀបចំ អនុវត្តលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក	២.៤.១. ចំនួនស្ថាប័នអនុវត្តលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ២.៤.២. ចំនួនគម្រោងលទ្ធកម្មអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិក	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ភាគីពាក់ព័ន្ធ
	២.៥. ជំរុញការពង្រឹងសុចរិតភាពក្នុងយន្តការលទ្ធកម្មសាធារណៈ	២.៥.១. ក្របខណ្ឌសុចរិតភាព (បណ្តឹងតវ៉ា-ផ្ទាស់ប្តូរព័ត៌មាន-កិច្ចសន្ទនា-បណ្តុះបណ្តាល...) ត្រូវបានបញ្ចូលក្នុងដំណើរការលទ្ធកម្មសាធារណៈ	អ.ប.ព.-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ភាគីពាក់ព័ន្ធ
	២.៦. ពង្រឹងកិច្ចសហការ និងការផ្ទាស់ប្តូរព័ត៌មានរវាង អ.ប.ព. និង ក.ស.ហ.វ.	២.៦.១. ចំនួនកិច្ចសហការ និងការផ្ទាស់ប្តូរព័ត៌មានលទ្ធកម្មសាធារណៈ	អ.ប.ព.-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ភាគីពាក់ព័ន្ធ
	២.៧. ពង្រឹងកិច្ចសហការ និងការគាំទ្រវិស័យឯកជនលើក្របខណ្ឌសុចរិតភាពក្នុងការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ	២.៧.១. ចំនួនកិច្ចសហការ និងការគាំទ្រវិស័យឯកជនលើក្របខណ្ឌសុចរិតភាពក្នុងការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ	អ.ប.ព.-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ភាគីពាក់ព័ន្ធ
៣. ពង្រឹងតម្លាភាពក្នុងការលក់ជាសាធារណៈ	៣.១. ជំរុញការចូលរួមទប់ស្កាត់បាតុភាពក្នុងការលក់ជាសាធារណៈ	៣.១.១. ចំនួនដងនៃការចូលរួមសង្កេតការណ៍ ៣.១.២. ចំនួនគម្រោងដែលបានចូលរួមសង្កេតការណ៍ ៣.១.៣. ចំនួនស្ថាប័នអនុវត្តការលក់ជាសាធារណៈដែលបានចូលរួមសង្កេតការណ៍	អ.ប.ព. -ស្ថាប័នមានសមត្ថកិច្ច -ភាគីពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	៣.២. រៀបចំកម្រងព័ត៌មានអ្នកទិញ/ក្រុមហ៊ុន ដែលមានភាពមិនប្រក្រតី សម្រាប់ជូនស្ថាប័នមានសមត្ថកិច្ច	៣.២.១. ចំនួនដងនៃការបញ្ជូនកម្រងព័ត៌មានទៅស្ថាប័នមានសមត្ថកិច្ច ៣.២.២. ចំនួនក្រុមហ៊ុន	
	៣.៣. ជំរុញការរៀបចំ អនុវត្តការលក់ជាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក	៣.៣.១. ចំនួនស្ថាប័នអនុវត្តលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៣.៣.២. ចំនួនគម្រោងអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិក	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -ភាគីពាក់ព័ន្ធ
	៣.៤. ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងការសង្កេតការណ៍ការលក់ជាសាធារណៈ	៣.៤.១. ចំនួនធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងការសង្កេតការណ៍	អ.ប.ព.
<u>គោលបំណងទី៥</u>៖ ពង្រឹងប្រសិទ្ធភាពការប្រកាសទ្រព្យសម្បត្តិ និងបំណុល			
១. ពង្រីកវិសាលភាពគោលដៅដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល	១.១. កំណត់គោលដៅថ្មីដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល	១.១.១. ចំនួនអ្នកត្រូវប្រកាសតាមគោលដៅដែលត្រូវបានពង្រីក	អ.ប.ព.
	១.២. អនុវត្តយន្តការប្រកាសទ្រព្យសម្បត្តិ និងបំណុល ចំពោះគោលដៅថ្មី	១.២.១. មានយន្តការ និងគោលដៅថ្មី ដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល	អ.ប.ព.
២. បន្តធ្វើទំនើបកម្មការប្រកាសទ្រព្យសម្បត្តិ និងបំណុល	២.១. បន្តធ្វើទំនើបកម្មលើការគ្រប់គ្រងស្ថិតិ ទិន្នន័យ ការទុកដាក់ឯកសារតាមបទដ្ឋានបច្ចេកទេស	២.១.១. មានស្ថិតិ ទិន្នន័យ និងការទុកដាក់ឯកសារ ត្រូវបានកែលម្អ	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
III-យុទ្ធសាស្ត្រអនុវត្តច្បាប់			
<u>គោលបំណងទី១</u>៖ ពង្រឹងយន្តការទទួល និងដោះស្រាយពាក្យប្តឹង			
១. ពង្រីក និងបង្កើនវិសាលភាពយន្តការទទួលពាក្យប្តឹង	*១.១. ពង្រីកមធ្យោបាយ និងវិសាលភាពទទួលពាក្យប្តឹង*	*១.១.១. ចំនួនប្រអប់ស/ប្រអប់ប្រៃសណីយ៍ ដែលបានបង្កើន* *១.១.២. ចំនួនមធ្យោបាយទទួលពាក្យប្តឹងត្រូវបានបង្កើន* *១.១.៣. ចំនួនទីតាំងដែលត្រូវបានបង្កើន*	*អ.ប.ព.*
	១.២. បង្កើនប្រសិទ្ធភាពនៃការទទួលពាក្យប្តឹង	*១.២.១. រយៈពេលនៃការទទួល ប្រមូលពាក្យប្តឹងត្រូវបានកែលម្អ*	*អ.ប.ព.*
២. បង្កើនប្រសិទ្ធភាពយន្តការដោះស្រាយពាក្យប្តឹង	*២.១. កែលម្អនីតិវិធីក្នុងការដោះស្រាយពាក្យប្តឹង*	*២.១.១. រយៈពេលនៃការចុះបញ្ជីត្រូវបានកែលម្អ* *២.១.២. រយៈពេលនៃការសិក្សាប្រមូលព័ត៌មានបឋមត្រូវបានកែលម្អ* *២.១.៣. រយៈពេលនៃការបញ្ជូនពាក្យប្តឹងដើម្បីប្រជុំវិភាគពាក្យប្តឹងត្រូវបានពន្លឿន* *២.១.៤. រយៈពេលនៃការឆ្លើយតបរបស់ អ.ប.ព. ត្រូវបានពន្លឿន*	*អ.ប.ព.*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
		២.១.៥. រយៈពេលនៃការចេញលិខិតបំភ្លឺត្រូវបានពន្លឿន ២.១.៦. រយៈពេលនៃការចេញលិខិតផ្ទេរសមត្ថកិច្ចត្រូវបានពន្លឿន	
	២.២. ធ្វើទំនើបកម្មយន្តការដោះស្រាយពាក្យប្តឹង	២.២.១. ប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក្យប្តឹងត្រូវបានធ្វើទំនើបកម្ម ២.២.២.ប្រព័ន្ធតាមដានការធ្វើយតបរបស់ អ.ប.ព. ត្រូវបានធ្វើទំនើបកម្ម ២.២.៣. ប្រព័ន្ធតាមដានការចេញលិខិតបំភ្លឺត្រូវបានធ្វើទំនើបកម្ម ២.២.៤. ប្រព័ន្ធតាមដានការចេញលិខិតផ្ទេរសមត្ថកិច្ចត្រូវបានធ្វើទំនើបកម្ម ២.២.៥. មានមធ្យោបាយ/បច្ចេកទេសនៃការប្រមូលព័ត៌មាន	
គោលបំណងទី២៖ ពង្រឹងប្រសិទ្ធភាពនៃការប្រមូលព័ត៌មាន			
១. ពង្រឹងបណ្តាញ និងយន្តការប្រមូលព័ត៌មាន	១.១. កសាងពង្រីកបណ្តាញប្រមូលព័ត៌មាន	១.១.១. បណ្តាញប្រមូលព័ត៌មានត្រូវបានពង្រីក ១.១.២. ចំនួនកិច្ចសហការតភ្ជាប់ទិន្នន័យជាមួយស្ថាប័នសាធារណៈ	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	១.២. ពង្រឹងការគ្រប់គ្រងការប្រមូលព័ត៌មាន	១.២.១. ចំនួនការបណ្តុះបណ្តាលអ្នកប្រមូលព័ត៌មាន ១.២.២. ចំនួនកម្មវិធីព័ត៌មានវិទ្យា ដែលត្រូវបានរៀបចំ	អ.ប.ព.
	១.៣. ពង្រឹងការប្រមូល និងបូកសរុបព័ត៌មានចំហ ដែលបម្រើការស៊ើបអង្កេត	១.៣.១. ចំនួនព័ត៌មានចំហដែលត្រូវបានបូកសរុប	អ.ប.ព.
២. ពង្រឹងសមត្ថភាពស៊ើបអង្កេត រក្សាការសម្ងាត់វិជ្ជាជីវៈ	២.១. ជំរុញការអនុវត្តឯកសារណែនាំពីការស៊ើបអង្កេត (SOP)-និងការរក្សាការសម្ងាត់វិជ្ជាជីវៈរបស់អង្គភាពប្រឆាំងអំពើពុករលួយ	២.១.១. ការអនុវត្តឯកសារណែនាំពីការស៊ើបអង្កេត (SOP) ត្រូវបានផ្សព្វផ្សាយ ២.១.២. ឯកសារណែនាំពីការរក្សាការសម្ងាត់វិជ្ជាជីវៈ ត្រូវបានដាក់ចេញ	អ.ប.ព.
៣. ពង្រឹងប្រសិទ្ធភាព នៃការស៊ើបអង្កេត	៣.១. ពង្រឹងសមត្ថភាពស៊ើបអង្កេត	៣.១.១. ចំនួនវគ្គបណ្តុះបណ្តាលជំនាញស៊ើបអង្កេត ៣.១.២. ចំនួនមន្ត្រីបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញស៊ើបអង្កេត	
	៣.២. កសាងឯកសារណែនាំពីការរក្សាការសម្ងាត់វិជ្ជាជីវៈ	៣.២.១. ឯកសារណែនាំពីការរក្សាការសម្ងាត់វិជ្ជាជីវៈ ត្រូវបានដាក់ចេញ	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
<u>គោលបំណងទី៣</u>៖ ពង្រឹងការងារជំនាញ បច្ចេកទេស កោសលវិច័យបម្រើដល់ការអនុវត្តច្បាប់			
១. កសាងសមត្ថភាពជំនាញ បច្ចេកទេសកោសលវិច័យ	*១.១. ហ្វឹកហ្វឺនជំនាញកោសលវិច័យគ្រប់ប្រភេទ*	*១.១.១. មានកម្មវិធីអភិវឌ្ឍ ជំនាញកោសលវិច័យ* *១.១.២. ចំនួនការហ្វឹកហ្វឺនការងារកោសលវិច័យ*	*អ.ប.ព.*
	១.២. ហ្វឹកហ្វឺនជំនាញការពារទូទៅ រួមមានការពារសាក្សី និងអ្នកផ្តល់ព័ត៌មាន	*១.២.១. មានស្តង់ដារប្រតិបត្តិការ (SOP) ការពារសាក្សី និងអ្នកផ្តល់ព័ត៌មាន* *១.២.២. ចំនួនសាក្សី និងអ្នកផ្តល់ព័ត៌មានត្រូវបានការពារ* *១.២.៣. ចំនួនមន្ត្រីទទួលបានការហ្វឹកហ្វឺន*	*អ.ប.ព.*
	១.៣. ហ្វឹកហ្វឺនជំនាញតាមដាន	*១.៣.១. មានកម្មវិធីអភិវឌ្ឍជំនាញតាមដាន* *១.៣.២. ចំនួនមន្ត្រីទទួលបានការហ្វឹកហ្វឺន*	*អ.ប.ព.*
<u>គោលបំណងទី៤</u>៖ ជំរុញការងារកសាងសំណុំរឿង តាមដានការចោទប្រកាន់ និងការកាត់ទោស			
១. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់និងចូលរួមគាំទ្រដល់ស្ថាប័នអយ្យការ និងតុលាការ	*១.១. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក្នុងការកសាងសំណុំរឿង*	*១.១.១. ចំនួនវគ្គបណ្តុះបណ្តាលពាក់ព័ន្ធការកសាងសំណុំរឿង* *១.១.២. ចំនួនមន្ត្រីបានទទួលការពង្រឹងសមត្ថភាពក្នុងការកសាងសំណុំរឿង*	*អ.ប.ព.*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	១.២. ពង្រឹងការតាមដានចំណាត់ការរបស់ស្ថាប័នអយ្យការ និងតុលាការលើការងារចោទប្រកាន់-កាត់ទោស និងចូលរួមនីតិវិធីតុលាការគ្រប់ថ្នាក់ និងចងក្រងសំណុំរឿង	១.២.១. ចំនួនសំណុំរឿងដែល អ.ប.ព. បញ្ជូនទៅតុលាការ ១.២.២. ចំនួនបុគ្គលត្រូវបានចោទប្រកាន់ និងកាត់ទោស ១.២.៣. ចំនួនកម្មវិធីសវនាការបានទទួល ១.២.៤. ចំនួនលិខិតរដ្ឋបាលបានបញ្ជូនចេញពាក់ព័ន្ធនឹងសំណុំរឿងដែល អ.ប.ព. បញ្ជូនទៅតុលាការ ១.២.៥. ចំនួនឯកសារបានរក្សាទុកពាក់ព័ន្ធសំណុំរឿងរបស់ អ.ប.ព. ១.២.៦. ចំនួនសវនាការដែលបានចូលរួម ១.២.៧. ចំនួនសំណុំរឿងដែល អ.ប.ព. បញ្ជូនទៅតុលាការ ហើយត្រូវបានដោះស្រាយបញ្ចប់ដោយតុលាការ	អ.ប.ព. -តុលាការ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
IV-យុទ្ធសាស្ត្រគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិ			
<u>គោលបំណងទី១</u>៖ ពង្រឹងក្របខណ្ឌច្បាប់ គោលនយោបាយ និយ័តកម្ម			
១. ពង្រឹងការរៀបចំ និងចងក្រងឯកសារលិខិតបទដ្ឋានគតិយុត្ត	*១.១. ចូលរួមក្នុងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសមត្ថកិច្ច អ.ប.ព*	*១.១.១. ចំនួនកិច្ចប្រជុំបានចូលរួម*	*អ.ប.ព. -ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
	១.២. រៀបចំ និងចងក្រងឯកសារលិខិតបទដ្ឋានគតិយុត្ត	*១.២.១. ចំនួនលិខិតបទដ្ឋានគតិយុត្តបានរៀបចំ និងចងក្រង*	*អ.ប.ព.*
២. ជំរុញការអនុវត្តអនុសាសន៍ដាក់ចេញពីការត្រួតពិនិត្យអនុសញ្ញា UNCAC នៅកម្ពុជាទាំងពីរជុំ (ផែនការសកម្មភាព)	*២.១. រៀបចំ និងអនុវត្តផែនការសកម្មភាពអនុវត្តអនុសាសន៍ (ភាគីពាក់ព័ន្ធ, រយៈពេលអនុវត្ត, លទ្ធផលរំពឹងទុក)*	*២.១.១. មានផែនការសកម្មភាពអនុវត្តអនុសាសន៍* *២.១.២. មានរបាយការណ៍វឌ្ឍនភាពអនុវត្តអនុសាសន៍*	*អ.ប.ព. -ស្ថាប័នពាក់ព័ន្ធ*
៣. ជំរុញការអនុវត្តអនុសាសន៍ដាក់ចេញពាក់ព័ន្ធការងារប្រឆាំងការសម្អាតប្រាក់ (APG...)	*៣.១. រៀបចំ និងអនុវត្តផែនការសកម្មភាពអនុវត្តអនុសាសន៍ (ភាគីពាក់ព័ន្ធ, រយៈពេលអនុវត្ត, លទ្ធផលរំពឹងទុក)*	*៣.១.១. មានផែនការសកម្មភាពអនុវត្តអនុសាសន៍* *៣.១.២. មានរបាយការណ៍វឌ្ឍនភាពអនុវត្តអនុសាសន៍*	*អ.ប.ព.-ស្ថាប័នពាក់ព័ន្ធ*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
៤. ជំរុញការសម្របសម្រួលការប្រមូលមកវិញនូវផលនៃបទល្មើសឱ្យកាន់តែប្រសើរ	៤.១. រៀបចំ/កែសម្រួលក្របខណ្ឌច្បាប់នៃការប្រមូលមកវិញនូវផលនៃបទល្មើស	៤.១.១. ចំនួនលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានរៀបចំ/កែលម្អ	ក្រសួងយុត្តិធម៌-អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ
	៤.២. រៀបចំ/កែសម្រួលក្របខណ្ឌស្ថាប័ននៃការប្រមូលមកវិញនូវផលនៃបទល្មើស	៤.២.១. មានក្រសួង-ស្ថាប័ន/ផ្នែកទទួលបន្ទុកការប្រមូលមកវិញនូវផលនៃបទល្មើស	អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ
	៤.៣. ជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ ដើម្បីសម្រួលដល់ការប្រមូលមកវិញនូវផលនៃបទល្មើស	៤.៣.១. ចំនួនកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ ដើម្បីសម្រួលដល់ការប្រមូលមកវិញនូវផលនៃបទល្មើស	អ.ប.ព.-ក្រសួងយុត្តិធម៌-ក្រសួងស្ថាប័នពាក់ព័ន្ធ
៥. បង្កើនការយល់ដឹងពីច្បាប់ គោលនយោបាយ និយ័តកម្ម ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ និងការសម្អាតប្រាក់	៥.១. ផ្សព្វផ្សាយ បណ្តុះបណ្តាលច្បាប់ គោលនយោបាយ និងនិយ័តកម្មដល់ស្ថាប័នប្រឆាំងអំពើពុករលួយ ស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នតុលាការ	៥.១.១. ចំនួនអ្នកទទួលបានការផ្សព្វផ្សាយបណ្តុះបណ្តាលច្បាប់ គោលនយោបាយ និងនិយ័តកម្ម	អ.ប.ព.-អាជ្ញាធរអនុវត្តច្បាប់-តុលាការ
៦. ពង្រឹងតួនាទី-ភារកិច្ចរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ	៦.១. រៀបចំកែសម្រួលក្របខណ្ឌលិខិតបទដ្ឋានគតិយុត្តស្តីពីតួនាទី-ភារកិច្ចរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ	៦.១.១. មានលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានរៀបចំ/កែសម្រួល	អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	៦.២. ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានរៀបចំ/កែសម្រួល	៦.២.១. ចំនួនគោលដៅទទួលបានការផ្សព្វផ្សាយ	អ.ប.ព. -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន
<u>គោលបំណងទី២</u>៖ កសាង និងអនុម័តច្បាប់ និងបទប្បញ្ញត្តិស្របតាមកាតព្វកិច្ចអន្តរជាតិ			
១. ពិនិត្យលទ្ធភាពស្នើវិសោធនកម្ម ឬកសាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តថ្មីដើម្បីលើកកម្ពស់ការប្រឆាំងអំពើពុករលួយ	១.១. រៀបចំយន្តការ និងវិធានផ្ទៃក្នុងសម្រាប់អនុវត្ត និងសម្របសម្រួលដល់ការផ្តល់ជំនួយផ្នែកច្បាប់ និងការប្រមូលមកវិញនូវផលនៃបទល្មើស	១.១.១. មានយន្តការ និងវិធានផ្ទៃក្នុងសម្រាប់អនុវត្ត និងសម្របសម្រួលដល់ការផ្តល់ជំនួយផ្នែកច្បាប់ និងការប្រមូលមកវិញនូវផលនៃបទល្មើស	ក្រសួងយុត្តិធម៌-អ.ប.ព.
២. កសាងក្រមប្រតិបត្តិមន្ត្រីសាធារណៈ	២.១. ជំរុញ និងគាំទ្រការរៀបចំ និងដាក់ឱ្យអនុវត្តក្រមប្រតិបត្តិមន្ត្រីសាធារណៈ	២.១.១. មានក្រមប្រតិបត្តិមន្ត្រីសាធារណៈ ២.១.២. មានយន្តការអនុវត្តក្រមប្រតិបត្តិ ២.១.៣. របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តក្រមប្រតិបត្តិតាមក្រសួង-ស្ថាប័នសាធារណៈ	អ.ប.ព. -ក្រសួងមុខងារសាធារណៈ -ក្រសួង-ស្ថាប័នពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
V-យុទ្ធសាស្ត្រកិច្ចសហការជាតិ អន្តរជាតិ និងការរឹបអូសផលនៃបទល្មើស			
<u>គោលបំណងទី១</u>៖ ពង្រឹងភាពជាដៃគូលើការងារប្រឆាំងអំពើពុករលួយក្របខណ្ឌជាតិ			
១. ពង្រឹងកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ	*១.១. រៀបចំកិច្ចសន្ទនា/ពិគ្រោះយោបល់លើការងារប្រឆាំងអំពើពុករលួយ*	*១.១.១. ចំនួនកិច្ចសន្ទនា/ពិគ្រោះយោបល់*	*អ.ប.ព. -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន*
	១.២. គាំទ្រការជំរុញអនុវត្តតួនាទី-ភារកិច្ចក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន (អប់រំ-បង្ការទប់ស្កាត់ បណ្តុះបណ្តាល លទ្ធកម្ម និងត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តតួនាទី-ភារកិច្ចក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន)	*១.២.១. ចំនួនការគាំទ្រការជំរុញអនុវត្តតួនាទី-ភារកិច្ចក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ* *១.២.២. ចំនួនក្រសួង-ស្ថាប័នដែលបានចូលរួមអនុវត្ត* *១.២.៣. ចំនួនរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃលើការងារអនុវត្តតួនាទី-ភារកិច្ចក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ*	*អ.ប.ព. -ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយតាមក្រសួង-ស្ថាប័ន*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
២. ពង្រឹងកិច្ចសហការជាមួយ៖ -រដ្ឋសភា និងព្រឹទ្ធសភា -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -ក្រសួងមហាផ្ទៃ -ក្រសួងយុត្តិធម៌ -ក្រសួងមុខងារសាធារណៈ -ទីភ្នាក់ងារ អនុវត្តច្បាប់ និងស្ថាប័នពាក់ព័ន្ធ -វិស័យឯកជន សិក្សាធិការ សារព័ត៌មាន សង្គមស៊ីវិល ដែលគាំទ្រដល់ការងារប្រឆាំងអំពើពុករលួយ	២.១. រៀបចំកិច្ចសន្ទនា/ពិគ្រោះយោបល់លើការងារប្រឆាំងអំពើពុករលួយ ដោះស្រាយបញ្ហាប្រឈមដែលចាំបាច់ត្រូវរួមគ្នាដោះស្រាយ និងចែករំលែកបទពិសោធន៍រវាងតួអង្គពាក់ព័ន្ធ	២.១.១. ចំនួនកិច្ចសន្ទនា/ពិគ្រោះយោបល់	អ.ប.ព.-ក្រសួង-ស្ថាប័នពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
<u>គោលបំណងទី២</u>៖ ពង្រឹងភាពជាដៃគូលើការងារប្រឆាំងអំពើពុករលួយក្នុងក្របខណ្ឌអន្តរជាតិ			
១. បង្កើនទំនាក់ទំនងជាមួយនឹងភ្នាក់ងារប្រឆាំងអំពើពុករលួយក្នុង និងក្រៅតំបន់	*១.១. ជំរុញកិច្ចសហការគ្នារវាង អ.ប.ព. និងស្ថាប័នប្រឆាំងអំពើពុករលួយក្នុង និងក្រៅតំបន់ និងអង្គការអន្តរជាតិដែលគាំទ្រដល់ការងារប្រឆាំងអំពើពុករលួយ*	*១.១.១. ចំនួនកិច្ចសហប្រតិបត្តិការរវាង អ.ប.ព. និងស្ថាប័នប្រឆាំងអំពើពុករលួយ ក្នុងនិងក្រៅតំបន់ និងអង្គការអន្តរជាតិគាំទ្រដល់ការងារប្រឆាំងអំពើពុករលួយ* *១.១.២. ចំនួន MoU ឬកិច្ចព្រមព្រៀង ដែល អ.ប.ព. បានចុះ*	*អ.ប.ព.*
២. ជំរុញការចូលរួមក្នុងយន្តការពហុភាគីថ្នាក់តំបន់ និងអន្តរជាតិលើការងារប្រឆាំងអំពើពុករលួយ	*២.២. ចូលរួមវេទិកាថ្នាក់តំបន់ និងអន្តរជាតិ*	*២.២.១. ចំនួនវេទិកាថ្នាក់តំបន់ និងអន្តរជាតិដែលបានចូលរួម*	*អ.ប.ព.*
	២.៣. បង្កើនវិសាលភាពការកសាងសមត្ថភាពរបស់មន្ត្រី អ.ប.ព. ជាមួយដៃគូអន្តរជាតិ	*២.៣.១. ចំនួនដៃគូផ្តល់ការកសាងសមត្ថភាពរបស់មន្ត្រី អ.ប.ព.*	*អ.ប.ព.*
<u>គោលបំណងទី៣</u>៖ ជំរុញការងារកិច្ចសហការ និងការសម្របសម្រួលលើការងារប្រឆាំងការសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស			
១. ជំរុញការងារប្រឆាំងការសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស	*១.១. ពង្រឹងការស៊ើបអង្កេតដំណាលគ្នា រវាងសម្ពាធបទល្មើស និងបទល្មើសសម្អាតប្រាក់*	*១.១.១. ស្តង់ដារប្រតិបត្តិការ (SOP) សម្រាប់ការស៊ើបអង្កេត រួមទាំងការស៊ើបអង្កេតករណីសម្អាតប្រាក់ ត្រូវបានកែលម្អ* *១.១.២. ចំនួនការស៊ើបអង្កេតដំណាលគ្នារវាងសម្ពាធបទល្មើស និងបទល្មើសសម្អាតប្រាក់*	*អ.ប.ព. -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	១.២.ហ្វឹកហ្វឺនជំនាញស៊ើបអង្កេត វិភាគព័ត៌មានហិរញ្ញវត្ថុ រកផលនៃបទល្មើស ការចាប់យក និងបទល្មើសសម្អាតប្រាក់	១.២.១. មានកម្មវិធីអភិវឌ្ឍជំនាញស៊ើបអង្កេតវិភាគព័ត៌មានហិរញ្ញវត្ថុ រកផលនៃបទល្មើស ការចាប់យក និងបទល្មើសសម្អាតប្រាក់ ១.២.២. ចំនួនមន្ត្រីទទួលបានការហ្វឹកហ្វឺន	អ.ប.ព.
	១.៣. ជំរុញការគ្រប់គ្រង ចាត់ចែងបណ្តោះអាសន្ននូវវត្ថុចាប់យក និងការរឹបអូសឱ្យកាន់តែមានប្រសិទ្ធភាព	១.៣.១. ស្ថិតិនៃការគ្រប់គ្រង ចាត់ចែងបណ្តោះអាសន្ននូវវត្ថុចាប់យក ១.៣.២. ចំនួនការអនុវត្តការរឹបអូសតាមអំណាចសាលក្រម ឬសាលដីកាស្តាពរ	អ.ប.ព.-ក្រសួងយុត្តិធម៌ តុលាការ ក្រសួង -ស្ថាប័នពាក់ព័ន្ធ
	១.៤. ពង្រីក និងពង្រឹងកិច្ចសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់ តាមរកទ្រព្យពាក់ព័ន្ធនឹងបទល្មើស និងរឹបអូសមធ្យោបាយប្រព្រឹត្តបទល្មើស និងផលនៃបទល្មើស	១.៤.១. មានកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធជាតិ ស្ថាប័នអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់ តាមរកទ្រព្យពាក់ព័ន្ធនឹងបទល្មើស និងរឹបអូសមធ្យោបាយប្រព្រឹត្តបទល្មើស និងផលនៃបទល្មើស ១.៤.២. ចំនួនទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសដែលត្រូវបានរឹបអូស	អ.ប.ព.-ក្រសួងយុត្តិធម៌ តុលាការ ក្រសួង -ស្ថាប័នពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	១.៥.ពង្រឹងការតាមដានចំណាត់ការរបស់ស្ថាប័នអយ្យការ និងតុលាការលើការងារបង្កកចាត់ចែងជាបណ្តោះអាសន្នវត្ថុចាប់យក និងការរឹបអូសផលនៃបទល្មើស	១.៥.១. ចំនួនសំណុំរឿងដែលបានតាមដានពាក់ព័ន្ធនឹងការបង្កក ចាត់ចែងជាបណ្តោះអាសន្នវត្ថុចាប់យក និងការរឹបអូសផលនៃបទល្មើស ១.៥.២. ចំនួនទ្រព្យសម្បត្តិ ដែលត្រូវបានបង្កក ចាត់ចែងជាបណ្តោះអាសន្នវត្ថុចាប់យក និងការរឹបអូសផលនៃបទល្មើស	អ.ប.ព.-ក្រសួងយុត្តិធម៌ តុលាការក្រសួង -ស្ថាប័នពាក់ព័ន្ធ
២. បន្តប្រើប្រាស់យន្តការដែលមានស្រាប់លើកិច្ចសហការ និងការសម្របសម្រួលការងារសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស	២.១. សម្របសម្រួលការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស	២.១.១. ចំនួនករណីដែលបានសម្របសម្រួល	អ.ប.ព. -អាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធ
	២.២. ពង្រឹងសមត្ថភាពក្រសួង-ស្ថាប័ន និងតួអង្គពាក់ព័ន្ធ ដើម្បីជានាប្រសិទ្ធភាព និងនិរន្តរភាពនៃការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម	២.២.១. ចំនួនវគ្គបណ្តុះបណ្តាល និងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល	អ.ប.ព. -ក្រសួង -ស្ថាប័នពាក់ព័ន្ធ
	២.៣. រៀបចំ និងអនុវត្តផែនការសកម្មភាពដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម	២.៣.១. មានផែនការសកម្មភាព ដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម	អ.ប.ព. –ក្រសួង -ស្ថាប័នពាក់ព័ន្ធ

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
៣. កសាងសមត្ថភាពស្ថាប័ន-តួអង្គពាក់ព័ន្ធនឹងការងារជំនួយផ្នែកច្បាប់ និងឧបករណ៍គតិយុត្តបម្រើដល់ការងារជំនួយផ្នែកច្បាប់ទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព	៣.១. ហ្វឹកហ្វឺនមន្ត្រីអាជ្ញាធរកណ្តាល និងមន្ត្រីពាក់ព័ន្ធពីការងារពាក់ព័ន្ធជំនួយផ្នែកច្បាប់ទៅវិញទៅមក	៣.១.១. ចំនួនមន្ត្រីទទួលបានការហ្វឹកហ្វឺន ៣.១.២. ចំនួននៃការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក	អ.ប.ព. - ក្រសួងយុត្តិធម៌
	៣.២. រៀបចំនិងផ្សព្វផ្សាយ ឯកសារណែនាំពីការផ្តល់ និងស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក	៣.២.១. មានឯកសារណែនាំពីការផ្តល់ និងស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ៣.២.២. ចំនួនមន្ត្រីដែលទទួលបានការផ្សព្វផ្សាយ ៣.២.៣. ចំនួនស្ថាប័នតួអង្គទទួលបានការផ្សព្វផ្សាយពីឯកសារណែនាំ	អ.ប.ព. - ក្រសួងយុត្តិធម៌
	៣.៣. ជំរុញការអនុវត្តការស្នើសុំ និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព រួមទាំងការអនុវត្តដោយផ្ទាល់នូវសាលក្រម/សាលដីការបស់តុលាការបរទេស	៣.៣.១.ចំនួនសំណើ និងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក	អ.ប.ព.
៤. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទម្រង់ផ្សេងទៀត ក្រៅពីជំនួយផ្នែកច្បាប់ទៅវិញទៅមក	៤.១. កសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នូវទម្រង់ផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្រៅពីជំនួយផ្នែកច្បាប់ទៅវិញទៅមក	៤.១.១. ចំនួនមន្ត្រីត្រូវបានកសាងសមត្ថភាព	អ.ប.ព.
	៤.២. ជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការអន្តរជាតិទម្រង់ផ្សេងទៀត ក្រៅពីជំនួយផ្នែកច្បាប់ទៅវិញទៅមក	៤.២.១. ចំនួនកិច្ចសហប្រតិបត្តិការ	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
VI-យុទ្ធសាស្ត្រពង្រឹងសមត្ថភាព អភិបាលកិច្ចផ្ទៃក្នុង និងការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ			
គោលបំណងទី១៖ ពង្រឹងសមត្ថភាព ធនធាន និងសុចរិតភាពស្ថាប័នប្រឆាំងអំពើពុករលួយ			
១. បង្កើនចំណេះដឹង/ សមត្ថភាពមន្ត្រី អ.ប.ព.	*១.១. រៀបចំកម្មវិធី បណ្តុះបណ្តាលចំណេះដឹង/ សមត្ថភាពមន្ត្រី អ.ប.ព.*	*១.១.១. ចំនួនវគ្គបណ្តុះបណ្តាលបង្កើនចំណេះដឹង/ សមត្ថភាព*	*អ.ប.ព.*
	១.២. រៀបចំការសិក្សាស្រាវជ្រាវអំពីប្រធានបទនានា	*១.២.១. ចំនួនការសិក្សាអំពីប្រធានបទនានា*	*អ.ប.ព.*
	១.៣. សហការជាមួយដៃគូជាតិ និងអន្តរជាតិ ក្នុងការបញ្ជូនមន្ត្រី អ.ប.ព. ចូលរួមកម្មវិធីចែករំលែកបទពិសោធន៍ និងចំណេះដឹងនានា	*១.៣.១. ចំនួនកម្មវិធីចែករំលែកបទពិសោធន៍ និងចំណេះដឹង ដែលមន្ត្រី អ.ប.ព. បានចូលរួម* *១.៣.២.ចំនួនមន្ត្រី អ.ប.ព. ដែលបានចូលរួមកម្មវិធីចែករំលែកបទពិសោធន៍ និងចំណេះដឹង*	*អ.ប.ព.*
	១.៤. សិក្សាយន្តការអន្តរជាតិដែលចូលរួមធ្វើឱ្យប្រសើរឡើងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា	*១.៤.១. ចំនួនយន្តការអន្តរជាតិដែលបានសិក្សា*	*អ.ប.ព.*
២. ពង្រឹងការគ្រប់គ្រងមន្ត្រី អ.ប.ព. ស្របតាមច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិល	*២.១. រៀបចំប្រព័ន្ធនៃការគ្រប់គ្រងទិន្នន័យអំពីមន្ត្រី អ.ប.ព.*	*២.១.១. មានប្រព័ន្ធគ្រប់គ្រងមន្ត្រី អ.ប.ព.*	*អ.ប.ព.*
	២.២. លើកកម្ពស់ការងារអប់រំកាយ កីឡា និងសុខភាព	*២.២.១. ចំនួនកម្មវិធីអប់រំកាយ កីឡា និងសុខភាព* *២.២.២. ចំនួនមន្ត្រី អ.ប.ព. ចូលរួមកម្មវិធីអប់រំកាយ កីឡា និងសុខភាព*	*អ.ប.ព.*

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
៣. ពង្រឹកការធ្វើឌីជីថលនីយកម្ម	៣.១. រៀបចំ និងបំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សុសវៃរ និងប្រព័ន្ធព័ត៌មានចាំបាច់	៣.១.១. បំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សុសវៃរ និងអ៊ីនធឺណិត ៣.១.២. ចំនួនកម្មវិធីដំណើរការការងារដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងទិន្នន័យទម្រង់ឌីជីថល	អ.ប.ព.
	៣.២. បង្កើនការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និងជំនាញឌីជីថលដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ	៣.២.១. ចំនួនកម្មវិធីចែករំលែកបទពិសោធ និងចំណេះដឹងពាក់ព័ន្ធឌីជីថលដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ	អ.ប.ព.
៤. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍សម្ភារបច្ចេកទេស បន្ទប់មន្ទីរពិសោធន៍ និង ICT	៤.១. បំពាក់ឧបករណ៍សម្ភារបច្ចេកទេស ឧបករណ៍ពិសោធន៍និង ICTចាំបាច់បម្រើដល់ការងារជំនាញ	៤.១.១. មានឧបករណ៍សម្ភារបច្ចេកទេស និង ICTចាំបាច់បម្រើដល់ការងារជំនាញ ៤.១.២. មានបំពាក់ឧបករណ៍ពិសោធន៍សារធាតុជីវសាស្ត្រ និងគីមីសាស្ត្រ	អ.ប.ព.
	៤.២. រៀបចំពង្រឹកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត	៤.២.១. មានអគារបំពេញការងារបន្ថែម មានសាលបណ្ណាល័យ បណ្ណសារ និងសារមន្ទីរប្រឆាំងអំពើពុករលួយ	អ.ប.ព.
៥. ពង្រឹងការអនុវត្តបទប្បញ្ញត្តិផ្ទៃក្នុង និងសុចរិតភាព	៥.១. បន្តរៀបចំផ្សព្វផ្សាយបទប្បញ្ញត្តិផ្ទៃក្នុង និងសុចរិតភាព	៥.១.១. មានកម្មវិធីផ្សព្វផ្សាយ ៥.១.២. ចំនួនមន្ត្រីចូលរួមវគ្គផ្សព្វផ្សាយ	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
៦. បង្កើតការិយាល័យរាជធានី-ខេត្ត	៦.១. រៀបចំការិយាល័យប្រឆាំងអំពើពុករលួយរាជធានី-ខេត្ត	៦.១.១. ចំនួនការិយាល័យប្រឆាំងអំពើពុករលួយរាជធានី-ខេត្ត ៦.១.២. ចំនួនមន្ត្រីបញ្ជូនទៅតាមការិយាល័យរាជធានី-ខេត្ត	អ.ប.ព.
គោលបំណងទី២៖ ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី៤			
១. ពង្រឹងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ	១.១. រៀបចំរបាយការណ៍ការអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ	១.១.១. របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ	អ.ប.ព.
	១.២. រៀបចំរបាយការណ៍ប្រចាំឆ្នាំជូនសាធារណៈជនលើការងារប្រឆាំងអំពើពុករលួយ	១.២.១. ចំនួនរបាយការណ៍ជូនសាធារណៈជនលើការងារប្រឆាំងអំពើពុករលួយ	អ.ប.ព.
	១.៣. រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយជូនប្រមុខរាជរដ្ឋាភិបាល	១.៣.១. ចំនួនរបាយការណ៍របស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយជូនប្រមុខរាជរដ្ឋាភិបាល	អ.ប.ព.
VII-យុទ្ធសាស្ត្របញ្ញាសិប្បនិម្មិត (AI) អភិវឌ្ឍន៍សមត្ថភាព សន្តិសុខ ព័ត៌មានប្រឆាំងជម្លៀសពុករលួយដោយ AI			
គោលបំណងទី១៖ រៀបចំចាប់ផ្តើមឱ្យបានលឿន ការពង្រឹងសមត្ថភាព AI របស់ អ.ប.ព.			
១. បង្កើនចំណេះដឹង/សមត្ថភាព AI	១.១.រៀបចំផ្សព្វផ្សាយដាស់អារម្មណ៍មន្ត្រី អ.ប.ព. ឱ្យដឹង/ស្គាល់ពី AI	១.១.១. ផ្សព្វផ្សាយកម្រិត អ.ប.ព. ១.១.២. ផ្សព្វផ្សាយកម្រិតនាយកដ្ឋាន និងផ្នែកជំនាញ	អ.ប.ព.

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
	១.២.ចាត់វគ្គ និងការសិក្សាកម្រិតមធ្យម និងកម្រិតជំនាញ (ទ្រឹស្តីនិងការអនុវត្ត)	១.២.១. វគ្គរួមអំពីទ្រឹស្តី ១.២.២.វគ្គអំពីការអនុវត្ត AI	អ.ប.ព.
	១.៣.ត្រៀម និងបំពាក់មូលដ្ឋានសម្ភារ និងធនធានមនុស្ស	១.៣.១.ការបំពាក់មូលដ្ឋានសម្ភារខ្នាតតូចសាកល្បង ១.៣.២.ការបន្តបំពាក់មូលដ្ឋានសម្ភារខ្នាតមធ្យម	អ.ប.ព.
២. បង្កើនជំនាញ AI	២.១.បង្កើនជំនាញ AI ដោយ អ.ប.ព. ខ្លួនឯង	២.១.១. ទាញយកមន្ត្រី អ.ប.ព. ពូកែ-អ្នកការងារពូកែខាង AI មកបង្រៀនដល់មន្ត្រី និងអ្នកផ្សេងទៀត	អ.ប.ព.
	២.២.បង្កើនជំនាញ AI ដោយអ្នកពូកែក្នុងប្រទេស	២.២.១. ផ្ញាស់ប្តូរ ឬទៅសិក្សាពីបុគ្គល/ក្រុម/អង្គភាពក្នុងប្រទេសដែលពូកែ AI	អ.ប.ព.
	២.៣. បង្កើនជំនាញ AI ដោយអ្នកពូកែ AI បរទេស	២.៣.១.ចេញទៅក្រៅប្រទេសតាមរយៈទស្សនកិច្ច-សិក្ខាសាលា-វគ្គសិក្សា ២.៣.២.ទទួលអ្នកពូកែ AI បរទេសមកបង្ហាត់បង្ហាញនៅ អ.ប.ព.	អ.ប.ព.
គោលបំណងទី២៖ ជាបណ្តើរៗ អ.ប.ព. លើកកម្ពស់សមត្ថភាពដើម្បីទប់ទល់ឱ្យបានការប្រឈមនឹងបទល្មើស ឧក្រិដ្ឋកម្មបច្ចេកវិទ្យាដែលងាយកើតឡើងដោយបន្ទុំ			
១. ខិតខំទប់ទល់បាតុភាពអវិជ្ជមានពីការអភិវឌ្ឍ AI	១.១. ការងារលិខិតបទដ្ឋានគតិយុត្ត	១.១.១. លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង អ.ប.ព. ១.១.២. លិខិតបទដ្ឋានគតិយុត្តខាងផ្ទៃក្រៅ អ.ប.ព.	អ.ប.ព.
	១.២. រៀបចំយុទ្ធសាស្ត្រ និងយុទ្ធវិធីឈរដូចម្តេចចំពោះមុខការបែកបាក់បច្ចេកវិទ្យាជាប្ទុក-ភូមិសាស្ត្រ AI	១.២.១. ក្រុមសិក្សាស្រាវជ្រាវ អ.ប.ព. (ក្រុម ART) សិក្សាឱ្យបានទាន់ពេល	ក្រុម ART

សកម្មភាពគោល	សកម្មភាព	សូចនាករ	ស្ថាប័នពាក់ព័ន្ធ
២.ខិតខំទប់ទល់ការកើនឡើងបទល្មើសហិរញ្ញវត្ថុក្នុងប្រទេស និងឆ្លងដែន	២.១.រៀបចំក្រុមសិក្សាវិភាគពីបទល្មើសហិរញ្ញវត្ថុក្នុងប្រទេស និងឆ្លងដែន	២.១.១.រៀបចំក្រុមឱ្យបាន ២ ទៅ ៣ ក្រុម	
	២.២. តាមដានលំហូរ និងការលាងលុយកខ្វក់-ការលាក់ទ្រព្យសម្បត្តិដែលកើនដោយ AI	២.២.១. រៀបចំក្រុមតាមមូលបទនីមួយៗ	
៣.បង្កើនសមត្ថភាពកោសលវិច័យ	៣.១. បង្កើនសមត្ថភាពកោសលវិច័យអំពើក្លែងនានាដោយ AI	៣.១.១. រៀបចំក្រុមកោសលវិច័យ	អ.ប.ព.
	៣.២.បង្កើនសមត្ថភាពរាំងស្កាត់ការបោកបន្ទំ ពិសេសក្នុងការប្រឡងនានាដោយ AI	២.២.១. រៀបចំក្រុមស៊ើបអង្កេតពិសេស	អ.ប.ព.
៤. ចែករំលែកព័ត៌មាន និងសន្តិសុខព័ត៌មានដែលត្រូវចែករំលែក	៤.១. បង្កើនសមត្ថភាពជំនាញ ចែករំលែកព័ត៌មានតាម AI ដោយជានាសន្តិសុខ-សុវត្ថិភាពនយោបាយ	៤.១.១. ដំណើរការ-ពង្រឹង-ដកពិសោធន៍ពង្រឹង-ពង្រឹងជាប្រចាំអំពីការងារទាំងនេះ	អ.ប.ព.

៦. ផែនការយុទ្ធសាស្ត្រ និងថវិកា

ស.ប.ព. មានកញ្ចប់ថវិកាដោយឡែកនៅក្នុងថវិកាជាតិសម្រាប់ដំណើរការការងាររបស់ខ្លួន ហើយថវិកានេះមានបរិមាណស្មើនឹង ០,២% ទៅ ០,៣% នៃចំណាយចរន្តសរុបរបស់ថវិកាថ្នាក់ជាតិ ដោយផ្អែកលើអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។ អ.ប.ព. អាចស្នើសុំរាជរដ្ឋាភិបាលនូវថវិកាបន្ថែមតាមការចាំបាច់ក្នុងករណីពិសេស។ លើសពីនេះទៀត អ.ប.ព. មានសិទ្ធិទទួលនូវអំណោយ ឬជំនួយពីអង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍ ក្រោមលក្ខខណ្ឌដែលមិនមានទំនាស់ផលប្រយោជន៍។

អ.ប.ព. អនុវត្តនូវថវិកាសមិទ្ធកម្មដែលជាដំណាក់កាលចុងក្រោយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវបន្សុីជាមួយផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី៤។

៧. ការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យ និងវាយតម្លៃ តាមរយៈយន្តការដែលមានស្រាប់ និងត្រូវពង្រឹងបន្ថែមជាបន្តបន្ទាប់ មានសារៈសំខាន់ និងចាំបាច់ ដើម្បីជានាបានូវប្រសិទ្ធភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤ (២០២៥-២០៣០) នេះ ឱ្យមានតម្លាភាព និងគណនេយ្យភាព។

ការត្រួតពិនិត្យការអនុវត្តការងារនឹងត្រូវធ្វើឡើង ដើម្បីតាមដានវឌ្ឍនភាពនៃដំណើរការអនុវត្តការងារ លទ្ធផលការងារ និងសមិទ្ធផលនានា ធៀបទៅនឹងចំណុចដៅ ឬសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ សំដៅពង្រឹងប្រសិទ្ធភាព និងសម្រេចបានូវប្រសិទ្ធផលជាអតិបរិមាតាមការរំពឹងទុក។

សូចនាករតាមដានការអនុវត្តការងារ ត្រូវបានកំណត់ឡើងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ សម្រាប់ឱ្យនាយកដ្ឋាន ក្រុមការងារ និងផ្នែកពាក់ព័ន្ធនឹងត្រូវយកមកប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញជាប្រចាំ។ ការបូកសរុបលទ្ធផលការងារប្រចាំឆមាស និងប្រចាំឆ្នាំ ក៏នឹងត្រូវធ្វើឡើងផងដែរ បន្ថែមលើកម្មវិធីត្រួតពិនិត្យ និងវាយតម្លៃប្រចាំខែពីសំណាក់ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។

អាស្រ័យដោយសកម្មភាពមួយចំនួន នឹងត្រូវដឹកនាំការអនុវត្តដោយស្ថាប័នពាក់ព័ន្ធ ទិន្នន័យ/ធាតុចូលពីស្ថាប័នសាមី និងដើរតួសំខាន់ក្នុងការវាស់វែង ការអនុវត្តសកម្មភាពទាំងនោះ។

ទន្ទឹមនោះ ការវាយតម្លៃ នឹងត្រូវបានធ្វើឡើងដោយផ្អែកលើសូចនាករ ឬលក្ខណៈវិនិច្ឆ័យ ដើម្បីវាស់វែងទៅលើកម្រិតប្រសិទ្ធភាពប្រសិទ្ធផលឥទ្ធិពលបញ្ហាប្រឈមនិងនិរន្តរភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ដំណាក់កាលទី ៤ នេះ ។ ក្នុងករណីចាំបាច់ សកម្មភាពជាក់លាក់មួយចំនួនក៏នឹងអាចត្រូវបានជ្រើសរើសជាកម្មវត្ថុនៃការវាយតម្លៃផងដែរ។

៨. ការរាយការណ៍ និងផ្សព្វផ្សាយ

របាយការណ៍លទ្ធផលអនុវត្តការងារ និងសមិទ្ធផលការងារប្រចាំឆមាស និងឆ្នាំ នឹងត្រូវរៀបចំដោយក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ MEG ដោយផ្អែកលើទិន្នន័យ និងការវិភាគផ្តល់ឱ្យដោយនាយកដ្ឋាន ក្រុមការងារ និងផ្នែកពាក់ព័ន្ធនានាប្រចាំខែ ឆមាស និងឆ្នាំ។

ការផ្សព្វផ្សាយរបាយការណ៍ នឹងត្រូវធ្វើឡើងក្នុងទម្រង់សង្ខេបខ្លឹមសារនូវរបកគំហើញ និងលទ្ធផលពីការត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងវេទិការបស់ អ.ប.ព. ក៏ដូចជាក្នុងទម្រង់ និងមធ្យោបាយដទៃទៀត។

៩. ការកែសម្រួល

នៅក្នុងដំណើរការ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដំណាក់កាលទី ៤ (២០២៥-២០៣០) នេះ ក.ជ.ប.ព. នឹងធ្វើការពិគ្រោះយោបល់ ផ្តល់អនុសាសន៍ ការគាំទ្រ និងជំរុញដល់ អ.ប.ព. ដែលជាអង្គប្រតិបត្តិ នៃផែនការយុទ្ធសាស្ត្រជាតិឱ្យអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវ ផែនការសកម្មភាពដែលបានដាក់ចេញប្រកបដោយការទទួលខុសត្រូវខ្ពស់ ស្របតាមចក្ខុវិស័យ បេសកកម្ម គុណតម្លៃ គោលនយោបាយ និងយុទ្ធសាស្ត្រ ដែលបានដាក់ចេញ។ ជាមួយគ្នានេះដែរ ក.ជ.ប.ព. ក៏ទទួលស្គាល់នូវលទ្ធភាព និងការចាំបាច់ជាយថាហេតុក្នុងការកែសម្រួល ឬបំពេញបន្ថែមនូវរាល់សកម្មភាពទាំងឡាយណាដែលកាល:ទេស:ចាំបាច់តម្រូវឱ្យអង្គប្រតិបត្តិយកមកអនុវត្តស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រដឹកនាំរបស់រាជរដ្ឋាភិបាល និងបរិបទជាក់ស្តែងផងដែរ។

១០.សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ក្លៀវក្លា និងឋាមពល របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** បានចេញដំណើរដ៏ស្វាហាប់ ជាមួយនឹងកម្មវិធីគោលនយោបាយដឹកនាំ និងចំណាត់ការប្រកបដោយភាពជាក់ស្តែងនិយមជាច្រើន ដែលបានទាញចម្រាញ់ចេញពីសមិទ្ធផល និងបទពិសោធន៍ការងារជាច្រើន ពីរាជរដ្ឋាភិបាលអាណត្តិមុនៗ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់ នៃមហាបុរសកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ កម្មវិធីគោលនយោបាយ និងចំណាត់ការដែលអំណោយផលទាំងនេះរួមផ្សំជាមួយនឹងបទពិសោធន៍ទទួលបានក្នុងការអនុវត្តយុទ្ធសាស្ត្រដំណាក់កាលទី៣ (២០២០-២០២៥) កន្លងមក ក៏ដូចជាពីសំណាក់ការជ្រោស្រ័យទំនាក់ទំនង និងសហប្រតិបត្តិការការងារជាមួយភាគីពាក់ព័ន្ធទាំងអស់ ទាំងដោយផ្ទាល់ ប្រយោល ទាំងជាតិ អន្តរជាតិ បានដើរតួជាត្រីវិស័យបង្ហាញផ្លូវ - តម្រង់ទិស និងសម្រួចការយកចិត្តទុកដាក់ និងការផ្តោតការងារឱ្យកាន់តែចំគោលដៅផង ឱ្យកាន់តែមានវិសាលភាពទូលាយផង និងឱ្យកាន់តែមានភាពប្រទាក់ក្រឡាផង លើការដ្ឋានយុទ្ធសាស្ត្រទាំង៦ ដែលត្រូវបានកំណត់ និងដាក់ចេញបន្តអនុវត្តសម្រាប់រយៈពេល៥ឆ្នាំទៅមុខនៃការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលនឹងមានការដឹកនាំអនុវត្តផ្ទាល់ដោយអង្គភាពប្រឆាំងអំពើពុករលួយផង និងដោយភាគីពាក់ព័ន្ធដូចជាស្ថាប័នរដ្ឋ វិស័យឯកជន អង្គនីតិប្បញ្ញត្តិ ផ្នែកសិក្សាធិការ ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិលផងជាដើម។

សកម្មភាពយុទ្ធសាស្ត្រគន្លឹះៗ ព្រមទាំងសកម្មភាពផ្សេងៗទៀតដែលត្រូវបានរំលេចក្នុងផែនការដំណាក់កាលទី៤នេះ នឹងត្រូវអនុវត្តដោយភាពច្នៃប្រឌិត បត់បែនតាមកាល:ទេស: និងការរីរឹ្ចជាក់ស្តែងសំដៅទាញយកផលផ្លែផ្កាឱ្យបានកាន់តែច្រើនតាមតែអាចធ្វើទៅបាន។ ការអនុវត្តនូវសកម្មភាពទាំងនេះដូចជាសកម្មភាពថ្មីៗ ផ្សេងទៀតដែលតម្រូវឱ្យមានការដាក់ចេញក្នុងពេលអនុវត្តផែនការ នឹងត្រូវបន្ត បន្សុំ និងសម្របតាមកម្មវិធី និងគោលនយោបាយថ្មីៗបន្តបន្ទាប់ទៀត ដែលនឹងត្រូវដាក់ចេញដោយរាជរដ្ឋាភិបាលនាពេលខាងមុខ។ បន្ថែមពីនេះ ដើម្បីជានានូវប្រសិទ្ធភាព និងភាពជ្រាកដប្រជាក្នុងការអនុវត្តផែនការ

ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃចាំបាច់ត្រូវធ្វើជាប្រចាំ តាមរយៈមធ្យោបាយជួបពិភាក្សាជាមួយអ្នកអនុវត្តផ្ទាល់ផង ការប្រមូលទិន្នន័យ វិភាគទិន្នន័យ ស្ថិតិ និងវាយតម្លៃពីកម្រិតជោគជ័យ និងបញ្ហាប្រឈម នៃការអនុវត្តជាក់ស្តែងនូវសកម្មភាពដែលបានរំលេចផង តាមរយៈយន្តការទំនើបកម្ម ជាជំនួយដោយប្រើព័ត៌មានវិទ្យាជាដើម សំដៅជាក់ចេញនូវអនុសាសន៍គាំទ្រដល់ការអនុវត្តសកម្មភាពឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាដាក់ចេញនូវរបាយការណ៍គ្រប់ជ្រុងជ្រោយអំពីការអនុវត្តផែនការជាប្រចាំផងដែរ។

ក.ជ.ប.ព. បន្តប្តេជ្ញាចូលរួមចំណែកបំពេញភារកិច្ច និងតួនាទីក្នុងអាណត្តិ ៥ ឆ្នាំ បន្តទៅមុខរបស់ខ្លួនលើការងារគាំទ្រ ជួយជ្រោមជ្រែង ផ្តល់ប្រឹក្សាយោបល់ និងអនុសាសន៍ តម្រែតម្រង់ទិសដៅការងារប្រតិបត្តិការ និងការងារនានាដែលអង្គភាពប្រឆាំងអំពើពុករលួយអនុវត្ត សំដៅជានានុលោមភាពតាមច្បាប់ជាធរមាន ជានាប្រសិទ្ធភាព ប្រសិទ្ធផល និងជានាការបន្តដើរលើមាគ៌ាដ៏ត្រឹមត្រូវក្នុងការកសាងសង្គមកម្ពុជា សស្អាត ប្រាសចាកអំពើពុករលួយ និងគាំទ្រដល់ការងារដឹកនាំ និងអភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាសំដៅគោរព និងសម្រេចឱ្យបាននូវចក្ខុវិស័យ បេសកកម្ម គោលនយោបាយ គុណតម្លៃ គោលដៅ និងយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ដំណាក់កាលទី៤ (២០២៥-២០៣០)៕

ថ្ងៃចន្ទ ៧កើត ខែអាសាឍ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២៥

ប្រធាន	សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន	.....
អនុប្រធាន	ឯកឧត្តម តុប សំ	.....
សមាជិក	សម្តេចមហាមន្ត្រី កុយ សុផល	.....
	ឯកឧត្តម កើត រិទ្ធ	.....
	លោកជំទាវ សោម គីមស្វក់	.....
	ឯកឧត្តម ហោ ង៉ង្ហ ប៊ុនធាត	.....
	ឯកឧត្តម តាំង ស៊ុនឆ្លាយ	.....
	ឯកឧត្តម កែវ រ៉ាមី	.....
	ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឌិម យ៉ិនជៀង	.....
	ឯកឧត្តម ឆ្លាយ សំកុល	.....
	ឯកឧត្តម ជីវ កេង	.....

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាណត្តិទី៤

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាណត្តិទី៤ ធ្វើសច្ចាប្រណិធានចូលកាន់តំណែង
នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៥

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាណត្តិទី៤



ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាណត្តិទី៤ ធ្វើសច្ចាប្រណិធានចូលកាន់តំណែង
នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៥

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាណត្តិទី៤

កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ លើកដំបូង ដើម្បីបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិ អាណត្តិទី ៤។

កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ លើកដំបូង ដើម្បីបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិ អាណត្តិទី ៤។

កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ លើកដំបូង ដើម្បីបោះឆ្នោតជ្រើសតាំង ប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិ អាណត្តិទី ៤។

១. កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយដើម្បីស្តាប់របាយការណ៍ស្តីពីសកម្មភាពការងាររបស់ អ.ប.ព. និងអនុម័តលើកិច្ចការមួយចំនួនរបស់ អ.ប.ព.

២. ជំនួបពិភាក្សាលើការប្រយុទ្ធប្រឆាំងអំពើពុករលួយ

ជំនួបពិភាក្សាជាមួយភាគីអន្តរជាតិលើការងារប្រឆាំងអំពើពុករលួយ

២. ជំនួបពិភាក្សាលើការប្រយុទ្ធប្រឆាំងអំពើពុករលួយ





ជំនួបពិភាក្សាជាមួយភាគីអន្តរជាតិលើការងារប្រឆាំងអំពើពុករលួយ

៣. ការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

បាឋកថាស្តីពី "ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ជូនដល់មន្ត្រីនគរបាលជាតិ

បាឋកថាស្តីពី "ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានពន្ធដារ

បាឋកថាស្តីពី "ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ជូនបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

៣. ការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

បាឋកថាស្តីពី "ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ជូនវិស័យឯកជន

បាឋកថាស្តីពី "ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ជូនសាលាវិជ្ជាជីវៈ និងសាលារៀន

៣. ការផ្សព្វផ្សាយច្បាប់ស្តីពីការប្រែឆាំងអំពើពុករលួយ

ការអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៣. ការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

ការចុះផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើពុករលួយ
ក្នុងឱកាសអបអរសាទរទិវាជាតិ អន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ ធ្នូ។

៣. ការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

ការចុះផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើពុករលួយ
ក្នុងឱកាសអបអរសាទរទិវាជាតិ អន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ ធ្នូ។

៤. ការបង្ការ និងឧបស្គាត់អំពើពុករលួយ

ការសង្កេតការណ៍ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
និងប្រឡងតាមក្រសួង-ស្ថាប័ន ដើម្បីបញ្ជាក់ពីតម្លាភាព និងសុចរិតភាពនៃការប្រឡង

៤. ការបង្ការ និងឧបត្ថម្ភអំពើពុករលួយ

ការងារបង្ការ ទប់ស្កាត់អំពើពុករលួយ ក្នុងដំណើរការសង្កេតការណ៍ប្រឡងក្របខណ្ឌមន្ត្រីរាជការនៅតាមបណ្តាក្រសួង-ស្ថាប័ននានា។

៤. ការអនុវត្តច្បាប់បង្ក្រាបអំពើពុករលួយ

ការងារប្រតិបត្តិការកសាងសំណុំរឿងបញ្ជូនទៅតុលាការ

ការទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

៤. ការអនុវត្តច្បាប់បង្ក្រាបអំពើពុករលួយ



ការងារប្រតិបត្តិការកសាងសំណុំរឿងបញ្ជូនទៅតុលាការ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

ការចុះអនុស្សរណៈនៃការយោគយល់គ្នារវាង អ.ប.ព. និងប្រៃសណីយ៍កម្ពុជា

កិច្ចប្រជុំពិភាក្សាជាមួយវិស័យឯកជនលើកិច្ចការប្រឆាំងអំពើពុករលួយ



កិច្ចសហការអន្តរជាតិ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

វគ្គបណ្តុះបណ្តាលស្តីពីក្រោមកិច្ចសហប្រតិបត្តិការជាតិ

វគ្គបណ្តុះបណ្តាលស្តីពីក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

កិច្ចសហការជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

កិច្ចសហការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

កិច្ចសហការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

កិច្ចសហការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ







កិច្ចសហការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

៦. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

កិច្ចសហការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ

មជ្ឈោចាយដាក់ពាក្យប្តឹង

Hotline 1282
លេខទូរស័ព្ទ 023 223 954
023 221 653

ដាក់ពាក្យប្តឹងក្នុងប្រអប់សំបុត្រ
ប្រៃសណីយ៍ ដោយសរសេរនៅលើ
ខ្នងសំបុត្រថា
"ជូនអង្គភាពប្រឆាំងអំពើពុករលួយ"

ប្តឹងផ្ទាល់នៅ
អង្គភាពប្រឆាំងអំពើពុករលួយ
អគារលេខ ៥៤ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

ដាក់ពាក្យប្តឹងក្នុងប្រអប់សំបុត្រស
(តាមទីសាធារណៈក្នុងរាជធានីភ្នំពេញ)

សរសេរ Email រួចផ្ញើទៅកាន់:
complaint@acu.gov.kh

ឬសរសេរសារ រួចផ្ញើទៅកាន់
គេហទំព័រ Facebook:
Anti-Corruption Unit

ប្តឹងផ្ទាល់មកមន្ត្រី
អង្គភាពប្រឆាំងអំពើពុករលួយ

អាសយដ្ឋាន

អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

សូម Scan QR ខាងក្រោម
ដើម្បីទទួលបានជា Soft-Copy

ភាសាខ្មែរ

ភាសាអង់គ្លេស

ចោះពុម្ពផ្សាយដោយ

ស្ថាប័នប្រឆាំងអំពុករលួយ
អង្គភាពប្រឆាំងអំពើពុករលួយ
អគារលេខ ៥៤ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី៣ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

© ACU2025